សារព័ត៌មាន ខ្មែរប៉ុស្ដិ៍ ស.រ.អា

# KhmerPost USA

E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

## មាតិការរឿង

Issue 165 Nov 17th-Dec 05.th, 2014

Free

១-ដំណើរពីអាមេរិកទៅអាស៊ី..........................០២
៣-នៅកម្ពុជាក្រោមមានការប្រណាំងទូកចំនួន.....០៣
៤-ពិសារបាយថ្ងៃត្រង់បូនវ៉ែងក្រោយទៀត.............០៥
៥-លទ្ធផលនៃការបោះឆ្នោត ៤វិច្ឆិកា..................០៧
៦-សេចក្ដីថ្លែងការណ៍របស់អង្គការ-សមាគម.........១០
៧-ភាពជាប់គាំងនៃវត្តត្រៃរតនារាមនៅតែបន្ត.........១៤
៨-លទ្ធផលការបោះឆ្នោតអភិបាលរដ្ឋម៉ាសាឈូសេត.១៥
៩-ធនាគារពិភពលោកនិយាយថា កម្ពុជាចាំបាច់.......១៥

New Office: Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852

## វិចារណកថា

# គណបក្សសង្គ្រោះជាតិក្នុងដំណើរទៅរកជ័យជំនះ



ពិន សំខុន

**ដោយ : ពិន សំខុន**

ក្នុងដំណើរមកកម្ពុជាយើងបានឃើញស្ថានភាពនគររបស់យើងបានជួបអ្នកនយោបាយ ហើយបញ្ចេញបទវិភាគថ្មីពីស្រុកខ្មែរជូនជាសណ្ដាប់។

ក្រុងនយោបាយភ្នំពេញចង្អៀតចង្អល់ដោយអ្នកក្រអ្នកមានចម្រុះដោយកម្មករនឹងនយោជិកព្រោងព្រាតដោយមន្ត្រីមានអំណាចនឹងរាជការអង្កាច់អង្គោចអ្នករកស៊ីសម្រាប់ដុល្លាប្រមាណ១០%នឹងអ្នករកស៊ីសម្រាប់លុយរៀល៩០% **តទៅទំព័រទី ០៩**

# ពិធីបុណ្យអុំទូកត្រឡប់មកភ្នំពេញវិញ បន្ទាប់ពីបាត់ខ្លួន៣ឆ្នាំ




នៅកម្ពុជាក្រោមក៏មានបុណ្យអុំទូកដែរ សូមអាននៅទំព័រទី ០៣



ស្ទឹមិន្ទ ទៅមើលស្រែបងប្រុសដែលនឹងបានផលល្អ




# ទៅលេងក្រុមគ្រួសារនៅ ស្រុកបាយឆៅ នាកម្ពុជាក្រោម

**ដោយ : ពិន សំខុន**

យន្តហោះក្ងាតាបានហោះចេញពីភ្នំពេញម៉ោង៤:២០នាទី មកដល់ព្រៃនគរវេលាម៉ោង៥:៣០ល្ងាច នៃថ្ងៃព្រហស្បត៍ទី៦ ខែវិច្ឆិកា ឆ្នាំ ២០១៤ នាំយើងទាំងបីនាក់ត្រឡប់មកស្រុកកំណើតរបស់សូបិន ដែលបានបែកទៅសហរដ្ឋអាមេរិកកាលពី១៥ឆ្នាំមុន។ បន្ទាប់ពីចេញពីចំណតយន្តហោះមកបងប្អូនប្រមាណ២០នាក់មកពីភូមិបាយឆៅចម្ងាយជិះឡាន៥ម៉ោងនៅរង់ចាំខាងក្រៅយ៉ាងអន្ទះសារអបអរសាទរការមកដល់របស់យើង។ យើងនាំគ្នាចេញដំណើរត្រឡប់ទៅវិញ អស់ដំណើរ៥ម៉ោងទៀត នៅប្រមាណជាម៉ោង១២អាធ្រាតនឹងមកដល់ភូមិបាយឆៅស្ថិតនៅភាគខាងត្បូងនៃវៀតណាមវិញ។ រថយន្តយើងបានរត់ឆ្លងកាត់ក្រុងព្រៃនគរជិតមួយម៉ោង នាព្រលប់ថ្ងៃ៦វិច្ឆិកា ភ្នែកសម្លឹងក្រុងដែលយើងមិនដែលស្គាល់យ៉ាងយក

**តទៅទំព័រទី០៥**





បន្ទាប់ពីបាងកកទៅដល់ភ្នំពេញ

# ដំណើរពីអាមេរិកទៅអាស៊ី

**តពីលេខមុន**

ថ្វីត្បិតតែស្លាបព្រាចានលាងមិនសូវស្អាត តម្រូវឱ្យយើងសំអាតដោយខ្លួនឯងបន្ថែមតែម្ហូបទាំងនោះត្រូវបាន់សូបិនបានហូបឆ្ងាញ់សសើរមិនដាច់មាត់ ជាពិសេសកោតសសើរដល់របៀបរកស៊ីដែលនៅទីវាលប្រកតំបូលតែគ្មានជញ្ជាំងដ៏ធំដាក់តុបានប្រហែល១០០ភ្ញៀវចូលពេញអ្នកបំរើឆ្វាតឆ្វែងចុងភៅធ្វើម្ហូបតម្រៀបគ្នាជាជួរធ្វើម្ហូបជំនាញខុស១គ្នាតែបំរើភ្ញៀវបានរហ័សទាន់ចិត្ត ហើយបានឆ្ងាញ់ថែមទៀតជាការដែលមិនសូវជួបប្រទះ។

ស្អែកឡើងជាថ្ងៃដែលត្រូវចេញដំណើរពីបាងកកទៅភ្នំពេញវេលាម៉ោង៥ល្ងាចយើងត្រូវរៀបវ៉ាលីសពីព្រលឹមចេញដើរមើលទីក្រុងជាចុងបញ្ចប់ ហើយទៅព្រលានយន្តហោះតែម្តង។ ដោយថ្ងៃនេះ ជាថ្ងៃអាទិត្យ នួត ក៏យកភរិយាមកជូនដំណើរយើងដែរ ពីព្រោះជាថ្ងៃបិទហាងយើងមានបំណងទៅទស្សនាវិហារព្រះកែវមរកដនឹងព្រះបរមរាជវាំងថៃតែរកកន្លែងចតឡានមិនបានដោយមនុស្សច្រើនពេកចុងបញ្ចប់យើងរកបានកន្លែងមួយយ៉ាងលំបាកហើយពេលបាយថ្ងៃត្រង់ក៏កន្លងបន្តិចទៅហើយដែរ។

យើងបានរកឃើញភោជនាហារបែរទៅមាត់ទន្លេចៅប្រាយ៉ាយ៉ាងស្អាតច្រឡឹងមួយឈ្មោះ...។ ដែលមានចំណតកាណូតដឹកអ្នកដំណើរនៅពីមុខម្ខាងនឹងមុខម្ខាងទៀតមានអ្នកដើររកទិញរបស់ប្រើប្រាស់ ឬអនុស្សាវរីយយ៉ាងអ៊ូអរតាមផ្លូវ នាំក្បែរវាំង។ យើងបានហូបម្ហូបចំណីផ្លែក១ ហើយឆ្ងាញ់រហូតដល់ម៉ោង២រសៀលទើបចប់ ហើយរៀបចំ

តទៅទំព័រទី ១២






# ពិធីបុណ្យអុំទូកត្រឡប់មកភ្នំពេញវិញ...



ទិដ្ឋភាពបុណ្យអុំទូកនៅទន្លេចតុមុខ

ជារៀងរាល់ឆ្នាំនៅខែកត្តិកព្រះរាជាណាចក្រកម្ពុជាតែងតែប្រារព្ធពិធីបុណ្យអុំទូកបណ្តែតប្រទីបអកអំបុក និងសំពះព្រះខែ។ ពិធីនេះត្រូវបានគេធ្វើឡើងនៅគ្រប់ទីកន្លែងប្រកបដោយបរិយាកាសរីករាយកុះករជាទីបំផុត ។ ជាងនេះទៀតនៅតាមដងទន្លេសាបត្រង់មុំទន្លេចតុមុខទល់មុខព្រះបរមរាជវាំងក្នុងរយៈពេល ៣ថ្ងៃគឺថ្ងៃ១៤កើត ១៥កើត និងថ្ងៃ ១រោចខែកត្តិកមានប្រជារាស្ត្រខ្មែរជាច្រើនបានមកចូលរួមអបអរសាទរក្នុងពិធីបុណ្យអុំទូកនេះ។ ប្រទេសកម្ពុជាបានខកខានការប្រារព្ធនូវពិធីបុណ្យអុំទូកបណ្តែត ប្រទីបអកអំបុកនិងសំពះព្រះខែរយៈពេលជាប់ៗគ្នា៣ឆ្នាំមកហើយគឺឆ្នាំ ២០១១-២០១២-និង២០១៣ ។ នៅក្នុងឆ្នាំ២០១៤នេះពិធីបុណ្យដ៏សប្បាយអធិកអធមនេះបានចាប់ពីថ្ងៃទី៥ដល់៧ ខែវិច្ឆិកាខាងមុខនេះ ។

ពិធីបុណ្យអុំទូកនៅប្រទេសកម្ពុជាគឺជាពិធីបុណ្យមួយដែលកម្ពុជាត្រូវបានគេប្រារព្ធធ្វើតាំងពីសម័យបុរាណក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ដើម្បីរម្លឹកដល់គុំរូវីរភាពដ៏អង់អាចក្លាហានរបស់កងទ័ពជើងទឹកខ្មែរដែលបានរំដោះទឹកដី រួចផុតពីការជិះជាន់របស់ពួកខ្មាំងសត្រូវ (ពួកចាម) ។ ពិធីនេះបានទទួលការនិយមគាំទ្រពីសំណាក់ប្រជាពលរដ្ឋគ្រប់ទិសទី ហើយនាំគ្នាប្រារព្ធធ្វើជារៀងរាល់ឆ្នាំ **តទៅទំព័រទី ០៨**



ប្រទីបនៃស្ថាប័នជាតិ

## នៅកម្ពុជាក្រោមមានការប្រណាំងទូកចំនួន៤០ និងមានអ្នកទស្សនាប្រមាណ១លាននាក់

**ដោយៈ ពៅ មេត្តាថ្ងៃសុក្រ ទី៧ វិច្ឆិកា ២០១៤ http://vodhotnews.com**

ទូកងដែលចូលរួមប្រណាំងក្នុងទឹកដីកម្ពុជាក្រោម

ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅក្នុងទឹកដីកម្ពុជាក្រោមស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋអំណាចវៀតណាមបានរៀបចំអុំទូកតំណាលជាមួយកម្ពុជាដែរ ដែលក្នុងពិធីនោះមានទូកចំនួន៤០ ។





ទិដ្ឋភាពនៃការប្រណាំងទូកក្នុងទឹកដីកម្ពុជាក្រោម

ព្រះតេជគុណ ថាច់ វណ្ណា មានស្រុកកំណើតក្នុងទឹកដីកម្ពុជាក្រោមមានថេរដីកាថា ពិធីបុណ្យអុំទូកក្នុងទឹកដីកម្ពុជាធ្វើឡើងពីរថ្ងៃ គឺថ្ងៃទី៥ និងទី៦ ខែវិច្ឆិកា ខណៈនៅកម្ពុជាក៏រៀបចំពិធីបុណ្យអុំទូកថ្ងៃទី៥ ទី៦ និងទី៧ ខែវិច្ឆិកានេះដែរ ។ ព្រះតេជគុណបន្តថា ទូកចូលរួមប្រកួតមានចំនួន៤០ ដែលក្នុងមួយទូកៗ មានចំណុះ៧៥នាក់ ហើយក្នុងនោះទូកមានចំនួន១២កីឡាការនីជាអ្នកអុំ ។

ទូកទាំងអស់មកពីបណ្តាខេត្តដូចជា ខេត្តឃ្លាំង ព្រះត្រពាំង ឡុងហូរ ពល់លាវ ក្រមួនសទឹកខ្មៅ ហើយមកជួបជុំគ្នានៅទន្លេបាសាក់ ទីរួមខេត្តឃ្លាំង ក្នុងទូកនិមួយៗតំណាងឱ្យវត្ត១ ។ ពិធីបុណ្យអុំទូកនេះ បានបញ្ចប់នៅថ្ងៃព្រហស្បតិ៍ទី៥ ម្សិលមិញ ហើយទូកទទួលបានលេខ១ មកពីវត្តកំពង់ទឹកលេខ២មកពីវត្តពោធិ៍ព្រឹត្យហៅវត្តព្រែកក្ងួយចាស់ និងលេខ៣មកពីវត្តត្រាវិចថ្មី ។ ទូកទទួលបានជ័យលាភីទាំងបីត្រូវរដ្ឋអំណាចវៀតណាមរៀបចំជារង្វាន់ដោយឱ្យទូរទស្សន៍ និងទឹកប្រាក់ ។



ព្រះតេជគុណ ថាច់ វណ្ណា បញ្ជាក់ថា កីឡាករប្រកួតទាំងអស់ជាជនជាតិខ្មែរ តែចំនួនដែលចូលរួមទស្សនាភាគច្រើនជាជនជាតិខ្មែរ ហើយក៏មានជនជាតិវៀតណាម និងជនបរទេសផ្សេងទៀតចូលរួមទស្សនាដែរ ក្នុងនោះអ្នកទស្សនាសរុបប្រមាណ១លាននាក់ ។ ពិធីអុំទូកនៅក្នុងដែនដីកម្ពុជាក្រោមនេះ រៀបចំឡើងជារៀងរាល់ឆ្នាំមិនដែលអាក់ខានទេ ។

ក្រៅពីអុំទូកក៏មានពិធីអកអំបុក សំពះព្រះខែ ដូចនៅកម្ពុជាដែរ ហើយលើសពីនេះក៏មានការសម្តែងសិល្បៈបង្ហាញពីវប្បធម៌ខ្មែរដល់អ្នកទស្សនាផងដែរ ៕

# វ៉ាឌី ម៉ម ទៅធ្វើទស្សនៈកិច្ចនៅកម្ពុជា

តំណាងរាស្ត្រទើបជាប់ឆ្នោតនៅឡូវែលកាលពីដើមខែវិច្ឆិកា កំពុងធ្វើដំណើរទស្សនៈកិច្ចនៅកម្ពុជា ហើយបានជួបអ្នកតំណាងនយោបាយគ្រប់គណបក្ស ជាពិសេសបានចូលរួមជាមួយបាតុករទាមទារឱ្យមានការដោះលែងអ្នកទោសនយោបាយ១៧នាក់ ។ មិត្តថាចបៀក ជាច្រើនបានសម្តែងការអបអរសាទរ ។




ការិយាល័យ មេធាវី
ថូម៉ាស ស្ទាលីយ៉ាណូស

**Law Office of Thomas Stylianos Jr.**
**287 Appleton St. Lowell MA 01852**

- Immigration • អន្តោប្រវេសន៍
- Auto Crash • គ្រោះថ្នាក់រថយន្ត
- Divorce • លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ **978-459-5000 or 800-308-3766**

GRAND OPENING

Friendly Insurance

We serve: Auto, Home, Business owners, Flood Insurance




We do: Tax, Payroll, IRS Audit Representation

We are: License to Practice before the IRS, Enrolled Agent, IRS Certified Acceptance Agent

2 Convenient Locations To Serve You:

LOWELL
42 Branch St
(978)452-3800

LYNN
471 Western Ave
(781)593-4344

Office Hours: Mon- Fri 9 - 6 pm, Sat 9 - 2 pm
Visit us at www.friendlyins.com

ផ្តល់កិច្ចបំរើទាំងអស់សំរាប់សេចក្តីត្រូវការផ្នែកហិរញ្ញវត្ថុរបស់លោក-អ្នក

យើងនិយាយភាសាខ្មែរ



**Bopha Malone**
*Branch Relationship Manager, AVP*
430 Gorham Street, Lowell, MA
Bopha.Malone@ebtc.com
978-656-5561



**Sue Suon**
*Branch Service Specialist*
222 Merrimack Street, Lowell, MA
Sue.Suon@ebtc.com
978-656-5679

ក្នុងនាមជាធនាគារសហគមន៍, ធនាគារអ៊ីនធើប្រៃស៍ផ្តល់នូវកិច្ចបំរើផ្ទាល់ខ្លួនដល់អតិថិជនមកពីវប្បធម៌ចម្រុះ។ យើងអាចជួយលោក-អ្នកចំពោះ សេចក្តីត្រូវការផ្នែកហិរញ្ញវត្ថុទាំងអស់របស់លោក-អ្នក។ ទាំងអស់គ្នា យើងអាចបង្កើតឲ្យមានអាជីវកម្មដែលប្រកបដោយសេចក្តីសំរេច និងសហគមន៍រីកចំរើន រស់រវើក។

» ធនាគារផ្ទាល់ខ្លួន
» ធនាគារសំរាប់ជំនួញ
» និក្ខេប
» ការចាត់ចែងផ្នែកវិនិយោគ
» គ្រោងការចូលនិវត្តន៍
» និងជាច្រើនទៀត

សូមនិយាយជាមួយបុប្ផា ម៉ាឡូន ឬស៊ូ សួន ថ្ងៃនេះ ហើយឲ្យគេជួយលោក-អ្នកបង្កើតឲ្យមានភាពជោគជ័យ!

Enterprise Bank
CREATE SUCCESS
EnterpriseBanking.com

FDIC

# ពិសារបាយថ្ងៃនេះបួនខែក្រោយទៀត ចាំពិសារម្តងទៀត

**ទស្សនៈអ្នកអាន**

**ដោយ : គុល ប៊ុន្នី**

នៅប្រទេសយើង ដែលមានក្រុមបោកខ្លះប្រសិទ្ធនាមឱយងារ ជាប្រទេសអច្ឆរិយ មែនអច្ឆរិយសំរាប់អ្នកអាត្មានិយម អ្នកឆ្អិនក្បាលស៊ីក្បាល ឆ្អិលកន្ទុយស៊ីកន្ទុយ ។ បើនិយាយឱ្យងាយស្តាប់ទៀតអ្នកឱ្យតែបានលុយដុល្លារ ឬក៏បានត្រឹមស៊ី ផឹក គេឱ្យព្រួស! ឱ្យលូៗ។

សម័យនេះបច្ចេកវិទ្យាទំនើប អ្នកវិទ្យាសាស្ត្រគេចេះធ្វើឱ្យមនុស្សមានមាត់ទិញ ភ្នែកទិញត្រចៀកទិញ ចង់ដឹង ចង់ឃើញ ។ អ្នកមានមេត្តាករុណា តាមដានដឹងថា នៅប្រទេសជាតិខ្មែរ ត្រូវប្រទេសជិតខាងឈ្លានពានរំលោភយកដីតាមព្រំដែន បាត់រាប់ពាន់គីឡូម៉ែត្រ បើបង្អង់ឱបដៃឈរមើលគ្រប់គ្នាមិនយូរទេ គេពិតជាលេបដូចកម្ពុជាក្រោមមិនខាន ។ ឯនយោបាយមួយទៀតគេគាបសង្កត់ខ្មែរសិទ្ធឱ្យរាស្ត្រវេទនា ឈូសផ្ទះឈូសដំណាំ រំលោភយកដី តវ៉ាចាប់ដាក់គុកច្រវ៉ាក់ ខ្នោះ វ៉ៃរបួស ឈឺខ្លួនផង ឈឺចិត្តផង ខ្វះខាតផ្នែកជីវភាពផង រឿងអីមិនស្លាប់មុនអាយុអស់ ។

រឿងអ្នកធំអ្នកមានអំណាច ចង់មាន ចង់បានផ្លូវកាត់វិញ ដេញប្តូរទីកន្លែងពីដីស្អាតមានដំណាំទទួលផលចិញ្ចឹមជីវិតរស់ហើយ គេដេញឱ្យទៅដីព្រៃមានគ្រាប់មីន ខ្វះទឹក ខ្វះពេទ្យ គ្មានសាលារៀនឆ្ងាយពីផ្សារ ពីទីប្រជុំជន រឿងអីមិនវេទនាស្លាប់មុនអាយុ ។

របាយការណ៍អង្គការសង្គមស៊ីវិល នៅប្រទេសកម្ពុជា មួយថ្ងៃៗមានមនុស្សរាប់សែននាក់ស្រែកទ្រហោរយំ ។ កន្លែងខ្លះដេញហើយឃើញគេទុកដីទំនេរចោល ទៅសង់ខ្ទម សង់រោងបង្ករបង្កើនផលគេឈូសទៀត សួរថា : បើខ្លួនយើងគ្រួសារយើងជួបរឿងបែបនោះវិញទទួលបានទេ ។ ដូច្នេះហើយទើបអ្នកតាមដានដឹងឃើញហើយដំចូលរួមលះបង់ កម្លាំងកាយចិត្តថវិការួមគ្នាជួយគណបក្សសង្គ្រោះជាតិ ជួយទប់ទល់នោះមិនបានមួយភាគរយ ក៏កុំឱ្យបក្សកាន់អំណាចជិះសេះលែងដៃពេក សព្វថ្ងៃពលរដ្ឋខ្មែររងគ្រោះផ្ញើក្តីសង្ឃឹមបក្សសង្គ្រោះជាតិមួយគត់ សម័យនេះហើយមានក្រុមមនុស្សចម្លែកខ្លះមិនជួយចូកជួយចែវយកជើងមករាទឹក អត់ខ្មាស់? ចង់ឱ្យចាំអង្គការសហប្រជាជាតិទៅជួយថ្ងៃណា ខែណា ឆ្នាំណា ព្រោះតែវេទនា ពេកនឹងបានពលរដ្ឋខ្មែរ ខំនាំគ្នាសមកពីខេត្តឆ្ងាយៗ មកប្តឹងតវ៉ា។ ខ្លះហ៊ីង្សា កាប់សម្លាប់គ្នាមានរាល់ថ្ងៃ ប្តីសម្លាប់ប្រពន្ធ ប្រពន្ធសម្លាប់ប្តី ឪសម្លាប់កូន កូនសម្លាប់ឪ ខ្លះមិត្តភក្តិផឹកសម្លាប់គ្នាក្រពេក វេទនាផ្លូវចិត្តពេក សីលធម៌លែងមាននៅសល់ ។ នៅប្រទេសគេដូចជា អ៊ីរ៉ាក់ ស៊ីរី លីប៊ី មួយថ្ងៃៗគេស្លាប់រាប់រយ ទើបអន្តរជាតិគេទៅជួយ

តទៅទំព័រទី១៣

Khmer Owned & Operated

The Joint Commission National Quality Approval

Independence Home Care
Health Services LLC

ថែរក្សាសុខភាពដល់លំនៅដ្ឋានរបស់អ្នកទូទាំងរដ្ឋ

**Licensed Home Care Provider / Companion Services**

Certified Medicare/Medicaid • Joint Commission Accreditation • Home Nursing Care Provider Licensed by RI Department of Health

**Approved Provider of All State Programs:** Department of Elderly Affairs / Department of Human Services

**Skilled Nursing**
- Registered Nurses
- Home Health Aide
- Physical Therapy
- Occupational Therapy
- Speech Therapy
- Medical Social Worker

**Unskilled Nursing**
- Companionship
- Personal Care
- Bathing
- Dressing
- Safety
- Meal Preparation and Housekeeping
- Medication Reminders
- Errands and Assistance with Transportation

**Employment**
**Nurses & CNAs**
- Helping Over 100 Rhode Island Elderly Southeast Asians
- We Employ Over 50 Southeast Asians
- FREE ASSESMENT




*Let our family, take care of yours.*



**CALL US TODAY!**
**(401) 437-8337**
www.independencehs.com
Available 24/7

1179 Elmwood Ave.
Providence, RI 02907

- See our Khmer Video about Home Care at our website -

# មានបុគ្គលិកនិយាយភាសាខ្មែរ សម្រាប់ជួយលោកអ្នក




The smaller
the customer.

## Better Products, Better Service
## A community bank

| | Washington SAVINGS BANK We give you more | Big Banks |
|---|---|---|
| ATMs | 60,000 Nationwide free ATMs | Much Less! |
| Free Checking | YES! | Are you kidding? |
| Online Banking | Everything the 'Big Banks' have: Online banking, Bill payment, mobile banking, mobile deposit | We'll give them this one, they have it too |
| Free Designer Debit Card | YES, OVER 80 DESIGNS! | They are not that creative |
| Unlimited Debit Card Cash Rewards | YES! Anytime, Anywhere | No |
| Customer Service | Friendly local people who really want to help solve problems | One word "Voicemail" |
| Lending | Local decisions, by local people who sincerely want to work with you. Your place or ours, day, evening or weekend | See above |
| Bank Headquarters | Lowell, MA - your money and loan payments stay in your community | Canada, Spain Scotland, North Carolina |

"I switched from a large bank several years ago and have never regretted it. This is a small town bank with large bank benefits and far superior service than you get at the larger banks." - Joe S."

"I recently switched from Bank of America and love it here. Should have done it sooner!" – Kelly P.



**PLUS RECEIVE A FREE**
**kindle fire®**

- Monthly Direct Deposit of at least $1,000
- At least one monthly automatic payment
- An active debit card

Washington SAVINGS BANK
We give you more

washingtonsavings.com

**978-458-7999**

Member FDIC/ Member DIF / Equal Housing Lender

See reverse side for terms and conditions

# លទ្ធផលនៃការបោះឆ្នោត ៤ វិច្ឆិកា ២០១៤

**ដកស្រង់ដោយ : ថាច់ វណ្ណា**

លោក រ៉ាឌី ម៉ម ជាអ្នកនយោបាយជើងថ្មី ដោយបានការគាំទ្រពីសំណាក់មហាជននៅទីក្រុងឡូវែល រដ្ឋម៉ាសាឈូសេត មានសន្លឹកឆ្នោតចំនួន៣ពាន់៨រយ៧៤សន្លឹកឆ្នោត បានឈ្នះលើសន្លឹកឆ្នោតរបស់លោក ហ្វ្រែត បាហូ ២ពាន់៨៦សន្លឹកឆ្នោត ។

លោក រ៉ាឌី ម៉ម ជាតំណាងរាស្ត្រថ្មីបំផុតក្នុងរដ្ឋម៉ាសាឈូសេត ដែលគេមានជំនឿថា ជាអ្នករដ្ឋសភាមានដើមកំណើតជាខ្មែរមុនគេបង្អស់ក្នុងសហរដ្ឋអាមេរិក ។

លោក ម៉ម បានចូលភៀសខ្លួនចូលមកនៅសហរដ្ឋអាមេរិកតាំងពីអាយុ១២ឆ្នាំ គាត់បានបំរើកិច្ចការសហគមន៍ជាច្រើនឆ្នាំ ដោយផ្តល់នូវភាពទំនាក់ទំនងរវាងសហគមន៍ ក្រុមរបាំអង្គរ និងទីប្រឹក្សាវប្បធម៌ អប់រំក្នុងសហគមន៍ខ្មែរ នៅទីក្រុងឡូវែល មានប្រជារាស្ត្រជាច្រើននាក់ បាននិយាយថាៈ ពួកគេនឹងជួយផ្តល់ជាកម្លាំងក្នុងការឃោសនាបោះឆ្នោតឱ្យលោក ម៉ម ដើម្បីឱ្យគាត់ក្លាយខ្លួនជាអ្នកនយោបាយយ៉ាងសកម្មប្រសើរជាងសព្វថ្ងៃនេះ ។

លោក ម៉ម ជាអ្នកមានសំដីទន់ភ្លន់គាត់បាននិយាយដោយសង្ខេបក្នុងវេលាម៉ោង៩យប់ ពេលដែលគាត់បានឈ្នះឆ្នោតថាៈ នេះគឺជាការចាប់ផ្តើមនៃប្រវត្តិសាស្ត្រ"ក្នុងពេលនោះសំឡេងរបស់មហាជននៅក្នុងបន្ទប់លាន់ឮរំពងបណ្តាលឱ្យមានការលំបាកនឹងស្តាប់ ប៉ុន្តែមហាជនបានជំរុញឱ្យគាត់និយាយឡើងនៅអ្វីជាគោលដៅតទៅអនាគតរូបថតអ្នកដែលនៅឈរខាងក្រោយខ្នង គឺអ្នកស្រីច័ន្ទ វ៉ោន ជាបងស្រីលោក ម៉ម នឹងភរិយា សី រ៉ាឌី និងកូនទាំង៤នាក់ ។

លោក ម៉ម បានសម្តែងសុន្ទរកថា ៨នាទីដោយសម្តីយ៉ាងសុភាពរាបសារជាងពីពេលមុនៗដែលគាត់ធ្វើការឃោសនាបោះឆ្នោត ប៉ុន្តែគាត់មិនបានបញ្ជាក់លក្ខណៈពិសេសណាមួយឡើយ ។

លោក ម៉ម ពុំបានលើកឡើងនៅអ្វីជាកេរ្តិ៍តំណែលសំរាប់ប្រជារាស្ត្រនោះទេ ប៉ុន្តែលោកបានយល់ឃើញនៅភាពផ្សេងៗគ្នានៅជុំវិញខ្លួនគាត់រួចបាននិយាយថា "យើងទាំងអស់គ្នាជាជនជាតិអាមេរិកាំង ព្រោះហេតុនេះទើបយើងមានវត្តមាននៅទីនេះ" សូមអញ្ជើញមើល ពណ៌សម្បុរជុំវិញខ្លួនអ្នក តើល្អស្អាតដែរ ឬទេ? អ្នកទាំងអស់គ្នាមានក្រុមគ្រួសាររបស់អ្នក រីឯខ្ញុំក៏ដូច្នេះដែរ ។

លោក ម៉ម ជាជនម្នាក់ក្នុងចំណោម៤នាក់បានជ្រើសចេញពីគណបក្សប្រជាធិបតេយ្យ រួចហើយក៏បានឈ្នះលើលោក បាហូរ ជាអ្នកតំណាងឱ្យគណកម្មធិការសាលាបច្ចេកទេសក្រុងឡូវែល រួមនឹការឈ្នះឆ្នោតលើកនេះ លោក ម៉ម ជាតំណាងរាស្ត្រថ្មីមួយប្រចាំក្រុងក្នុងអំឡុងពេល១៥ឆ្នាំកន្លងមកនេះ ។

ភូមិសាស្ត្រ-តំបន់ទី១៨ មីឌីលសិច បានបញ្ចូលជារង្វង់មួយ ចាប់ពីខាងត្បូងទន្លេ ម៉ារីម៉ែក ទៅភ្ជាប់ទិសខាងលិចទល់នឹងផ្លូវឡូវែល ខនែ្នកតើ (Lowell Connector) រួមទាំងតំបន់ ខៃវិន ហៃឡិន (Highlands) តំបន់ក្រុងខ្មែរ និងមួយចំណែកដីក្រុងឡូវែលដែលជាតំបន់ខៃវិន មើភី (Kein Murphy´s) តាំងពីឆ្នាំ១៩៩៩ រហូតទល់ដើមឆ្នាំក្នុងឆ្នាំនេះពេលដែលគាត់បានប្តូរមុខតំណែងទៅធ្វើជានាយកក្រុងឡូវែល ។

លោ ហ្វ្រែដ បាហូ ប្រសិនជាបានឈ្នះឆ្នោតគ្រាន់តែឈ្នះទៅលើចំនួនសភាដែលមិនមែនជាគណបក្សប្រជាធិបតេយ្យ ឬគណបក្សសាធារណរដ្ឋ គាត់ពុំបានទទួលថវិការរូបិយបដិភាគសំរាប់ការឃោសនាបោះឆ្នោតឡើយ ។ ក្នុងខណៈនោះលោក ម៉ម បានទទួលការគាំទ្រយ៉ាងរឹងមាំពីគណបក្សប្រជាធិបតេយ្យក្នុងក្រុងឡូវែល និងគណបក្សដទៃទៀត ដូចជាលោកអភិបាល ដេវិល ផែតត្រិក (Deval Patrik) នឹងរដ្ឋសភា អេលីន ឌូណូហ្គូ (Eileen Donoghue) និងក្រសួងការពារសុវត្ថិភាពសាធារណៈក្រុងឡូវែល បន្ថែមទៀត ។

នៅវេលាម៉ោង៨:៤៥នាទីរសៀល ថ្ងៃបោះឆ្នោតក្នុងចំណោមជនជាច្រើនដោយរួមបញ្ចូលទាំងគ្រួសារ និងអ្នកគាំទ្រ បាហូ បានផ្សព្វផ្សាយដំណឹងថា បាហូ ត្រូវធ្លាក់ឆ្នោតពេលនោះ លោក បាហូ បាននិយាយថា "គាត់មានសេចក្តីរីករាយណាស់ដោយបានវិលត្រឡប់ទៅកាន់ជីវភាពមួយមិនចាំបាច់ការឃោសនាតទៅទៀត គាត់បាននិយាយបន្ថែមថា : "ពួកគេបានធ្វើការឃោសនាដ៏ធំក្រៃលែង" និយាយឱ្យដល់ការលំបាកនឹងប្រឈមមុខចំពោះតំបន់ដែលមានគណបក្សប្រជាធិបតេយ្យច្រើនក្រាស់ក្រៃលយ៉ានេះ "ខ្ញុំយល់ឃើញថា វាជាការលំបាកនឹងយកឈ្នះលើគ្រឹះស្ថាននោះណាស់" ៕

# Rady Mom won November 2014 election

LOWELL -- Rady Mom is the city's newest state representative, a political novice who won strong backing from the city's Cambodian voters to become what is believed to be the first Cambodian-American legislator in the country.




Mom, a 45-year-old physical therapist, defeated unenrolled candidate Fred Bahou Tuesday to claim the 18th Middlesex House District, winning more than 61 percent of the vote. In an unofficial tally, Mom won 3,847 to 2,386.

Mom, who moved to the United States at age 12 during his home country's Khmer Rouge regime, has been active in the Cambodian community for years, including the Cambodian Mutual Assistance Association, Angkor Dance Troupe and Khmer Cultural Council. Many in the city's Cambodian community have said they've been energized by his campaign, becoming more active in local politics than they would normally be.

Mom, who is soft-spoken, could barely be heard above the din of the room. He gave his victory speech shortly after 9 p.m.

"This is history. This is just the beginning," he said, but some still struggled to hear him.

"Speak up, representative. Speak up," **Continued to Page 11**


# ការិយាល័យច្បាប់ ហ្វង់ស៊ីស្កូ ជេ.រូសា



Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ ស៊ីស្កូ ជេ.រូសា



Andrew ´Bunna´ Taing, Esq.
មេធាវី ប៊ុណ្ណា អែនឌ្រូ តាំង

Law Office of:
FRANCISCO J. ROSA
ATTORNEY AT LAW

SERVICES
- Auto Accidents/ Personal Injury
- Bankruptcy
- Immigration
- Consumer Protection
- Real Estate Closings/Disputes
- Divorces Child Custody

តំណាងក្តីដូចខាងក្រោម
- គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ
- ក្ស័យធន
- អន្តោប្រវេសន៍
- ការពារអតិថិជន
- ទំនាស់ផ្នែកអចលនវត្ថុ
- លែងលះ និងអាណាព្យាបាលកិច្ច

1550 Middlesex Street Lowell, MA 01851
Phone: **978-458-0934** | help@attorneyrosa.com
www.attorneyrosa.com

## តមកពីលើ ០៣ ប្រវត្តិពិធីបុណ្យអុំទូក

ដោយមានការប្រណាំង ទូកអុំ និងទូកចែវ បុរស-នារីបណ្តែតប្រទីប អក អំបុក និងសំពះព្រះខែឆ្លុះបញ្ចាំងពីជំនឿសាសនាយ៉ាងមុតមាំ ។ ក្នុងឱកាសនោះគេសង្កេតឃើញប្រជាពលរដ្ឋមកពីបណ្តាខេត្តក្រុងមួយចំនួនយកទូកមកប្រណាំងដណ្តើមយកជ័យជម្នះឱ្យខេត្តរបស់ខ្លួនទៀតផង ។ នៅអំឡុងឆ្នាំ១១៧៧ ពួកចាមបានលើកទ័ពមកធ្វើការលុកលុយត្រួតត្រាប្រទេសកម្ពុជាអស់រយៈពេលប្រមាណ៤ឆ្នាំ ខណៈនោះព្រះបាទជ័យវរ្ម័ន (ជ័យវរ្ម័នទី៧) បានធ្វើការបង្រួបបង្រួមជាតិចំណាយពេលវេលារៀបចំយុទ្ធសាស្ត្រកងទ័ពប្រយុទ្ធប្រឆាំងចំពោះពួកចាមរហូតទទួលបានជ័យជម្នះ ហើយព្រះអង្គបានឡើងគ្រងរាជសម្បត្តិដឹកនាំប្រទេសជាតិនៅឆ្នាំ១១៨១ និងបានធ្វើឱ្យប្រទេសជាតិមានការរីកចម្រើនរុងរឿងដល់កម្រិតកំពូលថែមទៀត ។ តាមឯកសារប្រវត្តិសាស្ត្រ និងសិលាចារឹកនានាបានបញ្ជាក់ថា ព្រះបាទជ័យវរ្ម័នទី៧ បានឡើងគ្រងរាជសម្បត្តិនៅរាជធានីសោធបុរៈ និងរៀបចំកសាងប្រទេសជាតិឡើងវិញដូចជា កសាងប្រាសាទ សាលាសំណាក់ មន្ទីរពេទ្យ ផ្លូវ ថ្នល់ ប្រព័ន្ធធារាសាស្ត្រពាសពេញផ្ទៃប្រទេស ។

តាមរយៈចម្លាក់នៅប្រាសាទបាយ័នគេសង្កេតឃើញមានប្រាង្គប្រាសាទមុខបួនបែរនៅគ្រប់ទិស ដែលធ្វើឱ្យអ្នកប្រាជ្ញជាតិអន្តរជាតិមួយចំនួនយល់ថា "ប្រាសាទបាយ័ន ជាវិមានទេពក្នុងរឿងព្រេងនិទានមានលក្ខណៈអច្ឆរិយខ្លាំងណាស់" ។ នៅតាមជញ្ជាំងនៃប្រាសាទមានចម្លាក់ទាក់ទងទៅនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋទំនៀមទម្លាប់ប្រពៃណីសាសនា សិល្បៈ កីឡា ជាពិសេសការធ្វើសឹកសង្គ្រាមជាមួយពួកចាម ដែលដឹកនាំដោយព្រះបាទជ័យវរ្ម័នទី៧ទទួលបានជ័យជម្នះយ៉ាងធំធេងតាមរយៈចម្បាំងកងទ័ពជើងទឹក ។ អ្វីដែលគួរឱ្យកត់សម្គាល់នោះ គឺចម្បាំងកងទ័ពជើងទឹក ដែលត្រូវបានគេឆ្លាក់ជាប់នឹងជញ្ជាំងយ៉ាងល្អប្រណីតគួរឱ្យគយគន់ខ្លាំងណាស់ ។ ចម្លាក់នៃកងទ័ពជើងទឹកនេះត្រូវបានកុលបុត្រខ្មែរជំនាន់ក្រោយចងចាំពីគុណបំណាច់របស់បុព្វបុរសខ្លួនដែលបានរំដោះទឹកដីឱ្យរួចពីការត្រួតត្រារបស់ខ្មាំងសត្រូវ ហើយនាំគ្នាប្រារព្ធធ្វើពិធីអុំទូករម្លឹកគុណបំណាច់ដ៏ថ្លៃថ្លានេះជារៀងរាល់ឆ្នាំ ។ ពិធីនេះមានតាំងពីសម័យមហាអង្គររហូតមក ហើយប្រជាពលរដ្ឋខ្មែរតែងប្រារព្ធធ្វើពិធីបុណ្យអុំទូកដើម្បីធ្វើការប្រលងប្រណាំងទូកគ្រប់ប្រភេទទាំងបុរស និងស្ត្រីដែលមកពីគ្រប់ខេត្តក្រុង ។

ចំណែកបងប្អូនខ្មែរកម្ពុជាក្រោម ដែលមានឈាមជ័រដូចគ្នា ទោះបីជាសព្វថ្ងៃនេះបានឃ្លាតឆ្ងាយពីយើង ហើយរស់នៅក្រោមការត្រួតត្រារបស់ប្រទេសវៀតណាមយ៉ាងណាក៏ ដោយក៏ពួកគាត់នៅតែរក្សានូវទំនៀមទម្លាប់ប្រពៃណីខ្មែរដដែលគេតែងតែនាំគ្នាប្រារព្ធពិធីបុណ្យអុំទូកជារៀងរាល់ឆ្នាំមិនដែលខកខាននោះទេ ។ ជារៀងរាល់ឆ្នាំបងប្អូនខ្មែរកម្ពុជាក្រោមនៅខេត្តឃ្លាំង



បានប្រារព្ធធ្វើពិធីនេះ ដើម្បីរម្លឹកដល់គុណវីរភាពរបស់កងទ័ពខ្មែរនាសម័យមហានគរដែលដណ្តើមជ័យជម្នះពីពួកចាមក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ហើយរៀបចំប្រទេសជាតិឱ្យមានការរីកចម្រើនរុងរឿងដល់កម្រិតកំពូល ។ តាមឯកសារស្រាវជ្រាវតន្ត្រី និងជីវិតរបស់អ្នកស្រី កែវ ណារុំ បានបញ្ជាក់ថា ស្តេចក្រាញ់នៅកម្ពុជាក្រោមស្រុកបាសាក់បានរៀបចំកងទ័ព ជា៣ក្រុមដើម្បីការពារភូមិសាស្ត្ររបស់ខ្លួន គឺ ១-ទ័ពស្រួចហាត់ច្បាំងនឹងទូកដែលមានទ្រង់ទ្រាយដូចសព្វថ្ងៃ ។ ២-ទ័ពជំនួយហាត់ច្បាំងនឹងទូកចែវមានទ្រង់ទ្រាយដូចទូកសព្វថ្ងៃដែរ និង ទី៣-ទ័ពបាសាក់ គឺទូកធំមានដំបូលចែវក្តោងរាងស្រួចដំបូលកាត់មុខឥតជញ្ជាំងសម្រាប់ផ្ទុកស្បៀងកងទ័ព ។ របៀបបង្ហាត់ទូកចម្បាំងនេះ ស្តេចក្រាញ់នៅកម្ពុជាក្រោមតែងឱ្យមន្ត្រីនៅក្រោមឱវាទធ្វើការប្រលងប្រណាំងទូកនៅថ្ងៃទី ១៥កើត ខែកត្តិក ដោយឱ្យកេណ្ឌទាហានជើងគោក និងជើងទឹកមកធ្វើការសមយុទ្ធជារៀងរាល់ឆ្នាំរយៈពេលមួយយប់មួយថ្ងៃ និងបានក្លាយជាទំនៀមទម្លាប់ដ៏មានសារសំខាន់សម្រាប់ជនជាតិខ្មែរ ។

ក្នុងពិធីនេះមានការលយប្រទីប ដើម្បីឧទ្ទិសកុសលដល់ព្រះគង្គា និងព្រះធរណីដែលបានផ្តល់នូវសេចក្តីសុខសប្បាយភោគផលក្នុងការងារកសិកម្មរបរចិញ្ចឹមជីវិតប្រចាំថ្ងៃ ។ នៅពេលយប់តាមក្រសួងនីមួយៗមានបណ្តែតប្រទីបលម្អទៅដោយភ្លើងចម្រុះពណ៌គួរជាទីគយគន់ និងបាញ់កាំជ្រួចព្រោងព្រាតដែលមានមនុស្សម្នាចូលរួមទស្សនាយ៉ាងច្រើនកុះករបញ្ចេញនូវស្នាមញញឹមគ្រប់គ្នា ។ ចំណែកឯពិធីអកអំបុក និងសំពះព្រះខែត្រូវបានប្រជាពលរដ្ឋខ្មែរធ្វើឡើង ដើម្បីរម្លឹកដល់ព្រះពោធិសត្វដែលយកកំណើតជាទន្សាយបានលះបង់អាយុសង្ខារក្នុងការបំពេញបារមីទានដល់ឥន្ទ្រព្រាហ្មណ៍ ។

តាមគម្ពីរបានចែងថា កាលពីព្រះបរមពោធិសត្វដែលបានយោងកំណើតជាសត្វទន្សាយនៅថ្ងៃពេញបូរមី ព្រះពោធិសត្វទ្រង់បានឧទ្ទិសព្រះមំសៈ (សាច់) របស់ទ្រង់ជាទានបារមីដើម្បីបំពេញឱ្យបានត្រាស់ជាព្រះពុទ្ធ ។ ពេលនោះព្រះឥន្ទទ្រង់បានជ្រាបនូវសេចក្តីប្រាថ្នារបស់ពោធិសត្វទន្សាយ ហើយព្រះអង្គទ្រង់បានកាឡាព្រះអង្គជាព្រាហ្មណ៍ចាស់មកសុំព្រះមំសៈរបស់ព្រះពោធិសត្វជាអាហារ ។ ព្រះពោធិសត្វបានឱ្យឥន្ទព្រាហ្មណ៍ដុតបង្កាត់ភ្លើង ដើម្បីព្រះពោធិសត្វលោតចូលដោយអង្គឯង ។ ពេលភ្លើងឆេះហើយព្រះពោធិសត្វទ្រង់ក៏លោតចូលក្នុងភ្លើងតាមសន្យា ។ ដោយអំណាចនៃផលបុណ្យភ្លើងដែលកំពុងឆេះយ៉ាងសន្ធោសន្ធៅនោះក៏រលត់ទៅវិញទាំងអស់ ។ គ្រានោះឥន្ទព្រាហ្មណ៍ក៏ស្ទុះទៅត្រកងបីយកព្រះពោធិសត្វឡើងទៅដល់ព្រះចន្ទ ហើយបានអធិដ្ឋានធ្វើឱ្យរូបទន្សាយផ្តិតនៅក្នុងព្រះច័ន្ទជាប់ជាដរាបមក ។ ចាប់តាំងពីនោះរហូតមកមនុស្សគ្រប់រូបឃើញរូបទន្សាយច្បាស់នៅក្នុងព្រះចន្ទនាថ្ងៃ១៥កើត ។ ដោយយោងតាមជំនឿនេះហើយ ទើបប្រជាពុទ្ធបរិស័ទតែងតែប្រារព្ធនូវពិធីអកអំបុក និងសំពះព្រះខែនៅរៀងរាល់យប់ពេញបូរមីខែកត្តិកនៅតាមវត្តអារាម ភូមិក្រុង ដោយមានចេក-អំបុក និងទឹកដូង ដើម្បីគោរពបូជាដល់ព្រះពោធិសត្វ និងប្រាថ្នាសុំសេចក្តីសុខក្សេមក្សាន្តរៀងៗខ្លួនរហូតមក ៕ **វណ្ណៈ**





CONWAY
INSURANCE AGENCY

**រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៏ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។**
**យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :**

**ការធានារ៉ាប់រងគ្រួសារ**
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បៈ
- វត្ថុបុរាណ

**ការធានារ៉ាប់រងជំនួញ**
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- វិកខ៊ឹខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY INSURANCE AGENCY
77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

តមកពីទំព័រទី ១

## គណបក្សសង្គ្រោះជាតិក្នុងដំណើរទៅ...

អ្នកតស៊ូតវ៉ានឹងអ្នកបង្ក្រាបប្រដាប់អាវុធ ។ល។ ទាំងពីរក្រុម បដិបក្ខ មានការមិនសប្បាយចិត្តដាក់គ្នារៀងរាល់ថ្ងៃ ហើយក៏រីករាលដាលធំឡើងៗរាល់ពេលវេលាដែរ ។

នាឱកាសបោះឆ្នោតឆ្នោត២០១៣ហើយភ្លាមរហូតមកដល់ថ្ងៃនេះ មានសញ្ញាជាច្រើនបញ្ជាក់ថា ក្រុមអ្នកក្រីក្រ អ្នកតស៊ូ អ្នកទន់ខ្សោយ ក្លាយជាមានកម្លាំងទាមទារឱ្យមានការផ្លាស់ប្តូររបបហើយសភាពការណ៍នេះ ក៏កំពុងតែក្លាយជាការពិតផងដែរ ដោយក្រុមអ្នកក្រនេះ បានគាំទ្រចលនាសង្គ្រោះជាតិ ហើយគណបក្សសង្គ្រោះជាតិ ក៏ក្លាយជាមានអំណាចតទល់នឹងគណបក្សប្រជាជនអ្នកពូនក្តោបអំណាចបានភ្លាម ។ តំណាងទាំង៥៥រូបនៃគណបក្សសង្គ្រោះជាតិកំពុងកើនឥទ្ធិពលសម្រាប់កែរច្បាប់នឹងទម្លាប់ដែលគាបគណបក្សប្រជាជនឱ្យរបេះចេញពីអំណាចរាល់ថ្ងៃដែរ ។

តើចលនាប្តូរអំណាចនេះអាចធ្វើទៅរួចឬទេ? គ្រឹះនៃអំណាចរបស់គណបក្សប្រជាជនបានចាក់នៅគ្រប់ទិសទីនៃព្រះរាជាណាចក្រកម្ពុជាមានប៉ូលិសយោធាគណបក្សមានមន្ត្រីឃុំស្រុកខេត្តគណបក្សមានពាណិជ្ជកម្មឱស្សាហកម្មគណបក្សមន្ត្រីធំៗគណបក្សប្រជាជនខ្លួនឯងក៏សង្ឃឹមលើជាស្ថាពរជានិច្ច ពិសេសទៅទៀតនោះ សហគមន៍



គណបក្សសង្គ្រោះជាតិត្រៀមប្រឈមនឹងការបែកបាក់



គណបក្សហ៊្វុនស៊ិនប៉ិចត្រៀមខ្លួននឹងក្លាយជាគណបក្សប្រឆាំង

អន្តរជាតិនៅតែនៅពីក្រោយអ្នកឈ្នះឆ្នោតដោយយុត្តិធម៌ដដែល ។ រីឯគណបក្សកាន់អំណាចវិញកំពុងនៅស្ងៀមស្ងាត់បង្កការគៀបសង្កត់ទៅលើបក្សប្រឆាំង ដែលគេអាចយល់បានថា ១មិនខ្វល់ពីជ័យជំនះនៅថ្ងៃមុខ របស់គណបក្សសង្គ្រោះជាតិ ពីព្រោះទោះជាលទ្ធផលអ្វីក៏ដោយខ្លួននៅតែកាន់អំណាចដដែល ២ ត្រៀមប្តូរលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលមានកេរ្តិ៍ឈ្មោះអាសោជន៍ទៅហើយ ៗរក្សាតែឈ្មោះគណបក្សប្រជាជនដែលអាចនៅរក្សាជាគណបក្សគណបក្សប្រឆាំងក្នុងសភាជាតិ គឺជាផលចំណេញរបស់គណបក្សប្រជាជនដែលចង់ឃើញមានការខ្វែងមតិក្នុងរង្វង់ចលនាប្រឆាំងនឹងខ្លួន ដ៏វាបណាដែលមានការបែងចែកមតិក្នុងចលនានៃបក្សប្រឆាំង ដ៏វាបនោះសម្លេងឆ្នោតក៏នឹងបែក ឬក៏នឹងស្លាប់ដោយការមិនទៅបោះឆ្នោត ។ លោក ញឹក ប៊ុនឆៃ អតីតវីរបុរសអូរស្មាច់ជាអគ្គលេខាគណបក្សហ៊្វុនស៊ិនប៉ិចទីប្រឹក្សាលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានឋានជាឧបនាយករដ្ឋមន្ត្រីបាននិយាយថា "គណបក្សដ៏មានប្រវត្តស្នេហាជាតិរបស់លោកអាចនឹងប្រគល់ឱ្យទៅក្រុមប្រឆាំងនឹងរដ្ឋាភិបាលមួយ ដើម្បីឱ្យប្រជាពលរដ្ឋនៅតែអាចទាមទារអំណាចរបស់ខ្លួនបាននៅពេលគណបក្សសង្គ្រោះជាតិលែងមានការគាំទ្រ បន្ទាប់ពីគណបក្សនេះសម្រេចចិត្តចូលសភាមក" លោកបន្តថា នៅមានគណបក្ស "ខ្មែរស្រឡាញ់ខ្មែរ" ផ្សេងមួយទៀតក៏បំរុងនឹងកើតដែរ គឺក្រុមដែលមិនចូលចិត្ត សម រង្ស៊ី, កឹម សុខា នឹងមិនចង់ចូលជាមួយហ៊្វុនស៊ិន-ប៉ិច ។

គណបក្សដែលបំរុងលេចមុខមកទាំងពីរនេះច្បាស់ជាមិនបំបែកសម្លេងឆ្នោតគណបក្សប្រជាជនទេ គឺយកសម្លេងតែពីគណបក្សសង្គ្រោះជាតិតែប៉ុណ្ណោះ ។

នៅមានរូបភាពម៉្យាងទៀត ដែលនឹងធ្វើឱ្យគណបក្សធំៗភ្ញាក់ខ្លួន គឺក្រុមសហជីពកម្មករ

តទៅទំព័រទី១១



សហជីពកម្មករអាចនឹងក្លាយជាគណបក្ស

ធនធានមហាសាលរបស់ខ្លួន ថានឹងអាចធ្វើអ្វីក៏បានដែរ ។ មកទល់នឹងថ្ងៃនេះខែវិច្ឆិកា២០១៤ គណបក្សសង្គ្រោះជាតិមិនទាន់ដឹងថា បើនឹងឈ្នះឆ្នោតនៅឆ្នាំ២០១៨ នឹងយកអំណាចរដ្ឋពីកណ្តាប់ដៃគណបក្សប្រជាជនដោយរបៀបណានៅឡើយទេ ក្តីសង្ឃឹម គឺថានឹងត្រូវឱ្យមានការប្រកាសជាសាធារណនឹងដោយយុត្តិធម៌នូវលទ្ធផលនៃការបោះឆ្នោតមួយ បន្ទាប់ពីគណបក្សសង្គ្រោះជាតិជាអ្នកឈ្នះឆ្នោត ហើយម៉្យាងទៀតសង្ឃឹមថាប្រជាពលរដ្ឋខ្មែរអ្នកតស៊ូនៅតែទាមទារការផ្លាស់ប្តូរយ៉ាងរឹងមាំរបស់ខ្លួន រហូតដល់បានសម្រេចនៅសភាជាតិបាន នាពេលចាញ់ឆ្នោតជាយថាហេតុ ។

នៅលើហេតុទី២នេះគេបានសង្កេតឃើញថា ពាណិជ្ជករជាច្រើននិយាយពីការវិលត្រឡប់នៃលុយដុល្លារពីបរទេសរបស់ម្ចាស់លុយខ្មែរដែលខ្លាចគេឃាត់មិនឱ្យដកលុយពីធនាគារនៅបរទេសលុយដែលមានប្រភពមិនច្បាស់លាស់ នាឱកាសដែលមានបាតុកម្មធំៗបានផ្ទុះឡើង ។

តើធ្វើដូចម្តេចនឹងទប់ចលនាប្រជាជនក្រីក្រមិនឱ្យប្តូរអំណាចពីគណបក្សប្រជាជនបាន?ចលនាមិនពេញចិត្តចំពោះគណបក្សសង្គ្រោះជាតិចូល


ខូម័រ សិប្បកម្មច្នៃរូបសំណាកក្រានីត
COLMER MONUMENT WORKS

Memorials of Distinction
អាសយដ្ឋាន:1025 Lawrence Street Lowell, MA 01852-4898
(978) 452-7821



- Granite Memorials ផ្នូររាងបញ្ឈរធ្វើពីថ្មក្រានីត
- Granite & Bronze Markers ផ្នូរផ្តេកមានឆ្លាក់សំរិទ្ធលេថ្មក្រានីត
- Cemetery Lettering in Khmer មានឆ្លាក់អក្សរខ្មែរលើថ្មនៃផ្នូរ

COLMER Monument Works

ភាពថ្លៃថ្នូរ កិត្តិយស និងការគោរពជូនលោកអ្នក
Honor. Dignity. Respect for All

# សេចក្តីថ្លែងការណ៍របស់អង្គការ_សមាគមខ្មែរកម្ពុជាក្រោម ចំពោះការចាប់ផ្សឹកព្រះតេជគុណ សឺន ហាយ កាលពីល្ងាចថ្ងៃទី១១ វិច្ឆិកា ព.ស.២៥៥៨ គ.ស.២០១៤





KKC condemns in strong language upon Phnom Penh City Hall authority for arresting, detaining and defrocking Ven. Son Hay on November 11, 2014.

This is a serious violation of the Cambodian constitution, Article 4: Motto of Cambodia: Nation, Religion, King; Article 43: Buddhism is the religion of the State.

Buddha Dhamma has 227 Vinaya (or rules) for the Buddhist monks (Especially the Bhikkhu). There are 4 rules that the Buddhist monks can be defrocked (disrobed): The 4



p?r?jikas and not the authority of Phnom Penh City Hall authority. Action of the Phnom Penh City Hall authority violates Buddhism and the Constitution.

The Khmer Krom Coalition appeals to the Minister of Cult and Religion including the two Supreme Patriarch to intervene to re-ordain Ven. Son Hay and restore his status as a Bhikkhu in accordance to the Buddhist rules.

Unofficial translation

Photos courtesy Soun Sangwath, Luon Sovath



សមាគមន៍ខ្មែរកម្ពុជាក្រោម
THE KHMER KAMPUCHEA KROM COMMUNITY
LA COMMUNAUTÉ DU KHMER KAMPUCHEA KROM

លេខ:០៧៥/១៤ខកក

សេចក្តីថ្លែងការណ៍

អង្គការ-សមាគមខ្មែរកម្ពុជាក្រោម ថ្កោលទោសយ៉ាងខ្លាំង ចំពោះអាជ្ញាធររាជធានីភ្នំពេញ ដែលបានចាប់ព្រះតេជគុណ **សឺន ហាយ** សម្រាកស្បង់ចីវរ(ចាប់ផ្សឹក)កាលពីល្ងាចថ្ងៃទី១១ខែវិច្ឆិកាឆ្នាំ២០១៤។

នេះគឺជាការរំលោភបំពានធ្ងន់ធ្ងរលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចែងថាបាវចនានៃព្រះរាជាណាចក្រកម្ពុជាគឺ ***ជាតិ សាសនា ព្រះមហាក្សត្រ*** និង មាត្រា៤៣ ដែលបានចែងថា ***ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ***។

ព្រះវិន័យរបស់ព្រះសង្ឃក្នុងព្រះពុទ្ធសាសនាមាន២២៧សិក្ខាបទ។ មានបទល្មើសតែ៤ប៉ុណ្ណោះ គឺបារាជិក ទើបអាចចាប់ផ្សឹកបាន តែមិនមែនជាសមត្ថកិច្ចរបស់អាជ្ញាធរទេ។ សកម្មភាពរបស់អាជ្ញាធររាជធានីភ្នំពេញ គឺការរំលោភបំពានស្ថាប័នព្រះពុទ្ធសាសនា និងបំពានរដ្ឋធម្មនុញ្ញយ៉ាងធ្ងន់ធ្ងរ។

អង្គការ-សមាគមខ្មែរកម្ពុជាក្រោម សូមអំពាវនាវ ដល់ក្រសួងធម្មការនិងកិច្ចការសាសនាព្រមទាំងស្ថាប័នព្រះសង្ឃគណៈទាំងពីរគណៈ ព្រះមហាសង្ឃនាយក និងសម្តេចព្រះសង្ឃរាជ ជួយអន្តរាគមន៍ជាបន្ទាន់ ដើម្បីយកព្រះតេជគុណ សឺន ហាយ មកបំបួសជាភិក្ខុសង្ឃឡើងវិញ ដោយអនុវត្តទៅតាមព្រះវិន័យជាកំហិត។

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤
ប្រធានសមាគមខ្មែរកម្ពុជាក្រោម

ថាច់ សេដ្ឋា

ទីស្នាក់ការផ្ទះលេខ ៧២ ផ្លូវលេខ ៤២៦A, ភូមិគោកឃ្លាំង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥) ០១២ ៩០៨ ៨៨២ /៩៣ ៨៧ ៨៧ ០២
E-mail: thachsetha13@gmail.com Website: www.khmerkromngo.org

## តមកពីទំព័រទី ០១ ទៅលេងក្រុមគ្រួសារនៅភូមិបាយឆៅ...

ចិត្តទុកដាក់ឃើញម៉ូតូច្រើនជាងឡានបើកប្រជ្រៀតគ្នាយ៉ាងមានសណ្តាប់ធ្នាប់មានលក្ខណៈជាអ្នកប្រើជាជំនិះសម្រាប់ទៅធ្វើការច្រើនជាងជិះកំសាន្តក្នុងទីក្រុងដែលសម្បូរដោយពន្លឺមិនខុសគ្នាពីភ្នំពេញប៉ុន្មានទេ ហើយក៏មានឃើញសំណល់នៃអាគារចាស់ជំនាន់អាណានិគមខ្លះៗដែរ។ រីឯជនបទបន្តបន្ទាប់សុទ្ធសឹងជាវាលស្រែនឹងរុក្ខជាតិបៃតងស្រងាត់ជាសញ្ញាថា ជាពលរដ្ឋក្រីក្ររស់ដោយកសិកម្មក៏រិតតូចមានប្រជុំជនខ្លះៗលក់ម្ហូបចំណីរាត្រីយ៉ាងស្ងប់ស្ងាត់។ នៅក្នុងរថយន្តឯនេះបងប្អូនយើងមិនបានខ្វល់ខ្វាយនឹងប្រជុំជន ឬជនបទដែលខ្លួនមិនដែលបានឆ្លងកាត់ម្តងណាអ្វីនោះទេ រវល់តែសួរនាំពីដំណើរនឹងសួរសុខទុក្ខពីអ្នកដំណើរយ៉ាងអ៊ូអររហូតដល់ផ្ទះ។ អ្នកស្រី ហ៊ាង ជាម្តាយ សូបិន នឹងលោកកងជាឪពុកចុងរីករាយជាងគេដោយបានរៀបចំឱ្យកូនបានអឹកធឹក ក្រៅពីនេះមានតាសងបង លាង និងក្មួយៗក៏សម្តែងភាពរីករាយដោយបានមកចូលរួមមកទទួលភ្ញៀវជាបងប្អូនដ៏កម្រនេះដែរ។

ភូមិបាយឆៅស្ថិតនៅក្នុងខេត្តត្រាវិញ ជាភូមិកំណើតរបស់ សូបិន ធាត់ធំ និងចូលសិក្សា កាលពីនៅក្មេង ម្ល៉ោះហើយនៅសល់ស្លាកស្នាមនៃអនុស្សាវរីយ៍ក្តៅអ៊ុនៗនៅឡើយ នៅពេលបានជួបផ្ទះជំនាន់បុរាណមិត្តភ័ក្ត្រចាស់ៗជួបមាមីងនឹងកូនក្មួយធំៗអស់ទៅហើយ។ ថ្វីត្បិតតែរបៀបរស់នៅជួបជុំគ្រួសារហាក់ដូចជាមានសេរីភាពច្រើនតែក៏មានការផ្តាំផ្ញើរឱ្យមានការប្រុងប្រយ័ត្នសំដីពីព្រោះជញ្ជាំងមានត្រចៀកអាចនឹងនាំគ្រោះថ្នាក់ដល់ក្រុមគ្រួសារ ។ តាសងបាននិយាយរៀបរាប់អំពីការរស់នៅលើទឹកដីវៀតណាមថា ខ្មែរមាន៩៣ភាគរយនាវៀតណាមខាងត្បូងកំពុង

តទៅទំព័រទី ១៧



សូបិន្ត មកដល់អាមេរិកជាមួយនឹងប្អូនពីរនាក់ កាលពី១៥ឆ្នាំមុន



រូបថតបច្ចុប្បន្ន សូបិន្ត ជួបជាមួយនឹងគ្រួសារនៅកម្ពុជាក្រោម







ថតរូបមុខក្លោងទ្វារវត្ត

# Rady Mom won November...

Continued from page 07

new colleague, state Rep. Tom Golden of Lowell, yelled from one side of the room. The crowd erupted.

It was Golden who, moments before, pinned a Legislature pin on the lapel of Mom's jacket and hugged him in a tight embrace.

Mom spoke for about eight minutes and seemed like a more polished speaker than he did two months ago after winning the September primary. He told a few stories about his campaign but stayed away from talking about specific issues. Standing behind him were his sister, Chanvon, his wife, Sirady, and children Justin, Joee, Amelia and Allyanna.

Rady Mom celebrates his victory.

Rady Mom celebrates his victory. (SUN/GRANT WELKER)

"With all of their concerns, hearing their voice, they're speaking to me," he said of voters he met campaigning. "You spoke to me, and I found out your concerns are exactly like mine."

Mom didn't mention his Cambodian heritage but did acknowledge the diversity in the room around him.

"We are all Americans. That's why we're here," he said. "Take a second to look around you. Look at the color around you. Isn't it beautiful? You are family, as I am to you."

Speaking at Pailin City Restaurant on Branch Street, Mom promised to be "your bridge from the city of Lowell to Beacon Hill."

"I will fight," he said. "I will fight for justice."

Mom, whose only previous run for political office was a campaign for City Council in 2005, has prioritized public safety, including backing a proposal for the city to use Shotspotter, a gunshot-detection system to help police officers respond almost instantaneously to gunfire. He's also backed a proposal for a regional lock-up facility.

Mom finished first of four Democrats in the September primary before beating Bahou, who represents Lowell on the Greater Lowell Technical School Committee. In his victory Tuesday, he is the city's first new representative in 15 years.

The 18th Middlesex District encompasses an area of the city generally south of the Merrimack River and west of the Lowell Connector, including the Highlands, the Acre, Cambodia Town and part of downtown. It was Kevin Murphy's district from 1999 until earlier this year, when he resigned to become the Lowell city manager.

Bahou would have been the only member of the Legislature who isn't a Democrat or Republican. He failed to gain many strong endorsements during the campaign, while Mom won strong support from Lowell area Democrats and others in the party, like Gov. Deval Patrick, state Sen. Eileen Donoghue and Lowell public-safety unions.

The crowd at the Athenian Corner on Market Street, where Bahou and family and supporters were gathered, started filing out at around 8:45 p.m., as word circulated that Bahou had lost. Bahou said he was happy to return to a life without campaigning.

"They ran a great campaign," Bahou said, before alluding to the difficulty facing a Democrat in a heavily Democratic district. "I think it's tough to beat the establishment."

## តមកពីទំព័រទី ០៩ គណបក្សសង្គ្រោះជាតិក្នុងដំណើរ...

ក្រុមគ្រូបង្រៀនក្រុមតស៊ូដឺធ្លី អាចនឹងផ្តុំគ្នាជាគណបក្សមួយនាពេលបោះឆ្នោតខាងមុខក្រុមនេះនៅមានប្រជាប្រិយភាពខ្លាំងណាស់នៅឡើយ។ ថ្វីត្បិតតែពង្រឹងបានដោយសមរង្សីក៏ដោយ ឥឡូវនេះគឺជាក្រុមដែលមានឯករាជ្យពេញលេញការបែកចេញពីទំនោរទៅរកគណបក្សសង្គ្រោះជាតិអាចបង្កើតជាគ្រោះថ្នាក់ធំដល់សង្គ្រោះជាតិ បានរឹងការចរចារត្រូវរ៉ូវគ្នាបានមកវិញ ក៏ក្រុមសហជីពនេះនៅតែមានលទ្ធភាពនៅក្នុងអំណាចទៅថ្ងៃមុខដដែលជាមិនខាន។

តើគណបក្សសង្គ្រោះជាតិមានអ្វីខ្លះហើយសម្រាប់ធ្វើដំណើរទៅរកឈ្នះមានខ្លះដែរ តែនៅតិចតួចណាស់ ដូចជាគ្មានគណកម្មការឯកទេសខាងកងទ័ពគ្មានប្រព័ន្ធសេដ្ឋកិច្ចរឹងមាំគ្មានការធានាពីសហគមន៍អន្តរជាតិគ្មានការធានាពីចិន ឬវៀតណាមថាមិនច្រៀតជ្រែកក្នុងបញ្ហាផ្ទៃក្នុងខ្មែរគ្មានអ្នកមានបទពិសោធន៍ក្នុងរដ្ឋាភិបាល ។ល។ គេនិយាយថាគណបក្សសង្គ្រោះជាតិមានតែគំនិតយោបល់តែមិនអាចអនុវត្តបានទេ។

តែគណបក្សនេះ ក៏មានប្រវត្តិជាមេដឹកនាំ សុច្ចរិត ក្លាហាន កាពារមនុស្សទន់ខ្សោយ ស្នេហាជាតិ ។ល។ ដែលជាហេតុធ្វើឱ្យមានការគាំទ្រខ្ពស់ ឥឡូវនេះបានតម្លើងគុណភាពសមាជិកផ្លូវការដោយមានបញ្ចូលបញ្ញាវន្តខ្មែរដែលមានបទពិសោធន៍ខ្ពស់ត្រឡប់មកពីមហាប្រទេសខាងលិចមកប៉ះប៉ូវការខ្វះខាតធនធានមនុស្សដែលធ្លាប់មានពីពេលមុនបាន ។ នៅមានបេក្ខជនរបៀបលះបង់នេះច្រើនទៀត ដែលអាចហាក់មកជួយកម្ពុជាសម្រាប់លំដាប់ថ្នាក់ខេត្តខណ្ឌឃុំឱ្យអាចវិវឌ្ឍន៍តាមផ្លូវត្រូវមកវិញបានយ៉ាងឆាប់រហ័ស។

យោបល់បញ្ចប់ប្រទេសខ្មែរ ក៏ដូចជាបរទេសសេរីណាទាំងអស់ដែលត្រូវការតម្លាភាពយុត្តិធម៌នឹងសេរីភាពក្នុងនយោបាយដឹកនៃប្រទេស ជាពិសេសទៅទៀតប្រជាពលរដ្ឋត្រូវការជឿលើមនុស្សដែលត្រឹមត្រូវមានប្រវត្តិពិតប្រាកដឱ្យមកដឹកនាំប្រទេសមិនអាចសង្ឃឹមតែលើក្រុមគ្រួសារអ្នកធំដោយគ្មានការជ្រើសរើសត្រឹមត្រូវបានទេ។ សន្លឹកឆ្នោតនឹងលទ្ធផលលើកក្រោយនឹងឆ្លុះបញ្ចាំងការខិតខំប្រឹងប្រែងខ្មែរក្នុងគំនិតនេះ ៕

GREATER LOWELL CHAMBER OF COMMERCE

131 Merrimack Street – Lowell MA
978-459-8154
www.greaterlowellchamber.org

**A resource for your business or organization!**
Networking Events
Seminars
Resources
TV & Radio Shows
And more!

**សភាពាណិជ្ជកម្មនៅក្រុងឡូវែល គឺជាធនធានមួយសម្រាប់មុខរបរ ឬសម្រាប់អង្គការរបស់លោកអ្នក**
ព្រឹត្តិការណ៍ទំនាក់ទំនង
សន្និសីទ
រកធនធាន
កម្មវិធីទូរទស្សន៍ និងវិទ្យុ
និងនៅមានច្រើនទៀត

**នៅថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០១៤ និងមានតាំងពិពណ៌ពាណិជ្ជកម្ម និងបង្ហាញផលិតផលនៅសណ្ឋាគារ រ៉ាឌីសាន់ នៅឆែមហ្វត។**

Save the Date: Business Expo & Showcase on October 28th at the Radisson Hotel & Suites in Chelmsford.



តមកពីទំព័រទី ២ ដំណើរពីអាមេរិកទៅអាស៊ី...


ដោះលែងព្រាបនៅមុខព្រះអង្គដងកើ

ទៅព្រលានយន្តហោះតែម្តង...តែចំពេលស៊យពេលចេញពីភោជនីយដ្ឋានឡានបានត្រូវប៉ូលិសចាក់សោរកង់ជាប់ ពីព្រោះយើងឥតបានឃើញថា ជាកន្លែងហាមឃាត់ ម្លោះហើយ ទូត បានរត់ការណ៍បង់ពិន័យនឹងហៅនគរបាលមកដោះកង់ចេញដល់ម៉ោង៣ទើបចប់ការណ៍តែម៉ោង ក៏រំកិលឆ្ងាយណាស់ហើយដែរ ។ ទូត បានបោះពួយរថយន្តយ៉ាងអស់សង្ឃឹមសំដៅទៅព្រលានយន្តហោះដែលពេលកំណត់ចេញដំណើរនៅម៉ោង៥:១០នាទី តែយើងបានមកដល់ព្រលានម៉ោង៤.១០នាទីទៅហើយការរត់ប្រជែងនឹងម៉ោងកំណត់ចេញដំណើរក៏ផ្តើមឡើងដែរ គឺការបន្តកន្ទុយយកសំបុត្រយន្តហោះការដាក់វ៉ាលីសធំ១បញ្ចូលយន្តហោះការឆ្លងប៉ូលីសអន្តោប្រវេសន៍ការឆ្លងឆែកឆេរសន្តិសុខការរត់ទៅរកច្រកទ្វារដែលនៅសែនឆ្ងាយការរត់មិនអាចលឿនទៅបានដោយសារមានក្មេង... ចុងបញ្ចប់យើងបានឈ្នះម៉ោងចេញដំណើររបស់"បាងកកអ៊ែរវៃ Bangkok Airway"តែត្រឹមមួយសសៃសក់បែកញើសពេញខ្លួនដោយសារ






សូបិន្ត រាយការណ៍ឱ្យ Facebook



ប៉ុណ្ណារ៉ូ រត់បានលឿនជាងការបានស្មានហើយគេសប្បាយនឹងរុញវ៉ាលីសដ៏ធំតែរអិលស្រួលលេងជាល្បែងផងជួយភាពស្តាយឥវ៉ាន់រយិងរយោងរបស់ខ្ញុំឱ្យមានភាពប្រសើរបាន ។

អារទទឹកជោកដោយញើសពេញខ្លួនតែសប្បាយចិត្តនឹងរត់ទាន់ពេលចេញដំណើរហើយនឹងបានមកដល់ភ្នំពេញនៅ៥០នាទីទៀតនេះ ។

## ស្រុកខ្មែរដែលខ្ញុំខានឃើញ១២ឆ្នាំមក ហើយ

យន្តហោះ"បាងកកអ៊ែរវេយ Bangkok Airway" បាននាំយើងមកចុះចតនៅអាកាសយានពោធិនតុងបន្ទាប់ពីហោះហើរចំនួន៥០នាទីពីទីក្រុងបាងកកមក ។ យើងបានមកដល់ចំណតយន្តហោះដ៏តូចបំផុតជាងព្រលានយន្តហោះដែលយើងទើបឆ្លងកាត់ទាំងអស់នៃពេលថ្មីៗនេះតែ ទោះជាយ៉ាងណាក្តីព្រលានយន្តហោះដ៏តូចនេះបានធ្វើឱ្យខ្ញុំរំភើបញាប់ញ័រដោយសារតែខ្ញុំទើបត្រឡប់មកជាន់ដីខ្មែរវិញជាលើកដំបូងបន្ទាប់ពីខកខានមិនបានមកឃើញកម្ពុជាចំនួន១២ឆ្នាំដ៏យូរមកហើយ ។

**ខេត្តកែបៈ ភ្ញៀវមកពីស្រុកបារាំងនិង ស.រ.អា.** ដែលនឹងចូលរួមពិធីការកូនមីរ៉ាតី និងដើរបានអង្គុយយ៉ាងណែនក្នុងរថយន្តបើស២៥កន្លែងបើកសំដៅទៅក្រុងកែបឥឡូវក្លាយជាខេត្តកែបដោយសារការបោះឆ្នោត កាលពីថ្ងៃទី១៧តុលា២០១៤ ។

**ខ្ញុំនៅសហរដ្ឋអាមេរិកប្រមាណជាង១០ឆ្នាំចុងក្រោយនេះមិនដែលបានត្រឡប់ទៅស្រុកកំណើត** ម្តងណាទេ មិត្តភ័ក្រ្តជាច្រើនតែងប្រាប់ថា បើទៅស្រុកខ្មែរពេលនេះមើលស្រុកមិនស្គាល់ទេ ដំណឹងរបៀបនេះរិតតែធ្វើឱ្យខ្ញុំចង់ទៅលេងស្រុកខ្មែរកាន់តែខ្លាំងឡើងថែមទៀត ។ ចុងបញ្ចប់ឱកាសទៅលេងស្រុកខ្មែរក៏មកដល់ដោយសារកូនស្រីពៅគេចង់រៀបចំពិធីមង្គលការតាមប្រពៃណីខ្មែរនៅស្រុកខ្មែរយើងជាឪពុកក៏ត្រូវតែសម្របសម្រួលតាមកូនតែប៉ុណ្ណោះ ។ តាមពិតទៅការសម្របសម្រួលតាមកូននេះក៏ជាគោលបំណងរបស់ខ្ញុំដែលចង់: ឃើញកូនខ្លួនរៀបការឱ្យបានពេញមុខស្របច្បាប់នឹងស្របប្រពៃណីជាប្តីប្រពន្ធខ្លាំងណាស់ដែរ ខ្ញុំតែងតែបញ្ចុះបញ្ចូលកូនស្រីទាំងអស់ឱ្យគិតគូររៀបការតាមប្រពៃណី ពីព្រោះជាចំណងគ្រួសារដែលរឹងមាំបានយូរអង្វែងជាងការចាប់ដៃគូរស្រករស់នៅស្ងាត់ៗតែខ្លួនឯងដូចដែលវប្បធម៌ក្មេងៗសម័យថ្មីគេតែងធ្វើនៅប្រទេសសេរីនេះ ។ បានឃើញកូនផ្តួចផ្តើមគំនិតនេះទៅហើយនោះក៏ប្រញាប់យល់ព្រមត្រៀមខ្លួនចូលរួមជាមេបាបំពេញមុខកូនភ្លាម ។



គូនស្រីសម្លាញមីរ៉ាតីនឹងដើរយុវជនជាតិបារាំងនឹងរៀបការតាមប្រពៃណីខ្មែរនឹងនៅចំពោះព្រះភក្រ្តព្រះមហាក្សត្រខ្មែរថ្ងៃទី២៤តុលាឆ្នាំ២០១៤ ។ ភ្ញៀវទាំងខាងប្រុសទាំងខាងស្រីសុទ្ធតែជាមិត្តភ័ក្រ្តនឹងជាមេបាកូនក្រមុំកូនកម្លោះប្រញាប់ជិះយន្តហោះធ្វើដំណើរពីប្រទេសមហាអំណាចទៅកាន់កម្ពុជាតាមបំណងប្រាថ្នាកូន និងជាឱកាសបានឃើញមាតុប្រទេសកម្ពុជាជាប្ញសគល់ដ៏ល្បីល្បាញផងមានតែម្តាយមីរ៉ាតីទេ ដែលនៅភ្នំពេញហើយជាស្រេចមិនចាំបាច់ទៅណាឆ្ងាយទេ ។ ហេតុអ្វីក៏ការកូននៅឯវាំងទៅវិញ? ខ្ញុំសូមឆ្លៀតឱកាសនិយាយដោះពីចម្ងល់នេះបន្តិច មីរ៉ាតី គឺជាកូនស្រីទីបីពៅរបស់ខ្ញុំជាមួយភរិយាមុនឈ្មោះ ស៊ីសុវត្ថិស៊ីលវីយ៉ា ជាព្រះញាតិវង្ស ហើយបានស្គាល់ព្រះមហាក្សត្របច្ចុប្បន្នតាំងតែពីនៅជាព្រះអង្គម្ចាស់





តទៅទំព័រទី ២៨

# Cambodia-Born US Politician Joins Prison Protest

By Chris Mueller and Mech Dara
| November 24, 2014

Three weeks after becoming the first Cambodian-American legislator in the U.S., Rady Mom joined hundreds of protesters in Phnom Penh on Sunday to demand the release of 17 imprisoned activists, opposition figures and monks from Prey Sar prison.

Mr. Mom, 45, who was elected as a Massachusetts state representative in the November 4 U.S. midterm elections, arrived in Cambodia last week for a two-week visit to the country.

"I feel pity for my brothers and sisters," a visibly upset Mr. Mom told some 200 protesters outside the maximum-security prison before passing the microphone to his spokesman, Khem Chantha.

"We call, through newspapers and the media, for the government to release our brothers and sisters," Mr. Chantha told the crowd. "Their crimes are not really serious—blocking traffic is not a penal offense."

Seven activists from the embattled Boeng Kak community were sentenced to one year in prison on November 11 after being convicted under the traffic law of obstructing traffic after they placed a bed frame in the middle of Monivong Boulevard. The stunt was intended to bring attention to flooding in their neighborhood.

The protesters and Mr. Mom hoped to meet with the 17 prisoners—a group that includes 11 activists, three CNRP figures and three monks—but were not allowed to enter the detention facility.

Anti-eviction activist Yorm Bopha, also from the Boeng Kak community, said that while disappointed at not being allowed inside, the protesters were heartened by Mr. Mom's presence Sunday.



"His support encourages and inspires us to fight for justice, and shows we are not alone," Ms. Bopha said. "We were happy to see him participate with us to demand the release of the 17 who have been unjustly imprisoned."

Prior to joining Sunday's demonstration, Mr. Mom met with Prime Minister Hun Sen on Thursday and opposition leader Sam Rainsy on Saturday. He plans to meet with a number of other CPP and CNRP officials throughout the next week and a half.

While visiting a school inside Phnom Penh's Svay Pope pagoda Sunday afternoon, Mr. Mom said that despite taking part in the morning's demonstration, the purpose of his trip was not political.

"The first [reason] was to have a little bit of vacation time," he said. "I also really wanted to have a connection—see the country where I was born—from a different point of view."

Mr. Mom said his meeting with Mr. Hun Sen last week was a way for him to view Cambodia through the eyes of the man who has ruled the country for nearly 30 years.

"[The meeting] was to meet a man, a prime minister, who runs this great nation…to get a little bit of insight on how he sees the country," he said.When asked if his view of the prime minister had changed after speaking with protesters and opposition lawmakers—who accuse Mr. Hun Sen's government of orchestrating some of the arrests—Mr. Mom said he did not know enough about the political situation to comment.

"I don't't know the whole story of all that," Mr. Mom said. "I'm more concerned [about] where I came from."

Mr. Mom was elected this month as the state representative for the 18th Middlesex district in Lowell, Massachusetts. Lowell has the U.S.'s second largest Cambodian-American population, numbering about 30,000.

Mr. Mom arrived in the U.S. with his family in 1982 after fleeing the Khmer Rouge regime and spending several years in a Thai refugee camp.

On Sunday, Mr. Mom said he hopes his story will inspire not only his constituents, but young Cambodians as well.

"I went to the States in 1982 without a word of English," he said. "I want to inspire men and women… whether that's in the States or here, to inspire them to step up, take pride in what they want to see changed. Don't just scream out, but step up and do something about it."

**(Additional reporting by Neou Vannarin)**

តមកពីទំព័រទី ០៥

## ពិសារបាយថ្ងៃនេះបួនខែក្រោយទៀត...

គេយកកប៉ាល់ទឹក យន្តហោះ កាំភ្លើងតូចធំទៅ ជួយសម្លាប់ទាំងសងខាង ឬទៅផល់ចាប់ពួកអាក្រក់ទៅចាប់មួយខែអស់ទេ ពួកអាក្រក់ ។

យើងទាំងអស់គ្នាឃើញហើយ ប្រទេសមួយៗដែល UN NATO អាមេរិកទៅជួយរាប់ឆ្នាំ មិនទាន់ឃើញចប់ងាយៗទេ ពីព្រោះអ្វី? ព្រោះពួកអាក្រក់មានលុយជួយអ្នកក្រឱ្យការពារវា ។

ដូច្នេះហើយទើបអន្តរជាតិសុខចិត្តនាំគ្នាជួយលុយរាប់ពាន់លានមួយឆ្នាំៗ ទោះបីដឹងថាពួក ហ៊ុន សែន យកទៅធ្វើមានបានគ្រប់គ្នាក្តីត្រឹមឃាត់គោរពសិទ្ធិមនុស្សៗៗ ។

ខ្ញុំចង់ជម្រាបអ្នករិះគន់គណបក្សសង្គ្រោះជាតិ បើអ្នកពិសារបាយថ្ងៃនេះហើយ បួនខែទៀតចាំអ្នកពិសារម្តងទៀតបាន ចារិះគន់បក្សសង្គ្រោះជាតិ ព្រោះពលរដ្ឋខ្មែរត្រូវការពិសារបាយរាល់ថ្ងៃមិនអាចចាំបានទេ ។ម្យ៉ាងទៀត អ្នកឃាត់ក្តី អ្នករិះគន់ក្តី អ្នកបង្កើតគណបក្សក្តី បើតាំងខ្លួនជាអ្នកនយោបាយជាអ្នកចេះជាអ្នកឆ្លាតចង់ឱ្យគេកោតទៅពូកែនៅស្រុកខ្មែរ ទៅជួបពលរដ្ឋខ្មែរផ្ទាល់ជួយគាត់សព្វថ្ងៃគាត់មានបញ្ហាអ្វីខ្លះ? បានជាគាត់មកភ្នំពេញ ទោះបីដឹងថា លទ្ធផលយ៉ាងណាមិនដឹង បែកក្បាលបាក់ដៃបាក់ជើងផងក៏មិនដឹង ។ ហើយទៅសួរផង អ្នកយាមផ្ទះ ហ៊ុន សែន អ្នកវៃពលរដ្ឋខ្មែរសាសន៍អីទៅហាមផងបើខ្មែរ កុំឱ្យវៃខ្មែរគ្នាឯង បើវាយយួនដេញឱ្យទៅស្រុកវាទៅ ។

សព្វថ្ងៃអ្នកមានមេត្តាករុណាទាំងក្នុង និងក្រៅប្រទេសផ្ញើលុយជួយជនរងគ្រោះរាល់ថ្ងៃ សុំទៅជួយសួរសុខទុក្ខក្រុមគ្រួសារពលករទៅក្រៅប្រទេស ហើយបាត់ខ្លួនព្រោះអ្វី?

បើអស់លោកអ្នកបានត្រឹមដើរស្រែកពីឆ្ងាយទេ អ្នកឯងអន់ជាង អ្នករត់ស៊ីកង់ម៉ូតូឌុបនៅស្រុកខ្មែរដែលឃើញខ្មែររងគ្រោះជួយដឹកទៅពេទ្យ ៕




# ភាពជាប់គាំងនៃវត្តត្រៃរតនារាមនៅតែបន្តស្វែងរកដំណោះស្រាយ(បន្ត)

**រៀបរៀងដោយៈ ពីទូ**


ប្រាហ៊ឹម កែ


សាន ប៊ិន


ចន្ទា គីម


ស ផែល

វត្តត្រៃរតនារាមនៅតែបន្តជាប់គាំងដោយសារគណកម្មការវត្តលើ តំណាងដោយលោកប្រាហ៊ុម កែនិងវត្តក្រោម តំណាងដោយលោកសានប៊ីនព្រមទាំងព្រឹទ្ធាចារ្យដែលដាក់ងារខ្លួនឯងថា ស្នូមទាំងប្រាំតំណាងឱ្យសហគមន៍ខ្មែរដែលបានចូលខ្លួនរកដំណោះស្រាយដើម្បីឱ្យវត្តបានបើកដំណើរការឡើងវិញនោះមិនបានឯកភាពគ្នាលើសំណើរទៅវិញទៅមក ។

ព្រឹទ្ធាចារ្យស្នូមទាំងប្រាំបានស្នើឱ្យគណកម្មការចាស់គឺវត្តលើនិងវត្តក្រោមដកខ្លួនលាលែងពីតំណែងរបស់ខ្លួនដែលកន្លងមក ថ្វីត្បិតតែបានទទួលការតែងតាំងស្របច្បាប់ដោយប្រជាជន ប៉ុន្តែគណកម្មការចាស់គឺវត្តលើនិងវត្តក្រោមមិនមានលទ្ធភាពធ្វើឱ្យវត្តត្រៃរតនារាមដំណើរការជាប្រក្រតីបានដូចនេះត្រូវទុកភារកិច្ចឱ្យពួកគាត់ជាអ្នកចាត់ចែងបន្តហើយសំណើរនោះត្រូវបានឯកភាពដោយភាគីខាងគណកម្មការវត្តលើគឺលោក ប្រាហឹមកែ ដែលយល់ថាសំណើររបស់ក្រុមព្រឹទ្ធាចារ្យស្នូមទាំងប្រាំដែលដំណាងឱ្យសហគមន៍ខ្មែរ គឺមានលក្ខណៈត្រឹមត្រូវស្មើភាពគ្នាលោកបានបញ្ជាក់ថា លោកចង់បញ្ចប់រឿងទាំងអស់ដោយគណកម្មការចាស់ស្ម័គ្រចិត្តលាលែងពីតំណែងទាំងអស់គ្នាទុកភារកិច្ចឱ្យព្រឹទ្ធាចារ្យចាស់ទុំជាអ្នករៀបចំវត្តឱ្យសហគមន៍បានធ្វើបុណ្យធ្វើទានឡើងវិញ ប៉ុន្តែបំណងលោក ប្រាហ៊ុម កែ ត្រូវបានបដិសេធដោយគណកម្មការវត្តក្រោមគឺលោកសានបិនជាប្រធានដោយលោកបាននិយាយថាមុនគណកម្មការរបស់លោកលាលែងចេញពីតំណែងលោកត្រូវបំពេញភារកិច្ចឱ្យចប់រួចរាល់ដោយគណកម្មការចាស់ត្រូវចូលរួមបង្កើតច្បាប់ទាំងអស់គ្នាដើម្បីជ្រើសរើសគណកម្មការថ្មីឯករាជ្យជាសាធារណៈដែលមានការចូលរួមបោះឆ្នោតជ្រើសរើសពីប្រជាជនក្នុងសហគមន៍ជាមុនសិនបន្ទាប់ពីគណកម្មការថ្មីឯករាជ្យតែងតាំងរួចរាល់ហើយទើបគណកម្មការចាស់យល់ព្រមលាលែងពីតំណែងដោយស្ម័គ្រចិត្ត ពីព្រោះលោកថាអស់ភារកិច្ចដែលត្រូវបំពេញតទៅទៀតហើយពីព្រោះគណកម្មការថ្មីត្រីវូបានបង្កើតឡើងដោយសហគមន៍ហើយដែរ ។

សារព័តិមានខ្មែរប៉ុស្តិ៍ក៏បានធ្វើកិច្ចសម្ភាសន៍ជាមួយលោកប្រាហឹមកែគណកម្មការវត្តលើនៅគេហដ្ឋានរបស់លោកផ្ទាល់នៅថ្ងៃទី៥ខែតុលាឆ្នាំ២០១៤។ លោក ប្រា ហឹមកែ បានថ្លែងថា បន្ទាប់ពីបានជួបជាមួយលោក ស ផែល តំណាងឱ្យវត្តក្រោម (តែលោក សាន ប៊ិន ថា មកជាឯកជន) ដោយជជែកគ្នារកដំណោះស្រាយឱ្យវត្តបានបើកដំណើរការធ្វើបុណ្យទានតទៅមុខទៀតដោយស្ថិតក្រោមឈ្មោះវត្តតែមួយដោយចង់ឱ្យការជជែកគ្នាច្បាស់លាស់ខ្ញុំបានបញ្ជាក់ជាមួយសផែលថាតើជាការនិយាយដោយស្មោះត្រង់ដើម្បីរកឱកាសឱ្យប្រជាជនខ្មែរយើងនៅរដ្ឋឡូវែលនេះបានសុខសន្តិភាពផុសចេញពីផ្លូវចិត្តមែនទេ? បើស្មោះត្រង់មែនចាំនិយាយគ្នាពីព្រោះខ្ញុំជាអ្នកបោះឆ្នោតដោយប្រជាជនហើយប្រជាជនមិនមែនឱ្យខ្ញុំមកធ្វើជាម្ចាស់វត្តទេ គឺឱ្យខ្ញុំមកជួយមើលការខុសត្រូវនៅក្នុងវត្តក្នុងការមកជួបខ្ញុំនេះត្រូវសម្តែងនូវភាពស្មោះត្រង់ដើម្បីឱ្យប្រជាជនជៀសផុតពីទុក្ខព្រួយដែលធ្លាប់មានពីស្រុកខ្មែររហូតមកដល់ស្រុកអាមេរិកនេះដោយត្រូវឆ្លងកាត់ការលំបាកដំបូងអត់ចេះភាសាគេ និងទំនៀមទំលាប់របស់គេដោយមកទីនេះសង្ឃឹមថាយើងមានវត្តអារ៉ាម

តទៅទំព័រទី ២៨


GATEWAY FAMILY DENTAL

www.gatewayfamilydental.com • (978) 455-5044

151 WARREN STREET, SUITE 120 LOWELL, MA 01852 (Same building as Social Security/near the courthouse)



DR. SERENA B. CHUOP

Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 13 years, she has been in private practices providing all aspects of General Dentistry. Her state of the art dental practice includes digital x-rays, paperless patient chart system, and new dental equipments.




WE PROVIDE ALL SERVICES INCLUDING: យើងផ្តល់នូវសេវាដូចខាងក្រោមនេះ

- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS
- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN
- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជុំនួសធ្មេញដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមរន្ធធ្មេញចាស់
- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វើរនីស្រោបធ្មេញ
- ព្យាបាល និងការពារធ្មេញជាទៀងទាត់
- ព្យាបាល ឫសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

Free Teeth Whitening Kit
(with new patient's x-ray, exam, cleaning at regular price)

MOST DENTAL INSURANCES ACCEPTED
INCLUDING MASSHEALTH
FINANCING AVALIABLE
យើងទទួលនូវគ្រប់ អ៊ិន ស៊ូរិន
Masshealth
យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ
CALL FOR YOUR FREE CONSULTATION
(978) 455-5044

# លទ្ធផលការបោះឆ្នោតអភិបាលរដ្ឋម៉ាសាឈូសេតឆ្នាំ២០១៤

**ដកស្រង់ដោយ : ថាច់ វណ្ណា**

អ្នកស្រី ម៉ាថា ខកស៊ី "Martha Coakley" បេក្ខជនឈរឈ្មោះអភិបាលរដ្ឋម៉ាសាឈូសេតបានថ្លែងសេចក្តីអំណរអរគុណដល់អ្នកដែលបានគាំទ្រគាត់នឹងបេក្ខជនដែលបានជាប់ ឆ្នោត ឆាស៊ី បេកើ "Charlie Baker" ដោយទឹកមុខរីករាយក្នុងសេចក្តីថ្លែងការណ៍ដោយយល់ស្របនឹងលទ្ធផលនៃការបោះឆ្នោត កាលពីព្រឹកថ្ងៃទី៥ ខែវិច្ឆិកាកន្លងទៅនេះ ក្នុងការិយាល័យ សមមើវៀវ "Smerbille" មានន័យដូចតទៅ :

អ្នកស្រី ខកស៊ី និយាយថា: "ខ្ញុំមានអារម្មណ៍ហាក់បីដូចជាយើងទាំងពីរនាក់បានជាប់ឆ្នោតយើងទាំងពីរនាក់បានបញ្ចេញនូវលក្ខណ:សំខាន់ៗសំរាប់រដ្ឋម៉ាសាឈូសេត ។

ក្នុងខណ:នោះលោក បេកើ កំពុងនិយាយដោយបន្ទូរអារម្មណ៍ជាមួយអ្នកសន្និសីទកាសែតរាយការណ៍ពីកិច្ចបោះឆ្នោត នឹងគំរោងការណ៍ដល់ក្រុមរបស់គាត់ចូលទទួលតំណែង ។

លោក បេកើ បានថ្លែងថា : ខ្ញុំកំពុងទន្ទឹងរង់ចាំទាំងអស់គ្នា មូដែអាវចូលរួមក្នុងការងារ យើងមានគំរោងពិតប្រាកដ១០០ភាគរយ ដើម្បីដឹកនាំតំណាងរាស្ត្រទាំងអស់ទូទាំងរដ្ឋ ។

លោក បេកើ ក៏បានធ្វើដំណើរទៅជួបជាមួយលោក ផែត្រិក ដើម្បីធ្វើកិច្ចប្រជុំផ្ទេរតំណែង លោក បេកើ បាននិយាយថា : លោក ជីម ភេសើ (Jim Peyser) អតីតនិយកផ្នែកសិក្សាធិការរដ្ឋម៉ាសាឈូសេត និងដឹកនាំក្រុមរបស់គាត់ទៅទទួលមុខតំណែង ។

អ្នកដែលដើរ អមជាមួយអ្នកស្រី ខកស៊ី ដោយលោកអភិបាល ដេវិល ផែត្រិក រដ្ឋសភាអែលីសាបិត (Elizabeth Warren) នឹងអ្នកស្រី អគ្គមេធាវី ម៉ូរ៉ា ហ៊ីលី និយាយលើកទឹកចិត្តឱ្យអ្នកស្រី ខកលី ជួយជ្រោមជ្រែងការងាររាជការជាមួយលោកបេកើ ទោះបីជាពេកកន្លងហើយ មានការប្រជែងគ្នាយ៉ាងក្តៅគគុកនោះក៏ដោយ ។ អ្នកស្រីបានថ្លែងថា : ការមុជ ឬងើបការចេញនិងចូល ហាក់បីដូចជា រឿងនិទានរបស់លោក បណ្ឌិ ស៊ុអើស (Dr.Seuss) ។

ការចាកចេញពីដំណែងអគ្គមេធាវី បានធ្វើឱ្យស្ត្រីម្នាក់កំពុងស្តាប់ផ្ទុះសំណើច អ្នកស្រីនិយាយថា "ជាការសំខាន់គឺអ្នកត្រូវស្តមបន្តិច" រួចអ្នកស្រីយកដៃចង្អុលទៅ **តទៅទំព័រទី ២៤**

# ធនាគារពិភពលោកនិយាយថា កម្ពុជាចាំបាច់ត្រូវពង្រឹងវិស័យទេសចរណ៍ និងកសិកម្ម

**ដោយ : ហួចស៊្ស វិលវ៉ូហ្វ** | October 7, 2014

វិស័យសំណង់បានដែងដាច់វិស័យទេសចរណ៍ និងវិស័យកសិកម្មរហូតក្លាយជាវិស័យធំបំផុតទី២របស់កម្ពុជាដោយវិស័យកាត់ដេរនៅតែជាវិស័យកំពូលដដែលនេះបើយោងតាមរបាយការណ៍មួយចេញផ្សាយកាលពីម្សិលមិញដោយធនាគារពិភពលោកដែលនិយាយថា កម្ពុជាចាំបាច់ត្រូវផ្តល់កញ្ចប់សេវាកម្មទេសចរណ៍បន្ថែមទៀត ជួសជុលផ្លូវថ្នល់ឡើងវិញ បន្ទាបថ្លៃអគ្គិសនី និងបង្កើនការប្រើប្រាស់ម៉ាស៊ីនធ្វើការជំនួសមនុស្សនៅក្នុងអាជីវកម្ម ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ។

របាយការណ៍ពាក់កណ្តាលឆ្នាំនេះលើកឡើងថា វិស័យទេសចរណ៍ និងវិស័យកសិកម្មបានដើរយឺតជាងវិស័យសំណង់នៅក្នុងឆមាសទី១ដើមឆ្នាំនេះ ហើយពេលនេះវិស័យទេសចរណ៍បានក្លាយជាវិស័យធំបំផុតទី៣ ចំណែកឯវិស័យកសិកម្មបានក្លាយជាវិស័យធំបំផុតទី៤ ដែលរួមចំណែកដល់ផលិតផលក្នុងស្រុកសរុប (GDP) របស់ប្រទេស ។

ធនាគារពិភពលោកបានធ្វើការសន្និដ្ឋានថា ការដើរយឺតក្នុងវិស័យទេសចរណ៍គឺដោយសារតែស្ថានភាពចលាចលខាងនយោបាយនៅក្នុងប្រទេសថៃ ចំណែកឯការដើរយឺតនៅក្នុងវិស័យកសិកម្មគឺដោយសារតែការធ្លាក់ចុះតម្លៃទំនិញកសិកម្មនៅទូទាំងពិភពលោក ។

របាយការណ៍ដែលព្យាករពីកំណើន GDP ៧.២ភាគរយនៅក្នុងឆ្នាំ២០១៤៧.៥ភាគរយនៅក្នុងឆ្នាំ២០១៥ និង៧.២ភាគរយនៅក្នុងឆ្នាំ២០១៦នេះ លើកឡើងថា "បញ្ហាប្រឈម គឺត្រូវជំរុញកំណើនកសិកម្ម និងទេសចរណ៍" ។

លោក លី សុដែត សេដ្ឋវិទូប្រចាំប្រទេសនៃធនាគារពិភពលោកបានមានប្រសាសន៍អំឡុងពេលចេញផ្សាយរបាយការណ៍នេះនៅការិយាល័យធនាគារនេះក្នុងរាជធានីភ្នំពេញថា ដើម្បីទទួលបានកំណើនប្រកបដោយនិរន្តភាពនៅក្នុងវិស័យទេសចរណ៍កម្ពុជាចាំបាច់ត្រូវផ្តល់កញ្ចប់សេវាកម្មទេសចរណ៍ចម្រុះបន្ថែមទៀត និងផ្តល់ជម្រើសសម្បូរបែបដល់ទេសចរ ។

លោកបានមានប្រសាសន៍ទៀតថា "យើងចាំបាច់ត្រូវធ្វើឱ្យផលិតផលទេសចរណ៍របស់យើងសម្បូរបែបដើម្បីឱ្យគេមកទស្សនាម្តងហើយម្តងទៀត ។ នេះរួមមានទាំងការបង្កើតទេសចរណ៍

**តទៅទំព័រទី ២៤**




KhmerPost USA, LLC
សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក
អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852
លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092
អ៊ីម៉ែល info@khmerpost.us
អានកាសែតនៅគេហទំព័រ www.khmerpost.us
តាមដានយើងនៅទំព័រហ្វេសប៊ុក Like us at: www.facebook.com/KhmerPostUSA
ផ្សាយពាណិជ្ជកម្ម Advertising
អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*
លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)
អ៊ីម៉ែលsobenpin@khmerpost.us
អ្នកនិពន្ធ Editorials
និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*
(978) 942 - 1641 | rogerpin@khmerpost.us
អ្នកនិពន្ធកិត្តិយស Contributed Writers:
Kim Phien, Richard Howe,Jr.
ច្នៃសោភ័ណភាពកាសែត Design Artist
Heng Chhunleng
នាយករដ្ឋបាល Office Manager 978-677-7163
Thach Vanna ថាច់ វណ្ណា

KhmerPost USA, LLC is an independent newspaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local community, and national news; and give an insight into Cambodian & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Massachusetts serving Greater Lowell, Lynn, Revere, MA, Providence, RI, CT, NY, NJ, and Philadelphia, PA.

Mail subscription is available within the U.S. & Canada at 100.00 or 120 Euros in Europe per year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសំរួលពីកាសែតអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ ពុធ ទី២២ ខែតុលា ឆ្នាំ២០១៤

# គណបក្សសង្គ្រោះជាតិបង្ហាញពីប្រាក់ខែលោក កឹម សុខា អនុប្រធានរដ្ឋសភា

**ដោយ អេឡិក វិល្លឹមមីនស៍** | **NOV 4, 2014**

មន្ត្រីគណបក្សប្រឆាំងម្នាក់បានរិះគន់តបចំពោះការអះអាងរបស់លោក កែម ឡី ស្ថាបនិក "ខ្មែរដើម្បីខ្មែរ" កាលពីសប្តាហ៍មុនដែលថា លោក កឹម សុខា អនុប្រធានគណបក្សសង្គ្រោះជាតិមានប្រាក់ខែ១៥.០០០ដុល្លារក្នុងមួយខែចាប់តាំងពីគណបក្សប្រឆាំងបានចូលសភាកាលពីខែសីហា។

លោក កែម ឡី ដែលបានផ្សព្វផ្សាយក្រុមកំណែទម្រង់ថ្មីរបស់ខ្លួននៅទូទាំងប្រទេសចាប់តាំងពីបង្កើតឡើងកាលពីថ្ងៃទី១៩ខែតុលាមកបានធ្វើការអះអាងនៅក្នុងខេត្តកំពង់ស្ពឺកាលពីថ្ងៃព្រហស្បតិ៍អំឡុងការពិភាក្សាអំពីការមិនមានសកម្មភាពកាលពីពេលថ្មីៗនេះរបស់គណបក្សសង្គ្រោះជាតិជាសាធារណៈ។

ជាការឆ្លើយតបលោក ហ៊ីង សុខសាន្ត ប្រធានក្រុមយុវជនគណបក្សសង្គ្រោះជាតិដែលបានបម្រើការជាអគ្គលេខាធិការរងរដ្ឋសភាចាប់តាំងពីខែសីហាមក កាលពីម្សិលមិញបានបញ្ចេញឯកសារផ្លូវការមួយបញ្ជាក់ពីប្រាក់ខែរបស់លោក កឹម សុខា ក្នុងនាមជាអនុប្រធានរដ្ឋសភា។

យោងតាមឯកសារដែលចុះហត្ថលេខាដោយលោក មិត្ត ការ៉េន អគ្គលេខាធិការរងរដ្ឋសភា កាលពីថ្ងៃទី២២ ខែសីហាឱ្យដឹងថា តាមពិតលោក កឹម សុខា មានប្រាក់ខែ៤.៧៣លានរៀល (ប្រហែល ១.១៨០ដុល្លារ) និងប្រាក់ឧបត្ថម្ភផ្សេងៗសរុបចំនួន៤.៧៦លានរៀល (១.១៩០ដុល្លារ)។

ប្រាក់ឧបត្ថម្ភចំនួន១.១៩០ដុល្លារនេះត្រូវបានបែងចែកទៅលើការប្រើប្រាស់រថយន្តប្រហែល ៥០០ដុល្លារ ហើយ៨៧.៥០ដុល្លារសម្រាប់អ្នកបើករថយន្ត៣៥២.៥០ដុល្លារសម្រាប់ "បេសកកម្ម" ១៥០ដុល្លារសម្រាប់គាំពារសុខភាព និង១០០ដុល្លារសម្រាប់"ជំនួយ"ហើយបូករួមបញ្ចូលគ្នាជាមួយប្រាក់ខែគោលរបស់លោក កឹម សុខា ចំនួន

**តទៅទំព័រទី ២១**

# CNRP Reveals Kem Sokha's Monthly Salary

**BY ALEX WILLEMYNS | NOVEMBER 4, 2014**

An opposition official has hit back at claims made by "Khmer for Khmer" founder Kem Ley last week that CNRP Vice President Kem Sokha has collected a salary of $15,000 per month since the opposition joined parliament in August.

Mr. Ley made the claim on Thursday during a talk about the CNRP's perceived recent inactivity in public.

In response, CNRP Youth President Hing Soksan, who has served as the deputy secretary-general of the National Assembly since August, on Monday released an official document listing Mr. Sokha's salary as the parliament's vice president.

According to the document, Mr. Sokha in fact draws a salary of 4.73 million riel (or about $1,180) and allowances totaling 4.76 million riel ($1,190).

The $1,190 in allowances are divided into about $500 for use of a car, $87.50 for a driver, $352.50 for "missions," $150 for health care, and $100 for "assistance." They boost Mr. Sokha's $1,180 basic salary to a figure of $2,370.

The figure is slightly less than the total $2,384 that National Assembly President Heng Samrin receives. A lawmaker with no committee responsibilities takes home a $975 salary, but allowances (including $500 for gasoline) boost the figure to $2,650.

Mr. Samrin and Mr. Sokha are each given an additional $500 per month for gasoline in addition to their compensation packages, Mr. Soksan said.

Mr. Ley, who maintains he is not planning to turn his "Khmer for Khmer" group into a rival party to the CNRP, said Monday that he stood by his claim. **Continued to page 21**

# នគរបាលអះអាងថា ក្រុមប្រឆាំងរដ្ឋាភិបាលជ្រើសរើសទ័ពផ្ទាល់ខ្លួន

**ដោយ អួន ភាព** | **NOVEMBER 3, 2014**

លោក គៀត ច័ន្ទថារិទ្ធ អ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិបានឱ្យដឹងកាលពីថ្ងៃអាទិត្យថា រណសិរ្សរំដោះជាតិខ្មែរ (KNLF) ជាក្រុមតស៊ូមតិនយោបាយដែលប្រឆាំងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងគណបក្សប្រជាជនកម្ពុជាកំពុងកាន់អំណាចកំពុងហ្វឹកហាត់កងទ័ពសម្ងាត់មានភេរវករប្រដាប់អាវុធរាប់រយនាក់ក្នុងបំណងផ្តួលរំលំរដ្ឋាភិបាល។

ការអធិប្បាយរបស់អ្នកនាំពាក្យរូបនេះអំឡុងសន្និសីទនៅស្នងការដ្ឋាននគរបាលជាតិក្នុងក្រុងភ្នំពេញកាលពីព្រឹកថ្ងៃអាទិត្យធ្វើឡើងបន្ទាប់ពីមានការចាប់ខ្លួនសមាជិករណសិរ្សរំដោះជាតិខ្មែរ ១០នាក់កាលពីខែមុនពីបទញុះញង់ឱ្យមានអំពើហិង្សា។ សេចក្តីថ្លែងការណ៍ប៉ូលិសបានចេញនៅពេលនោះបានឱ្យដឹងថា ក្រុមប្រឆាំងនេះកំពុង" ហ្វឹកហាត់កម្លាំងភេរវករដើម្បីដាក់គ្រឿងផ្ទុះជាសម្ងាត់នៅជិតព្រំដែនថៃ" និង"ផ្តួលរំលំរដ្ឋាភិបាលតាមរយៈការប្រើកម្លាំងប្រដាប់អាវុធខុសច្បាប់នេះ"។

ឧត្តមសេនីយ៍ឯក គៀត ច័ន្ទថារិទ្ធ បានប្រាប់អ្នកយកព័ត៌មានកាលពីថ្ងៃអាទិត្យថា "យើងមានភ័ស្តុតាងឯកសារដែលរឹបអូសបានដើម្បីបញ្ជាក់ថាពួកគេមានកម្លាំងប្រដាប់អាវុធរាប់រយនាក់ ហើយយើងជឿថា ពួកគេកំពុងលាក់ខ្លួនក្នុងប្រទេសនេះ"។

លោកបានមានប្រសាសន៍ទៀតថា ក្នុងចំណោមភ័ស្តុតាងដាក់បន្ទុកលើបុរសទាំង១០នាក់ដែលចាប់ខ្លួនកាលពីថ្ងៃទី២២និង២៣ខែតុលាគឺឯកសារមួយចេញដោយលោក សម សេរី ប្រធានរណសិរ្សរំដោះជាតិខ្មែរ និងស្នាមមេដៃរបស់ជនសង្ស័យដែលប្រកាសពីការបង្កើតកងទ័ពឧទ្ទាម និងក្រសួងការពារជាតិរបស់ខ្លួនផ្ទាល់។

អ្នកនាំពាក្យរូបនេះបានឱ្យដឹងថា "យើងបានសាកសួរជនសង្ស័យទាំងនោះ ហើយពួកគេបានសារភាពថា ពួកគេបានជ្រើសរើសកម្លាំងប្រដាប់អាវុធ ហើយពួកគេក៏បានទទួលការហ្វឹកហ្វឺននៅព្រំដែនខ្មែរ-ថៃដែរ" ហើយបុរសទាំងនោះបានសារភាពថាបានបញ្ចុះបញ្ចូលពលករចំណាកស្រុក ព្រះសង្ឃ និងនិស្សិតដែលសិក្សានៅប្រទេសថៃឱ្យធ្វើជាកម្លាំង។ **តទៅទំព័រទី ២១**

# Police Claim Anti-Gov't Group Raising Own Army

**BY AUN PHEAP | NOVEMBER 3, 2014**

The Khmer National Liberation Front (KNLF), a political advocacy group that opposes Prime Minister Hun Sen and his ruling CPP, is in the process of training a secret army consisting of hundreds of armed terrorists intent on overthrowing the government, national police spokesman Kirth Chantharith said Sunday.

The spokesman's comments during a press conference at the National Police headquarters in Phnom Penh on Sunday morning follow?the arrest of 10 KNLF members last month for plotting to incite violence. A police statement issued at the time said the dissident group was "training terrorist forces to secretly plant explosives near the Thai border" and "topple the government through the use of illegal armed force."

"We have evidence in the form of confiscated lists to prove that they have hundreds of armed forces, and we believe they are hiding in the country," Lt. Gen. Chantharith told reporters Sunday.

He said that among the evidence against the 10 men arrested on October 22 and 23 was a document-issued by KNLF president Sam Serey and thumbprinted by the suspects-announcing the establishment of a rebel army and its own defense ministry.

"We questioned the suspects and they confessed that they recruited armed forces and they also received training at the Cambodian-Thai border," he said, adding the men admitted to enlisting migrant workers, monks and students studying in Thailand.

Lt. Gen. Chantharith said police had also obtained 461 letters proving the KNLF's intention to provoke citizens to rise up against the government, and accused the group of attempting to "change history" by disseminating CDs and books entitled "Uproot January 7," which were critical of the government, King Norodom Sihamoni and the late King Norodom Sihanouk.

He said authorities also had documents to show that the KNLF was born out of the Tiger Head movement, another supposed terrorist organization, and accused both groups of being behind two separate bomb plots in Phnom Penh in 2007 and 2009. Four members of the Tiger Head movement were sentenced to between 20 and 28 years in prison for the 2009 case, in which explosives were found outside the

**Continued to page 21**

ឌី ខេមបូឌា ដេលី The Cambodia Daily

ជំណឹងថ្មៗស៊ីរូលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌី ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ ពុធ ទី២២ ខែតុលា ឆ្នាំ២០១៤

# គណបក្សប្រជាជនកម្ពុជារអាក់រអួលក្នុងការបោះឆ្នោតក្នុងសភា

**ដោយ ហ៊ុល រស្មី | NOVEMBER 4, 2014**

កាលពីថ្ងៃច័ន្ទ អតីតរដ្ឋលេខាធិការក្រសួងយុត្តិធម៌ស៊ឹងតែមិនទទួលបានអាសនៈនៅក្នុងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បន្ទាប់ពីគណបក្សប្រជាជនកម្ពុជាកំពុងកាន់អំណាចមិនមានវត្តមាននៃសមាជិកសភាភាគច្រើននៅសភាជាតិ។

ចៅក្រមចូលនិវត្តន៍ អ៊ិត រ៉ាឌី ជាបេក្ខជនម្នាក់ក្នុងចំណោម៥នាក់ត្រូវឈរឈ្មោះសម្រាប់តំណែងទំនេរនៅក្រុមប្រឹក្សានេះ ដែលមានភារកិច្ចរក្សាឯករាជ្យភាពរបស់តុលាការប្រទេសកម្ពុជា និងធានាឱ្យមានការប្រព្រឹត្តទៅដោយត្រឹមត្រូវរបស់តុលាការនេះ។ ចៅក្រម រ៉ាឌី ជាបេក្ខជនដែលពេញចិត្តរបស់គណបក្សប្រជាជន។

ក្នុងការបោះឆ្នោតនៅឆ្នាំមុន គណបក្សប្រជាជនកម្ពុជាទទួលបាន៦៨អាសនៈ ហើយគណបក្សសង្គ្រោះជាតិទទួលបាន៥៥អាសនៈ។ ទោះជាយ៉ាងនេះក្តីនៅពេលបោះឆ្នោតកាលពីថ្ងៃច័ន្ទ លោក រ៉ាឌី ទទួលបានតែ៦០សំឡេងប៉ុណ្ណោះក្នុងសភាដែលមាន១២៣អាសនៈដោយមួយសំឡេង "បដិសេធ" ៤៤សំឡេងមិនបានការ ហើយសមាជិកសភា១៨រូបអវត្តមាន។

សន្លឹកឆ្នោតមិនបានការចំនួន៤១ជាសន្លឹកឆ្នោតគ្មានគូសអ្វីសោះរបស់សមាជិកគណបក្សសង្គ្រោះជាតិដែលបានតវ៉ាដំណើរការជ្រើសរើសបេក្ខជនទាំង៥រូប ក្នុងដំណើរការនោះពួកគេមិនមានការចូលរួមទេ។

លោក ហេង សំរិន ប្រធានសភាជាតិបានមានប្រសាសន៍ថា "យោងតាមលទ្ធផលបោះឆ្នោតដែលទទួលបាននៅពេលនេះ ខ្ញុំសូមប្រកាសថា អស់លោក គឺបេក្ខជនទាំង៥រូបមិនជាប់ឆ្នោតទេ"។

មួយម៉ោងក្រោយមកសមាជិកសភាបានត្រឡប់មកសភាវិញរួមទាំងសមាជិកសភាគណបក្សប្រជាជនកម្ពុជា៣នាក់ដែលមុននេះបានអវត្តមាន ប៉ុន្តែគ្មានវត្តមានសមាជិកសភាម្នាក់ខាងគណបក្សសង្គ្រោះជាតិដែលបានចាកចេញពីសភា។

នៅទីបញ្ចប់ ក្នុងការបោះឆ្នោតជុំទី២ លោក រ៉ាឌី បានជាប់ឆ្នោតនៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដោយទទួលបាន៦៦សំឡេងគាំទ្រមួយសំឡេងប្រឆាំង និង៤០សំឡេងមិនបានការ។

លោកស្រី មូរ សុខហួរ ប្រធានកិច្ចការសាធារណៈរបស់គណបក្សសង្គ្រោះជាតិបានមានប្រសាសន៍ថា សមាជិកសភា៤១រូបក្នុងចំណោម៥៥រូបរបស់គណបក្សដំបូងឡើយមានវត្តមានក្នុងសភា។ លោក ស៊ុន ឆ័យ ប្រធានក្រុមអ្នកតំណាងគណបក្សសង្គ្រោះជាតិបានមានប្រសាសន៍ថា លោកបានចាកចេញនៅកណ្តាលទី ពីព្រោះលោកជាប់រវល់នឹងកិច្ចការផ្សេងទៀត។

លោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិបានមានប្រសាសន៍ថា គណៈប្រតិភូបក្សប្រឆាំងបានបោះឆ្នោតដោយឥតគូសក្នុងការបោះឆ្នោតទាំង២លើក។ លោកបានមានប្រសាសន៍ថា "យើងមិនបានចូលរួមក្នុងការបង្ហាញវត្តមានណាមួយទេ ពីព្រោះយើងស្ថិតនៅក្រៅដំណើរការតាំងពីចាប់ផ្តើមមកម្ល៉េះ"។

លោក សម រង្ស៊ី បានជួបជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បន្ទាប់ពីការប្រជុំសភា ហើយបានមានប្រសាសន៍ថា ពួកគាត់បានពិភាក្សាគ្នាអំពីការបួរវិធានផ្ទៃក្នុងរបស់សភា ព្រមទាំងគណៈកម្មការបោះឆ្នោតថ្មីផងដែរ ដែលកិច្ចការទាំង២នេះត្រូវបានសន្យាជាផ្នែកមួយនៃកិច្ចព្រមព្រៀងខែកក្កដា ដែលនាំឱ្យគណបក្សសង្គ្រោះជាតិបញ្ចប់ការធ្វើពហិការមិនចូលសភារបស់ខ្លួនរយៈពេល១០ខែ។

ក្រោយពីការចរចាជាច្រើនខែឈានដល់កិច្ចព្រមព្រៀងគណបក្សទាំង២នៅតែខ្វែងគំនិតគ្នាទាក់ទិននឹងគុណវុឌ្ឍិចាំបាច់សម្រាប់អគ្គលេខាធិការនៃគណៈកម្មការរៀបចំការបោះឆ្នោត។

លោក សម រង្ស៊ី មានប្រសាសន៍ថា "ចាប់តាំងពីក្រុមការងាររបស់បក្សទាំង២បានព្យាយាមធ្វើកិច្ចការនេះ ហើយនៅមានការខ្វែងគំនិតគ្នា ដោយអន្លើលោក ហ៊ុន សែន និងខ្ញុំបានព្យាយាមបញ្ចប់ការខ្វែងគំនិតគ្នានេះ"៕

**មានិត(រាយការណ៍បន្ថែមដោយ AlexWillemyns)**

# SNRP: activist be used in a new effort to separate the voice of the opposition

A former Ministry of Justice secretary of state was almost denied a seat on the Supreme Council of Magistracy on Monday after the ruling CPP failed to ensure it had a majority of lawmakers present at the National Assembly.

Retired Judge Ith Rady was one of five candidates up for the vacant position on the council, which is tasked with maintaining the independence of the country's judiciary and ensuring its proper functioning. Judge Rady was the CPP's favored candidate.

Opposition leader Sam Rainsy leads a group of CNRP lawmakers out of the National Assembly on Monday. (Siv Channa/The Cambodia Daily)

In last year's election, the CPP won a majority 68 seats to the CNRP's 55. However, when it came time for the vote Monday, Mr. Rady secured only 60 votes in the 123-seat parliament, with one "nay" ballot registered, 44 invalid votes and 18 lawmakers absent.

Forty-one of the invalid votes were blank ballots cast by CNRP lawmakers, who were protesting the selection process for the five candidates, from which they said they had been excluded.

"According to the result of the election that has come out this moment, I would like to announce that you, the five candidates, were not elected," National Assembly President Heng Samrin said.

An hour later, the parliamentarians returned to the chamber along with three previously absent CPP lawmakers, but without one lawmaker from the CNRP who had left the parliament.

In a second round of voting, Mr. Rady was finally elected to the Supreme Council of the Magistracy with 66 votes in favor, one vote against him and 40 invalid votes.

CNRP public affairs director Mu Sochua **Continued to page23**

said 41 of the party's 55 lawmakers were initially present in the chamber. The opposition's chief whip, Son Chhay, said he left midway through the session because he was busy with other tasks.

CNRP President Sam Rainsy said the opposition party's delegation had submitted blank ballots in both rounds of voting.

"We did not take part in showing any presence because we were actually out of the process since the very beginning," he said.

Mr. Rainsy met with Prime Minister Hun Sen after the session and said they discussed changes to the assembly's internal rules, as well as the new election commission, both of which were promised as part of a July deal that saw the CNRP end its 10-month boycott of parliament.

After months of negotiations to hammer out the details of the agreement, the parties remain split on the qualifications needed for the secretary-general of the National Election Committee.

"Since the working groups of the two parties have been trying to do this and there is still some gap, Hun Sen and I tried to reduce the gap," Mr. Rainsy said.

តមកពីទំព័រទី ១០ ទៅលេងក្រុមគ្រួសារនៅភូមិបាយឆៅ...

មានការផ្លាស់ប្តូរដោយរដ្ឋបាលវៀតណាមគកំពុងលើកដំកើងវប្បធម៌ខ្មែរខ្លាំងណាស់។ ក្មួយលីន អាយុ២០ឆ្នាំនិយាយថា ខ្លួនមិនបានរៀនវែងឆ្ងាយទេ ដោយត្រូវធ្វើការជួយឪពុកម្តាយចិញ្ចឹមគោ១សម្រាប់លក់យកចំណេញនៅឆ្នាំក្រោយសល់ពេលក៏ទៅស៊ីឈ្នួលធ្វើអំពៅ ឬការងារកសិកម្មផ្សេងៗ រីឯប្រពន្ធខ្លួនរៀនចប់សញ្ញាប័ត្រភាសាខ្មែរនឹងក្លាយជាគ្រូបង្រៀនភាសាខ្មែរស្ម័គ្រចិត្តនៅពេលសម្រាលកូនរួច។

ដោយសារបានមកជួបជុំបងប្អូនច្រើនគ្នាប៉ុណ្ណារ៉ូក៏ផ្តើមនិយាយខ្មែរកាន់តែច្រើនរៀងរាល់ថ្ងៃ។

យើងប្រទះឃើញអ្នកស្រុកបាយឆៅសុទ្ធតែខ្មែរទាំងអ្នកស្រែចំការទាំងអ្នកលក់ដូរយើងទៅសាលាឃុំ ឬស្នងការប៉ូលីសឃើញសុទ្ធតែកូនខ្មែរធ្វើការនៅទីនោះ វត្តធំ១៣ ស្ថិតនៅជិតៗគ្នា ១-វត្តពោធិព្រឹក្ស តាកូវ នៅឯកើត ជិតផ្សារ ២-វត្តបាយឆៅ ៣-វត្តជ្រោយទន្សាយ នៅឯលិចបង្អស់។

តាសងដែលជាសមាជិកគណកម្មការវត្តទី ៣-វត្តជ្រោយទន្សាយបាននិយាយថា រដ្ឋបាលវៀតណាមបានកត់ត្រាវត្តខ្មែរចំនួន១៤៤ សម្រាប់ខេត្តត្រាវិញតែមួយចាត់ឱ្យមានតំណាងមកពីគ្រប់វត្តរៀបចំលើកកំពស់វប្បធម៌ខ្មែរមានទាំងអក្សរសាស្ត្រ របាំ ភ្លេង នឹងចម្រៀងមានទាំងកសាងវត្តខ្មែរមួយនៅកោះត្រល់ទៀតផង។

ខេត្តនៃវៀតណាមដែលសម្បូរខ្មែររស់នៅមានស្រុកត្រាំង នៅខាងជើង ខេត្តព្រះលាវ ឬបាក់លីវ នៅខាងលិចឈៀងខាងត្បូងខេត្តទឹកខ្មៅ ខេត្តក្រមួនសរ ខេត្តឃ្លាំង ។ល។ ខេត្តទាំងនោះ ស្ថិតនៅភាគខាងត្បូងដែលរដ្ឋបាលវៀតណាមចូលចិត្តឱ្យហៅពលរដ្ឋខ្មែរថា ជាខ្មែរភាគខាងត្បូងជាងពាក្យខ្មែរកម្ពុជាក្រោម៕

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងថ្មីៗសម្រួលពីកាសែតអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ អង្គារ ទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៤

# គណៈកម្មការហិរញ្ញវត្ថុនៃរដ្ឋសភាស្នើសុំព័ត៌មានលម្អិតបន្ថែមស្តីពីថវិកាជាតិ

**ដោយ អេឡិក វិល្លៀមមីនស៍ AND h'ul rsµI | NOVEMBER 11, 2014**

គណៈកម្មការធនាគារ និងហិរញ្ញវត្ថុនៃរដ្ឋសភាបានជួបប្រជុំកាលពីម្សិលមិញ ដើម្បីពិភាក្សាអំពីសំណើថវិកាជាតិ៣ប្រាំបីពាន់លានដុល្លារសម្រាប់ឆ្នាំ២០១៥ ដោយក្រុមតំណាងរាស្ត្រមកពីគណបក្សទាំងពីរបានយល់ស្របគ្នាថា ចាំបាច់ត្រូវមានព័ត៌មានលម្អិតជាក់លាក់បន្ថែមទៀតមុនពេលពួកគេអាចវាយតម្លៃគម្រោងនេះបាន នេះបើយោងតាមការលើកឡើងរបស់លោក សុន ឆ័យ អនុប្រធានគណៈកម្មការនេះ។

លោក សុន ឆ័យ តំណាងរាស្ត្រជាន់ខ្ពស់មួយរូបរបស់គណបក្សសង្គ្រោះជាតិបានមានប្រសាសន៍ថា តំណាងរាស្ត្របួនរូបមកពីគណបក្សរបស់លោកដែលស្ថិតនៅក្នុងគណៈកម្មការនេះ ព្រមទាំងតំណាងរាស្ត្រប្រាំរូបមកពីគណបក្សប្រជាជនកម្ពុជាកំពុងកាន់អំណាចផង បានគ្រោងជំនួបមួយជាមួយលោក អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅចុងខែនេះ។

លោកបានមានប្រសាសន៍ទៀតថា "យើងមិនអាចប្រាប់អស់លោកគ្រប់យ៉ាងបានទេ នោះជាសំណើរបស់ប្រធាន ។ ប៉ុន្តែខ្ញុំអាចនិយាយបានថា យើងបានពិនិត្យមើលសេចក្តីព្រាង ហើយបានឃើញបញ្ហាមួយចំនួនដែលយើងនឹងលើកឡើងនៅពេលយើងជួបជាមួយរដ្ឋមន្ត្រីដូចដែលយើងបានគ្រោងទុកនៅថ្ងៃទី២៤ ខែវិច្ឆិកា។ យើងទាំងអស់គ្នាហាក់ដូចជាបានព្រមព្រៀងគ្នាថា យើងត្រូវការឯកសារបន្ថែមទៀតដើម្បីឱ្យយើងមានទិន្នន័យសម្រាប់លើកឡើងឱ្យបញ្ហានានា ជាមួយរដ្ឋាភិបាលរួមទាំងស្តីពីចំណូលព្រមទាំងការចំណាយផងដែរ"។

កាលពីចុងខែមុន រដ្ឋាភិបាលរបស់គណបក្សប្រជាជនកម្ពុជាបានបញ្ចេញសំណើដ៏ធំរបស់ខ្លួនសម្រាប់ការចំណាយ និងចំណូលសម្រាប់ក្រសួងនីមួយៗ ប៉ុន្តែគណបក្សសង្គ្រោះជាតិបានស្នើសុំព័ត៌មានលម្អិតបន្ថែមដែលធ្វើឱ្យអ្នកនៅក្រៅរដ្ឋាភិបាលអាចវាយតម្លៃអំពីថវិកាឱ្យបានល្អប្រសើរ។

លោក ជាម យៀប ប្រធានគណៈកម្មការធនាគារ និងហិរញ្ញវត្ថុនៃរដ្ឋសភាមិនអាចទាក់ទងសុំការបំភ្លឺបានទេ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ លោក ជាម យៀប បានធ្វើជាអ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា ប៉ុន្តែលោក ប៊ុល ឡាគីម ជំនួយការផ្ទាល់របស់លោកបានមានប្រសាសន៍កាលពីរសៀលម្សិលមិញថា តំណាងរាស្ត្រដែលកាន់តំណែងយូររូបនេះមិនទំនេរនិយាយជាមួយប្រព័ន្ធផ្សព្វផ្សាយទេ។

លោក ផៃ ស៊ីផាន អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រីបានមានប្រសាសន៍ថា លោកមិនដឹងច្បាស់ថា រដ្ឋាភិបាលនឹងយកចិត្តទុកដាក់ចំពោះសំណើរបស់លោក សុន ឆ័យ ដែលសុំឱ្យបញ្ចេញព័ត៌មានលម្អិតបន្ថែមទៀតអំពីសេចក្តីព្រាងថវិកា៣ប្រាំបីពាន់លានដុល្លារ ឬយ៉ាងណានោះទេ មុនពេលបញ្ជូនទៅរដ្ឋសភា។

លោកបានមានប្រសាសន៍ទៀតថា "ខ្ញុំមិនដឹងទេ។ ខ្ញុំគិតថា លោក សុន ឆ័យ មានសិទ្ធិស្នើសុំព័ត៌មានបន្ថែមស្តីពីបញ្ហានោះ។ គាត់មានសិទ្ធិសាកសួរពីបញ្ហានោះទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬគាត់អាចរង់ចាំបានរហូតដល់សម័យប្រជុំពេញអង្គដើម្បីចោទសួរអំពីវា"។

កាលពីសប្តាហ៍មុន លោក សុន ឆ័យ បានផ្ញើលិខិតមួយច្បាប់បែបនេះទៅលោក អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីស្នើសុំព័ត៌មានលម្អិតបន្ថែមស្តីពីថវិកាជាតិ។ ប៉ុន្តែ លោក សុន ឆ័យ បានមានប្រសាសន៍កាលពីថ្ងៃអាទិត្យថា លិខិតនោះត្រូវបានបញ្ជូនត្រឡប់មកលោកវិញដោយគ្មានការឆ្លើយតបពីព្រោះលោកបានបញ្ជាក់នៅក្នុងលិខិតនោះថា លោកជាអនុប្រធាននៃគណៈកម្មការសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយគ្មានការអនុម័តពីលោក ជាម យៀប ។

លោក ហែល ចំរើន អគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបដិសេធមិនធ្វើការអត្ថាធិប្បាយទេកាលពីល្ងាចម្សិលមិញជុំវិញថា តើក្រសួងរបស់លោកនឹងបញ្ចេញព័ត៌មានលម្អិតបន្ថែមទៀតស្តីពីថវិកាជាតិនៅក្នុងរយៈពេលប៉ុន្មានសប្តាហ៍ខាងមុខនេះ។

លោកបានមានប្រសាសន៍ថា "ពេលនេះអ្វីៗកំពុងស្ថិតក្នុងដៃរដ្ឋសភា ដូច្នេះមិនទាន់មានព័ត៌មានចេញផ្សាយជាសាធារណៈនៅឡើយទេ ពីព្រោះវាស្ថិតក្នុងដំណាក់កាលពិភាក្សា។ លោកបានលើកឡើងបន្ថែមទៀតថា សិក្ខាសាលាមួយនឹងត្រូវរៀបចំឡើងនៅរដ្ឋសភានៅថ្ងៃអង្គារសប្តាហ៍ក្រោយ និងបើកទូលាយឱ្យសាធារណជនបានដឹង និងផ្តល់ព័ត៌មានលម្អិតបន្ថែមទៀតអំពីថវិកា។

គណបក្សប្រជាជនកម្ពុជាមានសំឡេងភាគច្រើននៅក្នុងរដ្ឋសភាដោយមាន៦៨អាសនៈក្នុងចំណោមអាសនៈទាំង១២៣នៃរដ្ឋសភា ហើយនឹងអាចអនុម័តថវិកាឆ្នាំ២០១៥ដោយគ្មានការតវ៉ា។ លោក សុន ឆ័យ បានមានប្រសាសន៍ថា វាជាស្តង់ដារ ដែលគម្រោងថវិកាត្រូវអនុម័តដោយរដ្ឋសភាមិនលើសពីសប្តាហ៍ទី៣នៃខែធ្នូ ៕

**សុខុម**

# Assembly's Finance Commission Requests More Details on Budget

**BY ALEX WILLEMYNS AND HUL REAKSMEY | NOVEMBER 11, 2014**

The National Assembly's banking and finance commission met Monday to discuss the proposed $3.8-billion budget for 2015, with lawmakers from both parliamentary parties agreeing that more specific details are needed before they can evaluate the plan, according to the commission's deputy chairman, Son Chhay.

Mr. Chhay, a senior lawmaker for the opposition CNRP, said the four lawmakers from his party on the committee, as well as the five from the ruling CPP, had scheduled a meeting with Finance Minister Aun Porn Moniroth for later this month.

"We cannot tell you everything; that was a request by the chair. But I can say we looked into the draft and found quite a number of issues that we will raise when we meet with the minster as we plan on the 24th of November," Mr. Chhay said.

"There was one common ground that we all seemed to agree on: that we need more documents to allow us to have the data to raise [issues] with the government, including on the revenue as well as the expenditure," he said.

The CPP government late last month released its broad proposals for spending and revenue across each ministry, but the CNRP has been pushing for more detailed breakdowns that would allow those outside the government to better evaluate the budget.

The CPP's Cheam Yeap, chairman of the finance commission, could not be reached for comment. Mr. Yeap has in recent years served as a de facto CPP spokesman, but his personal assistant Bul Lakim said Monday afternoon that the long-serving lawmaker was no longer available to media.

Council of Ministers spokes- man Phay Siphan said he was unsure whether the government would heed Mr. Chhay's request to release more comprehensive details about the $3.8 billion draft budget before it is sent to the National Assembly.

"Well, I have no idea. I think Son Chhay has a mandate to request more details on that," Mr. Siphan said. "He has the right to ask that to the Ministry of Finance and Economics or he can wait until a plenary session to ask a question on it."

Mr. Chhay last week sent such a letter to Mr. Porn Moniroth, the finance minister, to request details about the budget. But Mr. Chhay said on Sunday that it was returned to him without any response because he had identified himself in the letter as the finance committee's deputy chairman without getting Mr. Yeap's approval.

Finance Ministry secretary-general Hel Chamroeun declined to comment Monday on whether his ministry would release significantly more details about the budget in the coming weeks.

"Everything is now in the hands of parliament, so no information has been released publicly yet as it's at the discussion stage," Mr. Chamroeun said. He added, however, that a seminar to be held at the National Assembly next Tuesday would be open to the public and provide some more details about the budget.

The CPP holds a majority in parliament, with 68 of the 123 National Assembly seats, and will be able to pass the 2015 budget without contest. Mr. Chhay said it was standard that a proposed budget is passed by the National Assembly no later than the third week of December.

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ជំនាន់ថ្មីប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ អង្គារ ទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៤

# មន្ត្រីគណបក្សសង្គ្រោះជាតិមួយរូបទៀតត្រូវចាប់ខ្លួន ជុំវិញករណីផ្ទុះអំពើហិង្សាកាលពីខែកក្កដា

**ដោយ គុច ណារ៉េន** | **NOVEMBER 12, 2014**

មន្ត្រីសំខាន់មួយរូបរបស់គណបក្សសង្គ្រោះជាតិដែលត្រូវតុលាការចេញដីកាឱ្យចូលបំភ្លឺជុំវិញការពាក់ព័ន្ធរបស់លោកនៅក្នុងហេតុការណ៍ប៉ះទង្គិចគ្នាមួយកាលពីថ្ងៃទី១៥ ខែកក្កដា នៅទីលានប្រជាធិបតេយ្យនោះ ត្រូវបានចាប់ខ្លួន ខណៈកំពុងបើកបរនៅក្នុងរាជធានីភ្នំពេញ ហើយត្រូវបានបញ្ជូនខ្លួនទៅពន្ធនាគារកាលពីម្សិលមិញនេះ បើយោងតាមការលើកឡើងរបស់មន្ត្រីនគរបាល និងមេធាវីរបស់លោក។

លោក មៀច សុវណ្ណារ៉ា ដែលបានឈរឈ្មោះជាបេក្ខភាពតំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័យតំណាងឱ្យគណបក្សសង្គ្រោះជាតិនៅក្នុងការបោះឆ្នោតជាតិកាលពីខែកក្កដា ឆ្នាំ២០១៣ ត្រូវបានចាប់ខ្លួន ខណៈកំពុងអង្គុយនៅកៅអីក្រោយនៃរថយន្តរបស់លោកបន្ទាប់ពីនគរបាលបានឃាត់រថយន្តលោកនៅតាមបណ្តោយមហាវិថីព្រះនរោត្តម ក្នុងរាជធានីភ្នំពេញជិតធនាគារជាតិ។

រូបភាពវីដេអូបានបង្ហាញពីសកម្មភាពមន្ត្រីនគរបាលស្លៀកពាក់ឯកសណ្ឋានមួយរូបអានដីកាចាប់ខ្លួនឱ្យលោក មៀច សុវណ្ណារ៉ា ដែលជាអតីតអ្នកកាសែតវិទ្យុអាស៊ីសេរីស្តាប់មុនពេលលោក មៀច សុវណ្ណារ៉ា ដើរទៅកាន់រថយន្តនគរបាលមួយគ្រឿងដែលនៅក្បែរនោះដោយយកដៃរបស់លោកក្បៀកស្មាមន្ត្រីនគរបាលស្លៀកពាក់ស៊ីវិលម្នាក់។

លោក ជួន ណារិន ស្នងការរងរាជធានីភ្នំពេញបានមានប្រសាសន៍ថា នគរបាលបានអនុវត្តការចាប់ខ្លួននេះតាមដីការបស់សាលាដំបូងរាជធានី។ លោកបានមានប្រសាសន៍ទៀតថា "យើងអនុវត្តដីកាតុលាការដើម្បីនាំខ្លួនគាត់ទៅតុលាការ"។

លោក ចាន់ ចិន មេធាវីរបស់លោក មៀច សុវណ្ណារ៉ា បានមានប្រសាសន៍ថា នៅក្នុងតុលាការ ចៅក្រមស៊ើបសួរ កែវ មុនី បានបង្គាប់ឱ្យឃុំខ្លួនកូនក្តីរបស់លោក ហើយបានបដិសេធសំណើសុំនៅក្រៅឃុំរង់ចាំសវនាការជំនុំជម្រះពីបទចោទប្រកាន់ជាច្រើនករណីប្រឆាំងរូបលោកពាក់ព័ន្ធនឹងករណីផ្ទុះអំពើហិង្សាកាលពីខែកក្កដា។

មេធាវីរូបនេះបានមានប្រសាសន៍ថា "បន្ទាប់ពីសាកសួរចប់សព្វគ្រប់ ចៅក្រមស៊ើបសួរបានសម្រេចឃុំខ្លួនកូនក្តីរបស់ខ្ញុំនៅពន្ធនាគារព្រៃស ពីព្រោះកូនក្តីរបស់ខ្ញុំត្រូវបានចោទប្រកាន់ពីបទចូលរួមនៅក្នុងការប៉ះបោរបទបង្កអំពើហិង្សា ដោយចេតនា និងបទប្រើកម្លាំងតតាំងប្រឆាំងមន្ត្រីសាធារណៈ"។



លោកបានមានប្រសាសន៍បន្តទៀតថា "ខណៈពេលសាកសួរ កូនក្តីរបស់ខ្ញុំបានច្រានចោលការចោទប្រកាន់របស់ព្រះរាជអាជ្ញា ពីព្រោះរូបភាព និងវីដេអូទាំងអស់ឱ្យនៃការតវ៉ានោះបង្ហាញថា កូនក្តីរបស់ខ្ញុំមិនពាក់ព័ន្ធនឹងការប៉ះបោរនោះទេ។ ភស្តុតាងបង្ហាញថា កូនក្តីរបស់ខ្ញុំបានប្រាប់ប្រជាពលរដ្ឋឱ្យស្រឡាញ់លទ្ធិប្រជាធិបតេយ្យ ហើយប្រាប់ថា ពួកគាត់គួរតែកុំប្រើអំពើហិង្សា ដូច្នេះនោះមិនមែនជាការញុះញង់ឱ្យធ្វើការប៉ះបោរឡើយ"។

ចៅក្រម កែវ មុនី បានបដិសេធមិនឆ្លើយបំភ្លឺទេជុំវិញរឿងក្តីលោក មៀច សុវណ្ណារ៉ា នៅពេលទាក់ទងតាមទូរស័ព្ទកាលពីរសៀលម្សិលមិញ។

បទចោទប្រកាន់ទាំងនេះលើលោក មៀច សុវណ្ណារ៉ា ត្រូវបានធ្វើឡើងដោយសាលាដំបូងរាជធានីកាលពីខែកក្កដា។ លោកប្រឈមការជាប់ពន្ធនាគារពី៧ឆ្នាំទៅ១៥ឆ្នាំ ប្រសិនបើតុលាការរកឃើញថា លោកមានពិរុទ្ធភាពពីបទចូលរួមក្នុងការប៉ះបោរមែននោះ។

បទចោទប្រកាន់ទាំងនេះបានកើតមានឡើងខណៈពេលតំណាងរាស្ត្រជាប់ឆ្នោតប្រាំពីររូបរបស់គណបក្សសង្គ្រោះជាតិត្រូវបានឃុំខ្លួនជុំវិញបទ

**តទៅទំព័រទី ២៩**

# Yet Another CNRP Official Arrested Over July Violence

**BY KUCH NAREN | NOVEMBER 12, 2014**

A prominent opposition CNRP official with an outstanding court warrant for his alleged role in a July 15 clash at Freedom Park was arrested while driving in Phnom Penh and sent to prison Tuesday, police officials and his lawyer said.

Meach Sovannara, who ran as a CNRP candidate for Banteay Meanchey province in the July 2013 national election, was arrested while in the back seat of his car after police stopped it along Phnom Penh's Norodom Boulevard near the National Bank.

Video footage shows Mr. Sovannara, a former Radio Free Asia journalist, having his arrest warrant read to him by a uniformed police officer before walking to a nearby unmarked police pickup truck with his arm around the shoulder of a plain-clothed officer.

Phnom Penh deputy municipal police chief Chuon Narin said police executed the arrest in line with a warrant released by the municipal court. "We implemented the court warrant to bring him to court," he said.

Mr. Sovannara's lawyer, Chan Chen, said Investigating Judge Keo Mony, in court, ordered his client imprisoned and denied him bail pending a trial for a slew of charges handed down against him in July.

"After finishing the questioning completely, the investigating judge decided to detain my client at Prey Sar prison as my client has been charged with participating in an insurrection, intentional violence and the act of opposing public officials with violent resistance," Mr. Chen said.

"While being questioned, my client denied the charges laid by the prosecutor because all images and video [of the protest] prove my client was not involved in an insurrection," he added.

"The evidence shows that my client was telling people to love democracy and that they should act non-violently, so that is not incitement to hold an insurrection."

Judge Mony declined to comment on Mr. Sovannara's case when reached by telephone Tuesday afternoon.

The charges against Mr. Sovannara were handed down by the Phnom Penh Municipal Court in July. He faces 7 to 15 years in prison if found guilty of taking part in an insurrection.

The charges came as seven CNRP lawmakers-elect were imprisoned over similar charges of "leading an insurrection" after protesters fought back against the notorious Daun Penh district security guards, who had for months brutally beat protesters trying to go near Freedom Park.

At least two of the district security guards were severely injured, with some briefly admitted into intensive care at hospital.

CNRP President Sam Rainsy declined to comment on Mr. Sovannara's arrest Tuesday and referred questions to party spokesman Yim Sovann. Mr. Sovann said that the opposition was concerned the arrest had been made to pressure it to yield in the stalled election-reform talks.

"Of course, yes, it's a concern. But we would like to appeal to the CPP not to create **Continued to Page 29**





# កោះតូច រមណីយដ្ឋានថ្មី ទឹកដីសមុទ្រ

ពីមុនកោះតូចធំដែលមានទីតាំងក្នុងដែនសមុទ្រខ្មែរភាគច្រើនជាលំនៅដ្ឋានសម្រាប់អ្នកនេសាទ និងជាបន្ទាយកងទ័ពជើងទឹក ប៉ុន្តែខណៈដែលមានភូមិមានសុខសន្តិភាព និងមានការអភិវឌ្ឍន៍នោះ កោះជាច្រើនត្រូវបានកែច្នៃជាតំបន់ទេសចរណ៍។ ដោយឡែកកោះតូច នៅខេត្តព្រះសីហនុកំពុងក្លាយជារមណីយដ្ឋានគួរឱ្យចាប់អារម្មណ៍ដោយសារទីនេះ មានឆ្នេរខ្សាច់ និងទិដ្ឋភាពដ៏ស្រស់បំព្រងពេលបានទៅទស្សនាមិនចង់ឃ្លាត...។



កោះតូច គឺជាភូមិ១ ក្នុងចំណោមភូមិទាំង៥ របស់សង្កាត់កោះរុង ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានផ្ទៃដីទំហំ១៨គីឡូម៉ែត្រក្រឡា ដោយមានប្រជាពលរដ្ឋរស់នៅចំនួន៩២គ្រួសារ ស្មើនឹង៣៨២នាក់។ កោះតូចមានចម្ងាយជាង ៣០គ.មពីដែនដីគោកភាគខាងលិចក្រុងព្រះសីហនុ គេអាចធ្វើដំណើរទៅដល់តាមរយៈទូកយន្តឆ្លងកាត់លម្ហសាគរ មើលដាច់កន្ទុយភ្នែក។

លោកសេង ហ៊ូលាង ចៅសង្កាត់រង សង្កាត់កោះរុង និងជាអតីតប្រធានភូមិកោះតូចបានឱ្យដឹងថា កោះតូចមានខ្យល់អាកាសបរិសុទ្ធ មានព្រៃព្រឹក្សា ខៀវស្រងាត់ ឆ្នេរខ្សាច់សក្បុស ផ្កាថ្មស្មៅបាតសមុទ្រ និងមច្ឆាជាតិគ្រប់ប្រភេទសម្រាប់ទាក់ទាញអ្នកទេសចរ។ ក្នុងចំណោមអ្នកកោះទាំងអស់មាន៣០ភាគរយប្រកបរបរនេសាទត្រីសមុទ្រ និង៧០ភាគរយទៀត ប្រកបរបរបើកកាណូតដឹកអ្នកទេសចរនិងរកស៊ី លក់ដូរនៅតាមឆ្នេរ។ ពីមុនកោះដ៏តូចនេះ គឺជាភូមិអ្នកនេសាទដោយមានប្រជានេសាទដល់ទៅ៧០ភាគរយឯណោះ ប៉ុន្តែនៅពេលនេះ ពួកគាត់បានប្តូរមុខរបរដោយយោងទៅតាមការអភិវឌ្ឍន៍របស់មាតុភូមិ។ កោះនេះមានមនុស្សរស់នៅតិចតួចណាស់កាលពីសម័យសង្គមរាស្ត្រនិយម លុះឆ្លងដល់របប ប៉ុល ពត គ្មានមនុស្សរស់នៅទេ ប៉ុន្តែក្រោយឆ្នាំ១៩៧៩ ទើបមានកងទ័ពជើងទឹកការពារដែនសមុទ្រទៅបោះទីតាំងឈរជើងដោយពុំទាន់អនុញ្ញាតឱ្យពលរដ្ឋសាមញ្ញទៅនៅទេ សូម្បីតែទូកនេសាទក៏មិនឱ្យចូលចតដែរ។ រហូតដល់ឆ្នាំ១៩៩៣ ទើបបើកសិទ្ធិឱ្យប្រជាពលរដ្ឋទៅតាំងលំនៅដ្ឋានដែលមុនដំបូងមានតែ៧គ្រួសារប៉ុណ្ណោះ ប្រកបរបរនេសាទត្រី លុះយូរៗទៅក៏មានអ្នកទៅរស់នៅច្រើនឡើងក្លាយទៅជាភូមិមួយចំណុះឱ្យសង្កាត់កោះរុង ក្រុងព្រះសីហនុ។

លោក សេង ហ៊ូលាង ឱ្យដឹងទៀតថា លុះមកដល់ឆ្នាំ២០០៨ ក៏មានជនបរទេសមួយចំនួនបាននាំគ្នាជិះទូកទៅកម្សាន្តនៅកោះនេះ ក៏ជាប់ចិត្តជិតអារម្មណ៍និយាយប្រាប់តៗគ្នា។ មិនយូរប៉ុន្មានក៏មានជនបរទេស២នាក់បានមកបើកផ្ទះសំណាក់លើទឹកដែលអ្នកភូមិនិយមហៅថា "ប៊ឹងកាឡូ" ៩ សម្រាប់ភ្ញៀវជាតិ និងអន្តរជាតិទៅសម្រាកកាយ ។ សព្វថ្ងៃមានជនបរទេសកើនឡើងដល់ ១១នាក់ បានមកធ្វើអាជីវកម្មបើកប៊ឹងកាឡូចំនួន៥ និងកំពុងសាងសង់បន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ភ្ញៀវទេសចរដែលកើនឡើងពី១ថ្ងៃទៅ១ថ្ងៃ។ ជាទូទៅក្នុង១ថ្ងៃកោះតូចបានទទួលភ្ញៀវទេសចរបរទេសចាប់ពី ៥០ទៅ៧០នាក់ ដែលជិះទូកយន្តពីដែនដីគោក ឬដេកសំងិលហាលថ្ងៃលើឆ្នេរខ្សាច់ ខ្លះក៏ស្ទូចត្រីលេងតាមចំណង់ចំណូលចិត្ត។

លោក អឿ វិបុល ប្រធានការិយាល័យអេកូទេសចរណ៍នៃមន្ទីរទេសចរណ៍ខេត្តព្រះសីហនុបានឱ្យដឹងថា សព្វថ្ងៃកោះតូច និងឆ្នេរខ្សាច់សុខសាន្ត ស្ថិតនៅក្នុងតំបន់ទេសចរណ៍កោះរុង កំពុងស្ថិតនៅក្នុងគម្រោងដាក់បញ្ចូលជាតំបន់ទេសចរណ៍ដ៏មានសក្តានុពលទៅអនាគតសម្រាប់ខេត្តព្រះសីហនុ។ ក្រៅពីនេះខេត្តព្រះសីហនុ ក៏នៅមានតំបន់ទេសចរណ៍សំខាន់ៗ ជាច្រើនកន្លែងទៀតដូចជា ឆ្នេរអូរត្រេះ ឆ្នេរចាំស្នេហ៍ នៅស្រុកព្រៃនប់ អន្ទង់ស កែវផុស ស្ទឹងហាវ ឆ្នេរអូរឈើទាល ទឹកធ្លាក់ក្បាលឆាយ ថ្មរូង និងកោះឫស្សីជាដើម។ លោកប្រធានការិយាល័យឱ្យដឹងទៀតថា ចំនួនភ្ញៀវទេសចរបរទេសដែលចូលមកកម្សាន្តនៅខេត្តព្រះសីហនុមានការកើនឡើងជាលំដាប់ដែលភាគច្រើនបានជិះទូកយន្តទៅកម្សាន្តដល់កោះកណ្តាលសមុទ្រឯណោះ ជាពិសេសកោះតូច កំពុងត្រូវប៉ាន់ណាស់។ គេអាចទាក់ទងមកមន្ទីរទេសចរណ៍មុននឹងចេញដំណើរកម្សាន្តនៅដែនកោះ ដើម្បីចៀសវាងការរាំងស្ទះលើមធ្យោបាយដឹកជញ្ជូន។

លោក សរុបថា មកដល់ពាក់កណ្តាលឆ្នាំ ២០១៣នេះភ្ញៀវបរទេសបានកើនឡើងចំនួន ៤១.៦៨ភាគរយ ដោយសង្ឃឹមថា នឹងកើនឡើងជាងនេះទៀត ដោយសារតំបន់ទេសចរណ៍សំខាន់ៗ ដូចជារមណីយដ្ឋាន កោះតូចជាដើមមានសេវាកម្មល្អប្រសើរ។ **តទៅទំព័រទី ២៥**





## Police Claim Anti-Gov't Group ...

**Continued from page 16**

Council of Ministers building and TV3 station.

Lt. Gen. Chantharith said police were still attempting to root out KNLF members in the country. "We are still targeting people and… searching to make arrests," he said.

Contacted on Friday, Mr. Serey -who has denied earlier police accusations that he was a member of the Tiger Head movement but admitted to once being close friends with its leader, Som Ek-said he was not involved in the 2009 bomb plot, which he said had been fabricated by the government.

"I would like to reject…that I am behind the bomb plot in 2009. I have never used any violence," Mr. Serey said by email from Denmark, where he has been living in self-imposed exile to avoid arrest by Cambodian authorities.

"I think this is a plot of government to make a story to arrest me so the government themselves who put a bomb in order to blame on KNLF and arrest us," he said.

Thirteen KNLF members were sentenced to between five and nine years in prison in April for plotting to overthrow the government in what was widely seen as a politically motivated verdict based on scant evidence.

## CNRP Reveals Kem Sokha's...

**Continued from page 16**

He said Mr. Sokha's office was entitled to further benefits that total $15,000.

"That calculation is correct," he said. "For the [deputy president or the president] of the National Assembly, they have at least one driver and I don't know how many bodyguards.

"When we talk to the general public we have no time to declare what is the net salary and what are the packages for each parliamentarian," he said. "I agree the net salary for each is small but if you calculate the package, it's enormous."

Mr. Soksan said the document he published covered the entirety of benefits afforded to Mr. Sokha by the assembly.

"What Kem Ley said is completely wrong. What I published is an official document," Mr. Soksan said.

"His bodyguards are his personal expense, and there is no salary from the National Assembly. If he says like that, he should have documents and proof."

## តមកពីទំព័រទី ១៦ នគរបាលអះអាងថា ក្រុមប្រឆាំង...

ឧត្តមសេនីយ៍ឯក គៀត ច័ន្ទថារិទ្ធ បានមានប្រសាសន៍ថា ប៉ូលិសក៏បានទទួលលិខិត៤៦១ច្បាប់ដែលបញ្ជាក់ពីគោលបំណងរបស់រណសិរ្សរំដោះជាតិខ្មែរញុះញង់ឱ្យពលរដ្ឋងើបឡើងប្រឆាំងរដ្ឋាភិបាល និងបានចោទក្រុមនេះពីបទព្យាយាម "កែប្រែប្រវត្តិសាស្ត្រ" ដោយការចែកចាយស៊ីឌី និងសៀវភៅមានចំណងជើងថា "រំលើងឫសគល់៧មករា" ដែលរិះគន់រដ្ឋាភិបាលព្រះមហាក្សត្រនរោត្តម សីហមុនី និងព្រះរតនកោដ្ឋនរោត្តម សីហនុ។

លោកបានឱ្យដឹងទៀតថា អាជ្ញាធរក៏មានឯកសារបញ្ជាក់ថា រណសិរ្សរំដោះជាតិខ្មែរនេះ គឺកើតចេញពីចលនាក្បាលខ្លាជាអង្គការភេរវកម្មមួយផ្សេងទៀត ហើយបានចោទក្រុមទាំងពីរថា នៅពីក្រោយផែនការដាក់គ្រាប់បែក២លើកដោយឡែកពីគ្នាក្នុងក្រុងភ្នំពេញកាលពីឆ្នាំ២០០៧ និង២០០៩។ សមាជិក៤នាក់របស់ចលនាក្បាលខ្លាត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពី២០ឆ្នាំដល់២៨ឆ្នាំចំពោះករណីនៅឆ្នាំ២០០៩ ដែលក្នុងហេតុការណ៍នោះ គេបានរកឃើញគ្រឿងផ្ទុះនៅខាងក្រៅអគារទីស្តីការគណៈរដ្ឋមន្ត្រី និងស្ថានីយទូរទស្សន៍ប៉ុស្តិ៍លេខ៣។

ឧត្តមសេនីយ៍ឯក គៀត ច័ន្ទថារិទ្ធ បានឱ្យដឹងថា ប៉ូលិសកំពុងព្យាយាមស្វែងរក និងបោសសម្អាតសមាជិករណសិរ្សរំដោះជាតិខ្មែរក្នុងប្រទេសកម្ពុជា។ លោកបានបន្ថែមថា "យើងកំពុងផ្តោតលើពួកគេ និងស្វែងរកចាប់ខ្លួនពួកគេនៅឡើយ"។

នៅពេលទាក់ទងកាលពីថ្ងៃសុក្រ លោក សេរី ដែលបានបដិសេធការចោទប្រកាន់មុននេះដោយប៉ូលិសដែលថា លោកជាសមាជិកនៃចលនាក្បាលខ្លា ប៉ុន្តែបានទទួលស្គាល់ថា ខ្លួនធ្លាប់ជាមិត្តភក្តិជិតស្និទ្ធជាមួយមេដឹកនាំក្រុមនេះ គឺលោក សម ឯក នោះ បាននិយាយថា លោកមិនបានពាក់ព័ន្ធក្នុងការដាក់គ្រាប់បែកនៅឆ្នាំ២០០៩ ដែលលោកនិយាយថា ត្រូវបានរដ្ឋាភិបាលប្រឌិតឡើងនោះទេ។

លោក សេរី បានឱ្យដឹងតាមរយៈសារអេឡិចត្រូនិកពីប្រទេសដាណឺម៉ាកដែលលោកកំពុងរស់នៅនិរទេសដោយខ្លួនឯង ដើម្បីគេចពីការចាប់ខ្លួនពីសំណាក់អាជ្ញាធរថា "ខ្ញុំសូមបដិសេធ...ដែលថាខ្ញុំនៅពីក្រោយការដាក់គ្រាប់បែកក្នុងឆ្នាំ២០០៩។ ខ្ញុំមិនដែលប្រើអំពើហិង្សាម្តងណាឡើយ"។

លោកបាននិយាយថា "ខ្ញុំគិតថា នេះជាគម្រោងរបស់រដ្ឋាភិបាលក្នុងការប្រឌិតរឿងនេះឡើងដើម្បីចាប់ខ្លួនខ្ញុំ គឺរដ្ឋាភិបាលខ្លួនឯងដែលបានដាក់គ្រាប់បែកក្នុងបំណងទម្លាក់កំហុសលើរណសិរ្សរំដោះជាតិខ្មែរ និងចាប់ខ្លួនយើង"។

សមាជិករណសិរ្សរំដោះជាតិខ្មែរ១៣នាក់ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារពី៥ឆ្នាំដល់៩ឆ្នាំកាលពីខែមេសា ពីបទមានគម្រោងផ្តួលរំលំរដ្ឋាភិបាល គឺជាអ្វីដែលគេយល់ឃើញទូទៅថា ជាសាលក្រមមានលក្ខណៈនយោបាយដែលផ្អែកលើភ័ស្តុតាងបន្តិចបន្តួចស្តួចស្តើងប៉ុណ្ណោះ ៕ **មាធិត**

## តមកពីទំព័រទី ១៦ គណបក្សសង្គ្រោះជាតិបង្ហាញពីប្រាក់

១.១៨០ដុល្លារ ធ្វើឱ្យមានចំនួនដល់ ២.៣៧០ដុល្លារ។

តួលេខនេះគឺតិចជាងប្រាក់ខែរបស់លោក ហេង សំរិន ប្រធានរដ្ឋសភាតែបន្តិចបន្តួចប៉ុណ្ណោះ ដែលសរុបចំនួន ២.៣៨៤ដុល្លារ។ សមាជិកសភាដែលមិនមានការទទួលខុសត្រូវក្នុងគណៈកម្មាធិការទទួលបានប្រាក់ខែ៩៧៥ដុល្លារ ប៉ុន្តែប្រាក់ឧបត្ថម្ភផ្សេងៗ(រួមទាំង៥០០ដុល្លារ សម្រាប់ថ្លៃសាំង" ធ្វើឱ្យមានចំនួនដល់២.៦៥០ដុល្លារ។

លោក សុខសាន្ត បានមានប្រសាសន៍ថា លោក ហេង សំរិន និងលោក កឹម សុខា ទទួលបានប្រាក់បន្ថែមដាច់ដោយឡែកពីគ្នាចំនួន៥០០ដុល្លារក្នុងមួយខែសម្រាប់ថ្លៃសាំង។

លោក កែម ឡី ដែលអះអាងថា លោកមិនមានគម្រោងប្រែក្លាយក្រុម "ខ្មែរដើម្បីខ្មែរ" របស់លោកឱ្យទៅជាគណបក្សប្រជែងជាមួយគណបក្សសង្គ្រោះជាតិនោះបានមានប្រសាសន៍កាលពីម្សិលមិញថា លោកប្រកាន់តាមការអះអាងរបស់លោក។ លោកបានមានប្រសាសន៍ថា ការិយាល័យរបស់លោក កឹម សុខា ទទួលបានប្រាក់កម្រៃបន្ថែមដែលសរុបចំនួន១៥.០០០ដុល្លារ។

លោកបានមានប្រសាសន៍ថា "ការគណនានេះគឺត្រឹមត្រូវ។ សម្រាប់អនុប្រធាន ឬប្រធានសភាពួកគាត់មានអ្នកបើកបរយ៉ាងតិចម្នាក់ ហើយខ្ញុំមិនដឹងថា ពួកគាត់មានអង្គរក្សប៉ុន្មាននាក់ទេ"។ លោកបានមានប្រសាសន៍ថា "នៅពេលយើងនិយាយទៅកាន់សាធារណជនយើងគ្មានពេលប្រកាសថា តើប្រាក់ខែសរុបប៉ុន្មាន ហើយកញ្ចប់សម្រាប់សមាជិកសភាម្នាក់ៗប៉ុន្មាននោះដែរ។ ខ្ញុំយល់ស្របថា ប្រាក់ខែសម្រាប់ម្នាក់ៗគឺតិច ប៉ុន្តែប្រសិនបើអ្នកគណនាពីកញ្ចប់វិញ វាច្រើន"។

លោក សុខសាន្ត បានមានប្រសាសន៍ថា ឯកសារដែលលោកបានចេញផ្សាយនិយាយពីប្រាក់កម្រៃទាំងអស់ដែលលោក កឹម សុខា ទទួលបាននៅសភា។ លោកបានមានប្រសាសន៍ថា "អ្វីដែលលោក កែម ឡី និយាយនោះ គឺខុសទាំងស្រុង។ អ្វីដែលខ្ញុំចេញផ្សាយគឺជាឯកសារផ្លូវការដែលចុះហត្ថលេខាដោយប្រធានសភា"។ លោកបានបន្តថា អង្គរក្សរបស់លោក គឺជាការចំណាយរបស់លោកផ្ទាល់ ហើយមិនមានប្រាក់ខែពីសភាទេ។ ប្រសិនបើគាត់និយាយដូចនោះ គាត់គួរតែមានឯកសារ និងភ័ស្តុតាង"៕ **សារុន**

**MARCOTTE LAW FIRM**
**ក្រុមហ៊ុនមេធាវី Marcotte**
45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្តីអន្តរាយដល់បុគ្គល
- សំណងបុគ្គល
- ពិការភាពដោយសន្តិសុខសង្គម
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បណ្តឹងវិវាទទូទៅ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍
- ច្បាប់ធានារ៉ាប់រង
- ការរំលោភបទព្រហ្មទណ្ឌ
- គ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់នៅការដ្ឋាន
- បំណុលអចលនទ្រព្យ

**មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ**

**(978) 458-1229**

**www.marcottelawfirm.com**

# GATEWAY FAMILY DENTAL

www.gatewayfamilydental.com • (978) 455-5044

**151 WARREN STREET, SUITE 120 LOWELL, MA 01852 (Same building as Social Security/near the courthouse)**






## DR. SERENA B. CHUOP

Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 13 years, she has been in private practices providing all aspects of General Dentistry. Her state of the art dental practice includes digital x-rays, paperless patient chart system, and new dental equipments.

**WE PROVIDE ALL SERVICES INCLUDING: យើងផ្តល់នូវសេវាដូចខាងក្រោមនេះ**

- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS
- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN

- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជុំនួសធ្មេញដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមរន្ធធ្មេញចាស់
- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វែរនីស្រោបធ្មេញ
- ព្យាបាល និងការពារធ្មេញជាទៀងទាត់
- ព្យាបាល ឫសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

Free Teeth Whitening Kit
(with new patient´s x-ray, exam, cleaning at regular price)

**MOST DENTAL INSURANCES ACCEPTED INCLUDING MASSHEALTH**
**FINANCING AVALIABLE**
**យើងទទួលនូវគ្រប់ អ៊ិន ស៊ូរិន Masshealth**
**យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ**
**CALL FOR YOUR FREE CONSULTATION**
**(978) 455-5044**



LOWELL ELDER CARE
978-596-1111

# មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

**345 Chelmsford St. Lowell, MA 01851/ – www.lowelleldercare.com**

## អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ៏កក់ក្តៅមួយ ដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

## ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។

## មណ្ឌលផ្តល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្តៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

## Our Services

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips





**សូមហៅលេខទូរស័ព្ទ (978) 596-1111**

Accepting New Patients

# មជ្ឈមណ្ឌលពេទ្យ និងទទួលព្យាបាល ស៊ី ប៊ី ស៊ី

AT NEW LOCATION
ចាប់បើកហើយ

## CBC Medical & Walk-In Center

*Serving the Lowell Community for over 20 years!*

Mon - Fri 8AM-4PM. 1st & 3rd Sat: 8AM-NOON. 978-454-9703

ទទួលអ្នកជំងឺថ្មី

### Services:

- In House Lab & Blood Work
- Immunizations
- Physical Exams
- Emergency Room Follow-Ups
- Nebulizer & Asthma Treatments

- EKG Testing
- Wellness & Preventative Care
- Workers Comp Medical Treatment
- DOT Physicals
- Walk-Ins for Illness & Minor Injury

### Primary Care & Urgent Care Services
*ពេទ្យគ្រួសារ និងសង្គ្រោះបន្ទាន់*

- ពិនិត្យឈាមនៅមន្ទីរពិសោធន៍ក្នុងមជ្ឈមណ្ឌល
- ចាក់វ៉ាក់សាំងការពារ
- ពិនិត្យរាងកាយ
- តាមដានពិនិត្យនៅបន្ទប់ព្យាបាលបន្ទាន់
- ហ្វឹកហាត់ផ្លែកដកដង្ហើម

- ថតចលនាបេះដូង
- ថែទាំសុខភាពទូទៅសម្រាប់គ្រួសារ
- ទទួលព្យាបាលអ្នកទទួលគ្រោះថ្នាក់នៅកន្លែងធ្វើការ
- ពិនិត្យនិងផ្តល់លទ្ធផលបញ្ជាក់ដើម្បីទទួលសិទ្ធ
- អាចពិនិត្យពេលឈឺ និងគ្រោះថ្នាក់ដោយមិនបាច់ណាត់ជួប

**Cambodian Speaking Staff** (បុគ្គលិកនិយាយភាសាខ្មែរ)

**យើងខ្ញុំមានសេចក្តីសោមនស្សរីករាយជូនលោកអ្នក**
**យើងខ្ញុំនឹងផ្លាស់ទៅទីតាំងថ្មី**
*នៅផ្លូវ16 Pine St Unit #5 Lowell, MA 01851*
*នាថ្ងៃទី 21 កក្កដា ឆ្នាំ 2014*



**CBC Staff And Dr. Joshi Welcome You!**
**បុគ្គលិក និងវេជ្ជបណ្ឌិត យូស៊ី សូមស្វាគមន៍លោកអ្នក!**

***ចាក់ថ្នាំ Flu មកដល់ហើយ**




Like us on facebook

**CALL TO MAKE AN APPOINTMENT TODAY**
**(សូមទូរស័ព្ទដើម្បីណាត់ជួប)**
**978-454-9703**

## 16 Pine Street Unit #5 Lowell, MA 01851

តមកពីទំព័រទី ៩
## ខ្ទឹមក្រហមជួយបំបាត់រោគផ្កាសាយ....

សន្លឹកឆ្នោត និងហ៊ីលី ជាឧបករណ៍ ។

មាន៩៩ភាគរយនៅមណ្ឌលបោះឆ្នោតបានរាយការណ៍ថា លោក បេកើ បានឈ្នះឆ្នោតប្រមាណ៤ម៉ឺនសន្លឹកឆ្នោត ។

លោក បេកើ ជានាយកមន្ទីរសុខាភិបាលបានចំណាយថវិការដ៏ច្រើនហួសពីប្រាក់ចំណូលដើម្បីដណ្ដើមឱ្យបានជោគជ័យក្នុងការបោះឆ្នោតធ្វើឱ្យមានសភាពពុះកញ្ជ្រោលក្នុងសប្ដាហ៍ចុងក្រោយ រូបិយបដិភាគគាំទ្រក្នុងនោះ មានទាំងបុស្តុន ហ្គូប (Boston Globe)និងចៅហ្វាយក្រុងជាច្រើនរូបពីគណបក្សប្រជាធិបតេយ្យផងដែរ ។

ក្នុងការជាប់ឆ្នោតរបស់លោក បេកើ បានធ្វើឱ្យកំពង់ផែជំនួញរបស់នីតិប្រតិបត្តិដែលគណបក្សសាធារណៈរដ្ឋបានជ្រើសតាំង និងមានដំណើរការរស់ឡើងវិញ និងនាំមុខនៅសេរីនិយមជាងគេបំផុតក្នុងស.រ.អា ។

លោក បេកើ និងដើរតាមគន្លងរបស់លោក ម៉ឹត រ៉ូមនី (Mith Romney)លោក ផល សែរលាក់ស៊ី (Paul Cellucci)និងលោក ប៊ីវ វែវ (Bill weld)មានទ្រព្យសម្បត្តិ ឯកជនដោយមិនស្របច្បាប់ បណ្ដែតលើផ្ទៃសមុទ្រ និងចូលទៅក្នុងរដ្ឋដែលមានច្បាប់ អនុញ្ញាតិ ។

នោះជាសាច់មួយដុំដែលអភិបាលរដ្ឋនៃគណបក្សសាធារណៈរដ្ឋកំពុងធ្វើដំណើរសារក្រោយវិលទៅរកសម័យកាល១៩៩០របស់ លោក វែវ (Weld´s)ធ្វើការបោះឆ្នោតគណបក្សសាធារណរដ្ឋបានកាន់អំណាចរដ្ឋបាលក្នុងរដ្ឋម៉ាសាឈូសេតអស់រយៈពេល៥៥ឆ្នាំ គិតពីឆ្នាំ១៩១៣ រហូតមក ។

ក្នុងពេលជាមួយគ្នានេះដែរ គណបក្សសាធារណរដ្ឋបានក្ដាប់អំណាចនៅក្នុងរដ្ឋសភាអស់រយៈកាល៤៨ឆ្នាំផងដែរ ។

បេក្ខជនឯករាជ្យ៣រូបឈរឆ្នោតជាអភិបាល និងត្រូវរងសំពៀតអំពីសំណាក់មហាជន ទោះជាយ៉ាងនោះក៏ដោយ យើងគួរតែជួយបង្កបង្កើតគណបក្សនយោបាយថ្មី១ទៀតនៅក្នុងរដ្ឋ លោក ជែប មែក កូមីក (Jeff Mccormick)និងលោក (Scott Lively)ស្កត លីវស៊ី នាក់ទាំង២ពុំបានទទួល១ភាគរយនៃសន្លឹកឆ្នោតផង ។

លោក អ៊ី វែន ផលឆាក់(Evan Falchuk) បានខិតខំរកសន្លឹកឆ្នោតបានជាង៣ភាគរយនៃសន្លឹកឆ្នោតលោក ផល ឆាក់ គឺជាអ្នកទ្រមទ្របាននូវកិរិតផ្ដើមការកកើតគណបក្សឯករាជ្យនោះជាហេតុបណ្ដាលឱ្យគាត់ទទួលបាន៣ភាគរយក្នុងការបោះឆ្នោតបង្កើតជាច្រកចូលទៅក្នុងរដ្ឋបានទទួលស្គាល់ជាសភាគណបក្ស១រូប និងផ្ដល់សិទ្ធិឱ្យចូលរួមក្នុងសភាជាលើកដំបូង ដើម្បីបំពេញឯកសារបេក្ខជនសភា ៕

តមកពីទំព័រទី ១៥
## ធនាគារពិភពលោកនិយាយថា កម្ពុជាត្រូវ...

ធម្មជាតិបន្ថែមទៀតផងដែរ។ ទេសចរ៨០ភាគរយធ្វើដំណើរទៅប្រទេសថៃ ដើម្បីកម្សាន្តនៅតាមតំបន់ឆ្នេរ ហើយមានតែ១.៤ភាគរយប៉ុណ្ណោះដែលមកកម្ពុជាដើម្បីកម្សាន្តនៅតាមតំបន់ឆ្នេរ"។

របាយការណ៍នេះបញ្ជាក់ថា ចំនួនពាក់កណ្ដាលនៃទេសចររបស់កម្ពុជាមកតាមផ្លូវគោក ហើយថា គួរតែមានការជួសជុលថែទាំផ្លូវថ្នល់ឱ្យបានល្អប្រសើរ ហើយភ្ជាប់តំបន់ទេសចរណ៍ និងច្រកព្រំដែនសំខាន់ៗ។ របាយការណ៍នេះបានបញ្ជាក់ថា "ការធ្វើដំណើរតាមផ្លូវថ្នល់ដែលមានសភាពល្អនឹងជួយជំរុញឱ្យគោលដៅទេសចរណ៍សម្បូរបែបលើសពីឧទ្យានបុរាណអង្គរ ដើម្បីរាប់បញ្ចូលតំបន់ឆ្នេរខ្សាច់ និងទេសចរណ៍ធម្មជាតិផងដែរ"។

និយាយពីវិស័យសំណង់ដែលរីកចម្រើនយ៉ាងឆាប់រហ័សរបស់កម្ពុជាវិញ លោក អិនរីក អាលដាស ខារ៉ូល (Enrique Aldaz-Carroll) ដែលជាសេដ្ឋវិទូប្រចាំប្រទេសនៃធនាគារពិភពលោកបានសង្កត់ធ្ងន់ថា ធនាគារមើលមិនឃើញសញ្ញាកំណើនមិនរឹងមាំទេ ប៉ុន្តែលោកបានមានប្រសាសន៍ថា ចាំបាច់ត្រូវពិនិត្យតាមដានវិស័យនេះ។

លោកបានមានប្រសាសន៍ថា"វិស័យសំណង់គឺវិលចុះវិលឡើង ដូច្នេះយើងត្រូវធ្វើឱ្យប្រាកដថា កំណើនមិនរឹងមាំនឹងមិនកើតឡើងឡើយ"។ លោកបានមានប្រសាសន៍បន្ថែមទៀតថា វិស័យនេះបានកើនឡើង១៥ភាគរយកាលពីឆ្នាំមុន ហើយទំនងជានឹងទទួលបានកំណើនកាន់តែលឿនជាងមុននៅឆ្នាំនេះ។

របាយការណ៍នេះក៏បានផ្ដល់អនុសាសន៍ដែរថា កម្ពុជាគួរតែកែលម្អបរិយាកាសវិនិយោគរបស់ខ្លួនតាមរយៈការបន្ទាបថ្លៃអគ្គិសនីកាត់បន្ថយការិយាធិបតេយ្យហួសហេតុ និងកាត់បន្ថយអំពើពុករលួយ។"ឧបសគ្គធំៗដែលនៅតែកើតមានសម្រាប់ក្រុមហ៊ុននានា គឺតម្លៃអគ្គិសនី និងការទទួលបានការផ្គត់ផ្គង់អគ្គិសនីប្រើប្រាស់ការសូកប៉ាន់ និងការអនុវត្តគ្មានការប្រកួតប្រជែង"។

លោក ជូលៀន ខ្លាក (Julian Clarke) សេដ្ឋវិទូធុរកិច្ចជាន់ខ្ពស់នៅធនាគារពិភពលោកបានមានប្រសាសន៍ថា ពេលនេះក្រុមហ៊ុននានាសូកប៉ាន់រដ្ឋាភិបាលតិចជាងឆ្នាំមុនៗ ប៉ុន្តែថា ការប្រើប្រាស់ម៉ាស៊ីនធ្វើការជំនួសមនុស្សនឹងជួយកាត់បន្ថយអំពើពុករលួយបានកាន់តែច្រើន។

លោកបានមានប្រសាសន៍ទៀតថា"តាមការរំពឹងទុកក្រុមហ៊ុនទាំងអស់នឹងផ្ដល់អំណោយដល់រដ្ឋាភិបាល ប៉ុន្តែរឿងល្អគឺថា ចំនួនត្រូវបានកាត់បន្ថយ។ ការប្រើប្រាស់ម៉ាស៊ីនធ្វើការជំនួសមនុស្សគឺត្រូវការជាចាំបាច់ ដូច្នេះឱកាសសូកប៉ាន់នឹងលែងមាន"៕ **សុខុម**


រោងជាង ចេនា

LEGEND
AUTO BODY INC.

អាស័យដ្ឋាន 115 Rock St. #7 Lowell, MA 01854
សូមទំនាក់ទំនង **អាដាំ ទ៉ា** : 978-458-2085
ជួសជុលយានយន្តលោកអ្នកប្រកបដោយគុណភាព

Lowell Finest Quality of Body Work

**មានបម្រើ**
- ជួសម៉ាស៊ីនយានយន្ត
- ប្រភេទយានយន្តក្នុង និងក្រៅប្រទេស

**តួយានយន្ត**
- បញ្ជាក់ប័ណ្ណធានារ៉ាប់រងទទួលស្គាល់ដោយរដ្ឋ

**ដឹកឡានត្រូវខូច** 978-815-9957 (ខេ-ស៊ី)






AUTO BODY INC.
(978) 458-2085

**Services**
- Auto Body
- Auto Mechanics
- Foreign and Domestics
- State and Insurance Certified

Towing - **978-815-9957** (K.C)



115 Rock St. Unt #7 Lowell, MA 01854

## តមកពីទំព័រទី ១៩ មន្ត្រីគណបក្សសង្គ្រោះជាតិមួយរូបទៀត...

ចោទប្រកាន់ស្រដៀងគ្នាពីបទ "ដឹកនាំការបះបោរ" បន្ទាប់ពីក្រុមអ្នកតវ៉ាបានវាយតបទៅលើសន្តិសុខខណ្ឌដូនពេញដែលក្នុងរយៈពេលប៉ុន្មានខែនោះបានវាយដំយ៉ាងព្រៃផ្សៃលើអ្នកតវ៉ាដែលព្យាយាមចូលទៅជិតទីលានប្រជាធិបតេយ្យ។

យ៉ាងហោចណាស់ សន្តិសុខខណ្ឌពីរនាក់បានរងរបួសធ្ងន់ ហើយសន្តិសុខមួយចំនួនទៀតត្រូវបានបញ្ជូនទៅផ្នែកថែទាំនៅមន្ទីរពេទ្យមួយរយៈពេលខ្លី។

លោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិបានបដិសេធមិនឆ្លើយបំភ្លឺទេជុំវិញការចាប់ខ្លួនលោក មៀច សុវណ្ណារ៉ា កាលពីម្សិលមិញ ហើយបានបង្វែរសំណួរទៅលោក យឹម សុវណ្ណ អ្នកនាំពាក្យគណបក្សនេះ។ លោក យឹម សុវណ្ណ បានមានប្រសាសន៍ថា គណបក្សប្រឆាំងមានការព្រួយបារម្ភថា ការចាប់ខ្លួននេះត្រូវបានធ្វើឡើងដើម្បីដាក់សម្ពាធឱ្យខ្លួនយល់ស្របតាមនៅក្នុងការចរចាអំពីកំណែទម្រង់បោះឆ្នោតដែលបានជាប់គាំងកាលពីពេលថ្មីៗនេះ។

លោក យឹម សុវណ្ណ បានមានប្រសាសន៍ថា "ជាការពិតវាជាក្តីបារម្ភ។ ប៉ុន្តែយើងសូមអំពាវនាវទៅគណបក្សប្រជាជនកម្ពុជាមេត្តាកុំបង្កបញ្ហាបន្ថែមទៀត ដើម្បីបរិយាកាសល្អនៃការចរចា។ យើងចង់ចរចាក្រោមបរិយាកាសល្អ យើងមិនចង់ឃើញបញ្ហាកើតឡើងម្តងហើយម្តងទៀតនោះទេ នេះគឺជាឆាកល្ខោនដែលគណបក្សប្រជាជនកម្ពុជាសម្តែងដដែល"។

បច្ចុប្បន្នគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិកំពុងជាប់គាំងនៅក្នុងការចរចាជុំវិញលក្ខណសម្បត្តិដែលសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមួយដែលត្រូវបានធ្វើកំណែទម្រង់គួរមាន និងថា តើគួរអនុញ្ញាតឱ្យពួកគេមានសញ្ជាតិបរទេស ឬយ៉ាងណា។

ការចាប់ខ្លួនតំណាងរាស្ត្រជាប់ឆ្នោតប្រាំពីររូប និងមន្ត្រីមួយរូបទៀតរបស់គណបក្សសង្គ្រោះជាតិកាលពីខែកក្កដា បានកើតមានឡើងតែមួយសប្តាហ៍ប៉ុណ្ណោះមុនពេលលោក សម រង្ស៊ី និងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសភ្លាមៗបញ្ចប់ការជាប់គាំងខាងនយោបាយក្នុងប្រទេស និងការបញ្ចប់ការធ្វើពហិការមិនចូលសភារយៈពេល១០ខែរបស់តំណាងរាស្ត្រទាំង៥៥រូបនៃគណបក្សសង្គ្រោះជាតិ។

នៅក្នុងខែដែលឈានដល់កិច្ចព្រមព្រៀងថ្ងៃទី២២ ខែកក្កដា ដោយគណបក្សសង្គ្រោះជាតិបានច្រានចោលការប្រើប្រាស់ពាក្យពេចន៍របស់គណបក្សប្រជាជនកម្ពុជានៅក្នុងសេចក្តីព្រាងសម្រាប់ជំពូកថ្មីមួយនៃរដ្ឋធម្មនុញ្ញដែលជាផ្នែកនៃកិច្ចព្រមព្រៀងនោះ នគរបាលបានចាប់ខ្លួនមេដឹកនាំចលនាយុវជនបីរូបរបស់គណបក្សសង្គ្រោះជាតិក្នុងរាជធានីភ្នំពេញ។




សកម្មជនទាំងបីរូបនោះត្រូវបានដោះលែងវិញពីរសប្តាហ៍ក្រោយពីគណបក្សសង្គ្រោះជាតិព្រមចូលសភាតាមការទាមទាររបស់គណបក្សប្រជាជនកម្ពុជា។

លោក ស៊ុំ ពុទ្ធី ដែលជាសមាជិកគណបក្សសង្គ្រោះជាតិនៅក្រុមប្រឹក្សាខណ្ឌច្បារអំពៅ ក៏ត្រូវបានចាប់ខ្លួនដែរកាលពីខែកញ្ញាពាក់ព័ន្ធនឹងការតវ៉ាដដែលនេះ ហើយបច្ចុប្បន្នមន្ត្រីមួយរូបក្នុងចំណោមមន្ត្រីទាំងពីររូបរបស់គណបក្សសង្គ្រោះជាតិកំពុងជាប់ឃុំនៅពន្ធនាគារព្រៃស។

លោក យឹម សុវណ្ណ បានមានប្រសាសន៍កាលពីម្សិលមិញថា លោកជឿថា ការចរចាដែលកំពុងបន្តរវាងគណបក្សទាំងពីរជុំវិញច្បាប់ស្តីពីច្បាប់បោះឆ្នោតនៅតែអាចដំណើរការទៅមុខបាន ទោះបីជាមានការចាប់ខ្លួនលោក មៀច សុវណ្ណារ៉ា ក្តី។

លោកមានប្រសាសន៍ទៀតថា "បញ្ហានេះ នឹង ធ្វើឱ្យការចរចាមានការពិបាក។ ទោះជាយ៉ាងណាយើងនឹងព្យាយាមអស់ពីលទ្ធភាពដើម្បីចរចាដោយសន្តិវិធី ហើយខ្ញុំជឿថា លោកប្រធាន សម រង្ស៊ី របស់ខ្ញុំនឹងអំពាវនាវទៅមេដឹកនាំកំពូលៗនៃគណបក្សប្រជាជនកម្ពុជាឱ្យព្យាយាមដោះស្រាយនេះ"។

លោកបានលើកឡើងថា លោកជឿថា ការចរចាជាមួយគណបក្សប្រជាជនកម្ពុជានឹងឈានទៅដល់ការដោះលែងលោក មៀច សុវណ្ណារ៉ា ក្នុងពេលឆាប់ៗនេះ។ លោកបានបន្តថា "ការចាប់ខ្លួនបានកើតឡើងពីរបីដងរួចមកហើយកាលពីមុន។ ដំណោះស្រាយនឹងដូចកាលពីមុន"៕

**សុខុម** (រាយការណ៍បន្ថែមដោយ Alex Willemyns)


AccuCare Home Care Agency
Group Adults Foster Care Program

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

Homecare Agency
Group Adult Foster Care Program (GAFC)
MassHealth

*ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន*
*បុគ្គលិកមានសណ្ដានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ*
*អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ*



*Compassionate Care & Reliable*
*Professional & Cultural Sensitive*
*Management & Staffs speak Khmer*

*កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើង ដែលមានប ញ្ហារ៉ាំរ៉ៃផែ្នកសុខភាព ឬជរាហើយមិនចង់ ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។*

*Accucare Homecare Agency is the perfect solution for seniors and others who are not ready to leave their home for an institutional setting or live with reltives because of illness or chronic conditions. We improve your life by providing one-on-one compassionate senior care in the comfort of your own home.*

***ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :***
*To be eligibled for GAFC you must:*
*-រស់នៅផ្ទះរដ្ឋ (live in subsidized or public housing)*
*-អាយុ ២២ ឆ្នាំឡើងទៅ (age 22 years and older)*
*-មាស់ហែលស្តង់ដា (eligible for Masshealth Standard)*
*-ត្រូវការជំនួយក្នុងការរស់នៅប្រចាំថ្ងៃយ៉ាងហោចណាស់មួយដូចជា មុជទឹក ស្លៀកពាក់ ពេលប្រើបង្គន់ទឹក ចំអិនអាហារ ឬ ពេលដើរ (need daily assistance with one or more personal care tasks such as bathing, dressing, toileting, meal preparation and/or moving)*
*-មានការអនុញ្ញាតពីគ្រូពេទ្យផ្ទាល់ខ្លួនអ្នក (have physician statement of your condition)*
*-ត្រូវបានវាយតំលៃផ្នែកសុខភាព និងការអនុម័តយល់ព្រមពីកម្មវិធី (be screened and approved for the program )*

***ផលប្រយោជន៍ទទួលបាន :***
*Benefits you will get:*
*-ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ (personal care service in your home, up to one hour of service each day)*
*-ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក (Medication Managemant)*
*-ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីជើ (an individual care plan developed by a registered nurse and case manager)*
*-វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់ (ongoing monitoring of needs)*
*-សមាជិកអាចទាក់ទងមក ២៤ម៉ោង (24-hour access to services)*

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:

ឱក តុលាយុត្តិ ឡូវែល
Tolayuth Ok: Lowell
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

ទស្សនៈអ្នកអាន

# តើល្មមជឿបានហើយ ឬនៅ?

**ដោយ : សុខ សាន្ត**

ជាដំបូងខ្ញុំសូមទោសបងប្អូន សមាជិកគណបក្ស សម រង្ស៊ី (កាលពីមុន) លេខមុនខ្ញុំមិនបានរំលឹកពីភាពឈ្លាសវៃប្រធានបក្ស សម រង្ស៊ី មកនិយាយ លើកតែភាពឈ្លាសវៃរបស់ប្រធានបក្សសិទ្ធិមនុស្សមកនិយាយ មកពីខ្ញុំយល់ថាបងប្អូនពិតជាយល់ព្រោះ២៦អាសនៈ និង៣អាសនៈមួយណាសំខាន់ជាង ។

វិលមករកអត្ថបទរបស់យើងវិញ តាំងពីគណបក្សសង្គ្រោះជាតិចូលសភាមក យើងឃើញបទនយោបាយនៅក្នុងរដ្ឋសភាប្រទេសកម្ពុជាល្អប្រសើរច្រើនល្មមអាចកំណត់បានថា បក្សសង្គ្រោះជាតិមានសមត្ថភាពអាចសណ្តោង បក្សប្រជាជនឱ្យដើរមករកផ្លូវល្អ ផ្លូវត្រូវវិញ បានជាបណ្តើរៗ ទោះជានៅមានបុគ្គលខ្លះគាត់មិនអាចបត់បែនឱ្យទាន់សភាការណ៍ក្តី ក៏គាត់កំពុងតែគិតតើគួរធ្វើជាមនុស្សល្អឱ្យទាន់សម័យកុំព្យូទ័រ ឬក៏នៅតែងឱបអតីតកាលយកខុសធ្វើត្រូវ យកត្រូវធ្វើខុស អតីតកាលឃោរឃៅ ឃុំ ឃាំង ឃះ ។

មិនបាច់យើងរំលឹកក៏គាត់នឹកឃើញដែរ ព្រោះសម័យនេះទៅហើយ បើបត់បែនមិនទាន់លោកអ្នកនឹងទទួលបានងារ ក្បត់ប្រទេសជាតិ ក្បត់សង្គម ក្បត់ពលរដ្ឋខ្មែរ រមិលគុណថ្ងៃ២៣តុលា សន្និសីទទីក្រុងប៉ារីស ដែលបានធ្វើឱ្យបុគ្គល១ចំនួនក្លាយជាមហាសេដ្ឋីខាងគំនិតស្មោគគ្រោកនៅជិតជាប់គ្រប់ពេលវេលា ។ ក្នុងនាមជាពលរដ្ឋខ្មែរសុំអង្វរ អង្វរហើយ អង្វរទៀត សូមអស់លោកក្រឡេកទៅមើល អតីតកាលអស់លោកផង ។ ហើយតើគួរដែរ ឬទេ? ដែលអស់លោកអ្នកផ្ចិបភ្នែក ធ្វើខ្វាក់ បណ្តោយឱ្យពលរដ្ឋខ្មែរលង់ធ្លាក់ ជ្រៅទៅៗ ដូចធ្លាក់នរកទាំងរស់ ។ ល្មមហើយ ពិតជាល្មមមិនគួរទុកខ្លួនប្តីប្រពន្ធកូនចៅ ឱ្យនៅជាមួយសន្តានអាក្រក់ជួរជាតិតទៅទៀតទេ ។ មេត្តាសម្លឹងមើលងាយក្រោយទៅរកអតីកាល តើអញបានធ្វើអ្វីខ្លះពីមុនមក តើលោកណាខ្លះរងគ្រោះ ព្រោះទង្វើអតីតកាលរបស់ខ្លួន បើអញនៅប្រព្រឹត្តបែបនេះតទៅទៀតពលរដ្ឋរងគ្រោះ និងថ្កោលទោសអញដល់ថ្នាក់ណាទៅអនាគត ។ នេះគ្រាន់តែជាការពិចារណាមួយ ក្នុងពេលប្រាស់ខ្លួនគេងទៅ សម្លឹងពិដានផ្ទះគិតថាតើថ្ងៃនេះ ខ្ញុំបានធ្វើអ្វីខ្លះ ជាអំពើអកុសល ឬជាអំពើអកុសល ហើយក៏សូមកោតសរសើរទឹកចិត្ត បងប្អូនខ្មែរយើងនៅគ្រប់ទិសទី ក្នុងប្រទេស និងក្រៅប្រទេស ដែលបានលះបង់កម្លាំងកាយកម្លាំងចិត្ត ថវិកា ទោះតិចក្តី ច្រើនក្តី ក៏ជាភក្តីភាព ដ៏ស្មោះត្រង់ ដែលអស់លោកអ្នកមានចំពោះប្រទេសជាតិ និងពលរដ្ឋខ្មែរដែលរងគ្រោះ ។

ហើយក៏សូមជំរាបបងប្អូនខ្មែរយើងខ្លះ ដែលបានជួយបក្សសង្គ្រោះជាតិកន្លងមក ក៏ដូចជួយប្រទេសជាតិ និងពលរដ្ឋខ្មែរ សូមមេត្តាគិតសារឡើងវិញ កុំអាក់អន់ចិត្តនឹងថ្នាក់ដឹកនាំបក្សង្គ្រោះជាតិ ព្រោះសន្តានចិត្តមនុស្សយើងមិនដូចគ្នាទាំងអស់ទេ! ព្រោះការគិតរបស់យើងម្នាក់ៗមិនត្រូវគ្រប់ពេលវេលានោះដែរ ហើយអ្នកផងក៏មើលឃើញទង្វើគ្រប់យ៉ាងដែលយើងធ្វើ ។ ទំរាំបានត្រាសជាព្រះពុទ្ធ លោកបានកសាងជាច្រើនជាតិ ! ទំរាំមានអង្គការសហប្រជាជាតិមួយនៅលើពិភពលោកបណ្តុំគំនិតបណ្ឌិត អ្នកប្រាជ្ញ អស់លោកចេះដឹងយ៉ាងច្រើននៅលើពិភពលោក ! ទំរាំឈានមកដល់ថ្ងៃនេះ លោក សម រង្ស៊ី លោក កឹម សុខា ប្រើគំនិតគួរប្រាជ្ញ ស្មារតី ឈ្លាសវៃច្នៃប្រឌិត គំនិតល្អៗ គ្រប់បែបយ៉ាងទំរាំពលរដ្ឋយ៉ាងច្រើននៅលើពិភពលោកគាំទ្រ កោតសរសើរគិតមើលសារឡើងវិញ តើបងប្អូន ក្មួយ បានលះបង់អ្វីខ្លះ ពេលវេលាប៉ុន្មាន ថវិកា គំនិត ប្រាជ្ញាមួយជីវិតខ្លួន ឈ្លាសវៃ ជួយខ្លួនឯង បងប្អូន ប្តីប្រពន្ធ កូន ចៅ សាច់ញាតិបានគំនិតណាឧត្តុង្គឧត្តម្ភ ថ្លៃថ្នូរ កិរិតណា គិតសិនចាំវាយតម្លៃពីសមត្ថភាពរបស់ខ្លួនយើង ។

សំខាន់បំផុតកុំធ្វើឱ្យអំពើល្អឧត្តុង្គឧត្តម្ភរបស់យើងវាបាត់បង់ទៅជាមួយ ការមោទនៈភាពខ្លួនឯងជ្រុលពេក បែរជាបាត់បង់ឱកាសដែលខ្លួនប្រាថ្នាចង់បាន (សន្សឹមៗកុំបំបោលក្រែងពុំដល់ដូចប្រាថ្នា) ។ ការចាប់យកពេលវេលា ជួយប្រទេសជាតិ និងសង្គមទាមទារសេចក្តីសុច្ចរិតស្មោះត្រង់ ចំពោះជាតិ និងពលរដ្ឋខ្មែរដែលរងគ្រោះពិតៗ ទើបបានជោគជ័យ ។

ព្រោះសម័យនេះមិនមានអាថិកំបាំងកម្លាំងទៀតទេ មធ្យោបាយហុតទឹកសម្លឹងកាកមិនជោគជ័យទេ ព្រោះវានឹងធ្វើឱ្យបរាជ័យ ទទួលភាពអាម៉ាស់ទៅថ្ងៃក្រោយ ៕

ហ្វេយ៍មីកខេប ផ្ទះសម្រាប់ពិធីបុណ្យសព
Fay McCabe Funeral Home
105 Moore Street. Lowell, MA 01852
978-459-9222

បម្រើសហគមន៍ខ្មែរដោយការយកចិត្តទុកដាក់ កិត្តិយស
និងការគោរពជាង៣០ឆ្នាំមកហើយ

- Serving All Faiths បម្រើសេវាកម្មគ្រប់ជំនឿ
- Traditional Funerals កម្មវិធីបុណ្យសពជាលក្ខណៈប្រពៃណី
- Cremation Services មានផ្តល់សេវាបូជាសព
- Pre Arranged Funerals រៀបចំរោងមុនកម្មវិធីបុណ្យសព

លោកអ្នកនឹងក្រុមគ្រួសារទទួលបាននូវការយកចិត្តទុកដាក់
និងការបម្រើល្អប្រពៃពីទីនេះ ។

www.faymccabe.com



Locates 1 mile from Glory Buddhist Temple,
between Gorham St. & Lawrence St.
ទីកន្លែងនៅចំងាយ១ម៉ាយពីវត្តពន្លឺពុទ្ធចក្រ
ចន្លោះផ្លូវ Gorham St. & Lawrence St.

មានបុគ្គលិកនិយាយភាសាខ្មែរ

# កូនឈឺបំពង់ក ឪពុកម្ដាយគួរធ្វើដូចម្ដេច?



**បើសិនជាអ្នកមានកូនតូចនៅផ្ទះ អ្នកប្រហែលជាត្រូវយកចិត្តទុកដាក់លើពួកគេច្រើន ដោយសារតែពួកគេងាយនឹងមានបញ្ហាផ្ដាសាយ និងក្អក ។ តាមពិតការឈឺបំពង់.កលើក្មេងតូចៗច្រើនតែកើតមានជាញឹកញាប់ ដែលបណ្ដាល មកពីការបង្ករោគដោយបាក់តេរីឬវីរុសដើម្បីឱ្យប្រព័ន្ធភាពស៊ាំរបស់ក្មេងរីកចម្រើន ។ ដូចនេះយើងមានវិធីសាស្ត្រមួយចំនួនអាចឱ្យគេធូរស្រាលបានមួយកម្រិតផងដែរ ។**

**- ធ្វើឱ្យផ្លូវដង្ហើមស្អាតល្អ**

នៅពេលក្មេងមានអាការផ្ដាសាយ និង ហៀរសំបោរ អាការតឹងច្រមុះនឹងធ្វើឱ្យមាត់បើករហូត ដែលជាហេតុនាំឱ្យបំពង់.កទៅជាស្ងួត និងឈឺចាប់បាន ។

-យកល្អគួរតែប្រើថ្នាំបំបាត់ការតឹងច្រមុះមុនពេលវាធ្វើទុក្ខពេលដេក ។

-បន្តក់សេរ៉ូមប្រៃក្នុងច្រមុះដើម្បីឱ្យផ្លូវ ដង្ហើមស្អាតល្អ ។

**-ត្រូវឱ្យកុមារទទួលទានដំណេកគ្រប់គ្រាន់**

យកល្អគួរតែឱ្យកូនគេងឱ្យបានច្រើនបំផុត ព្រោះ

-ការគេងជួយឱ្យក្មេងសន្សំកម្លាំងបានច្រើនដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺឈឺបំពង់.ក

-ការគេងត្រាំទឹកក្ដៅឧណ្ហៗនឹងជួយឱ្យពួកគេឆាប់ជា ។

**ខ្ពុរមាត់**

វាគឺជារឿងសំខាន់ដែលកូនរបស់អ្នកចេះរបៀបខ្ពុរមាត់ជាមួយនឹងទឹកក្ដៅឧណ្ហៗពេលពួកគេឈឺបំពង់.ក ។

-ការខ្ពុរមាត់នឹងទឹកអំបិលក្ដៅឧណ្ហៗនឹងជួយឱ្យបំពង់.កស្អាតល្អ

-រមៀតនិងអំបិលគួរតែដាក់ទៅក្នុងទឹកក្ដៅឧណ្ហៗនោះ ដើម្បីអាចជួយកាត់បន្ថយការបង្ករោគនៅក្នុងបំពង់.កបាន ។

**-ផឹកទឹកក្ដៅ**

ក្មេងគួរតែលើកទឹកចិត្តឱ្យញ៉ាំទឹកក្ដៅឧណ្ហៗឱ្យបានច្រើនដូចជា

-ទឹកដែលមានជីវជាតិច្រើន

-ទឹកស៊ុប

**- ឆ្អុង**

យកល្អយ៉ាងហោចណាស់ក៏ឱ្យក្មេងៗឆ្អុង ឬងូតទឹកក្ដៅដែរ ព្រោះចំហាយឆ្អុងក្ដៅៗនឹងជួយឱ្យផ្លូវដង្ហើមបើកបានល្អ

-សំណើមនៃចំហាយឆ្អុងក្នុងបំពង់.កនឹងជួយឱ្យអាការឈឺនោះបាត់ទៅវិញ

**-សម្អាតបំពង់.ក**

នៅពេលក្មេងឈឺបំពង់.កនៅរដូវរងាយកល្អគួរតែឱ្យពួកគេស្លៀកសម្លៀកបំពាក់ដែលកក់ក្ដៅ និងយកអ្វីមកគ្របបំពង់.កខាងក្រៅ និង ផ្ដល់ភាពកក់ក្ដៅដល់បំពង់.កផង ។

**-ញ៉ាំទឹកឱ្យបានច្រើន**

ក្មេងនឹងមិនសូវឃ្លានអាហារទេនៅពេលពួកគេមានជំងឺផ្ដាសាយ ។ បើសិនជាពួកគេឈឺបំពង់.កទៀត ពួកគេនឹងមិនចង់ញ៉ាំអាហាររឹងៗឡើយ ។ អ្វីដែលជាតម្រូវការសម្រាប់ពួកគេមានដូចជា ញ៉ាំទឹកឱ្យបានច្រើន ដើម្បីឱ្យប្រព័ន្ធក្នុងរាងកាយមានជាតិទឹកគ្រប់គ្រាន់ និងកម្ទាត់ជាតិពុល ៕




# ហាងខ្មែរជួសជុលរថយន្ត

**បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ**

# Rathe's Auto Service

State and Emission Inspaction General Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងក៏រិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្ដាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្ដេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬ ធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376

# ANGKOR AUTO SERVICE,INC.

# ហាងជួសជុលរថយន្ត "អង្គរ"

**Free Estimate**

**Auto Body and Maintenance**



**BODY WORKS**

**Auto glass and windshields**

**Auto Frame Straightening and Painting**

មានបទពិសោធន៍២០ឆ្នាំ ជាជាងរថយន្តមានសញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់អិនស្វ៊ិរិនបានផង យើងផ្ដល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES

State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services



From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.

4835 N. 16th Street. Philadelphia, PA 19141
Tel : (215) 455-7810 / Ricky : (215) 485-1425

## តមកពីទំព័រទី ១២ ដំណើរពីអាមេរិកទៅអាស៊ី

កាលនោះព្រះអង្គគង់ជាឯកអគ្គរាជទូតប្រចាំយូណេស្កូនាទីក្រុងប៉ារីសមកម្លេះ។ ព្រះអង្គធ្លាប់ឱ្យជាជំហ៊ររយ៉ាងមាំដល់ ស៊ីលវិយ៉ា នឹងកូនស្រីទាំងបីក្នុងការទ្រទ្រង់សកម្មភាពមនុស្សធម៌ជួយកុមារកំព្រាកម្ពុជាពីប្រទេសបារាំងមក តាំងពីអំឡុងឆ្នាំ១៩៩៤មកទល់សព្វថ្ងៃនេះ។ ជាអកុសលខ្ញុំនិងស៊ីលវិយ៉ាមិនបានរស់នៅជាមួយគ្នាចែកផ្លូវគ្នាតាំងពីឆ្នាំ១៩៨៨មកម្លេះ ។

ថ្ងៃទី ៩តុលា២០១៤មេឃស្រឡះល្អខ្ញុំនឹងភរិយាសុបិនរៀបចំដំណើរយ៉ាងហត់នឿយឥតបានដេកពួនមួយយប់ពេញពីព្រោះជាប់រវល់ធ្វើការឱ្យកុំប៉ានីរហូតដល់នាទីចុងក្រោយចុងបញ្ចប់ក៏បានចេញដំណើរតាមយន្តហោះ"AAeGeG American Airline" ពី Boston បុស្តុនទៅម៉ោង១០ព្រឹកមកកាន់ Chicago ឈីកាហ្គោនៅម៉ោង១កន្លះ រីឯអ្នកដែលសប្បាយរីករាយជាគេគឺប៉ុណ្ណារ៉ូដែលតាំងពីព្រលឹមព្រាង។និយាយនឹងលេងច្រើនឥតឈប់ឈរធ្វើឱ្យយើងជាឪពុកម្តាយតាមចាប់ស្ទើរមិនឈ្នះ។ យន្តហោះប៊ូអ៊ីងដែលមានចំណុះភ្ញៀវពេញប្រមាណ៣០០នាក់អង្គុយយ៉ាងចង្អៀតណែនក្បែរអ្នកដំណើរគ្រប់ប្រភេទមិនដឹងនរណាជានរណាទេយើងមិនចាំបាច់ស្លៀកពាក់ជាមនុស្សសំខាន់អ្វីទៀតទេឥឡូវនេះដំណើរតាមយន្តហោះគ្រាន់តែជាជំនិះរបស់មនុស្សតែប៉ុណ្ណោះបើចង់ក្លាយជាមនុស្សសំខាន់គេត្រូវទិញសំបុត្រយន្តហោះថ្នាក់ទី១ឬទី២ ទើបមានការយកចិត្តភ្ញៀវតាមឋានៈជាមនុស្សសំខាន់បានដូច្នេះគឺចំនួនលុយទេដែលអាចចង្អុលបង្ហាញថាមនុស្សណាជាអ្នកសំខាន់នោះ ។ នៅឈីកាហ្គោយើងរង់ចាំជើងដំណើរបន្តរហូតដល់ម៉ោង៣កន្លះរសៀល ទើបចេញដំណើរបន្តទៅកាន់បាងកក Bangkok នៃប្រទេសថៃជាបន្តទៅទៀត។ ម្តងនេះយើងជិះយន្តហោះខ្នាតធំជាងគេបង្អស់ គឺប៊ូអ៊ីង៧៤៧ ដាក់ភ្ញៀវនឹងបុគ្គលិកបានជាង៥០០នាក់...ជាថ្មីម្តងទៀតខ្ញុំសូបិននឹងកូនអាយុ៤ឆ្នាំកន្លះ អង្គុយថ្នាក់ទី៣ យ៉ាងគួរឱ្យអាណិតខ្លួនលើកៅអីតូចចង្អៀតរីខ្លួនមិនរួចចំនួន១៤ម៉ោងមុននឹងដល់ដំណាក់សម្រាកប្តូរយន្តហោះនៅហុងកុងទីក្រុងចិនកុម្មុយនិស្តក៏សាងជាក្រុងសេដ្ឋកិច្ចទំនើបដោយចក្រភពអងគ្លេសដែលបានត្រួតត្រាលើដែនដីចិននេះចំនួន១០០ឆ្នាំ ។ យើងបានមកដល់ចំពេលដែលប្រជាជនចិនតំបន់ហុងកុងនេះចុះធ្វើបាតុកម្មគគ្រឹកមេឃគគ្រឹកដីជាងមួយអាទិត្យហើយទាមទារមិនឱ្យចិនដីគោកកុម្មុយនីស្តបេយ៉ីងលូកដៃដ៏មានអំណាចរបស់ខ្លួនមកលើការគ្រប់គ្រងតាមបែបសេរីរបស់ចិនហុងកុងបើទោះជាបេយ៉ីងជាម្ចាស់ទឹកម្ចាស់ដីក៏ដោយ ។ ការពិតទៅយើងមិនបានឃើញអ្វីទាំងអស់ក្រៅតែពីចិននៅក្រុមហ៊ុនយន្តហោះកាតេផាសវីហ្វិកជាតហាយភាចិថិចនឹងនៅវាលយន្តហោះដ៏ធំសម្បើមនៃក្រុងហុងកុងខ្ញុំបានសួរទៅនារីធ្វើការក្នុងយន្តហោះដ៏ស្រស់ស្អាតម្នាក់ថាតើហុងកុងនៅតែវឹកវរនៅឡើយទេឬក៏ស្ងប់ស្ងាត់ទៅហើយ? នាងតបដោយញញឹមហើយញាក់ស្មាផងថាខ្ញុំឥតដឹងដែរ ពីព្រោះខ្ញុំចេញមកធ្វើការ២ថ្ងៃហើយ...ប៉ុណ្ណារ៉ូឃើញខ្ញុំនិយាយជាមួយស្រីចិនក៏ចូលជិតហើយសួរថា ប៉ាចេះនិយាយភាសាចិនឬ? ពីព្រោះមុននេះបន្តិចខ្ញុំបានប្រាប់គេថាចិនគេនិយាយភាសាចិនយន្តហោះនេះក៏ជារបស់ចិននៅហុងកុងដែរខ្ញុំក៏ឆ្លើយនឹង

តទៅលេខក្រោយ

## តមកពីទំព័រទី ១៤ ភាពជាប់គាំងនៃវត្តត្រៃរតនារាមនៅតែបន្ត...

ប៉ុន្តែវត្តបច្ចុប្បន្នមានបញ្ហាជាប់គាំងកាន់តែបន្ថែមទុក្ខព្រួយមួយចំណែកទៀតចំណែកលោក សថែល វិញបាននិយាយថា គាត់ត្រូវបានចាត់ជាតំណាងមកទីនេះជួបពូ ដើម្បីនិយាយឱ្យបានសុខសន្តិភាពទាំងអស់គ្នាឱ្យបានស្មើមុខគ្នាទៅកុំឱ្យមានឈ្នះចាញ់គ្នាទៀតខ្ញុំថាវាស្រួលទេតើ? ខ្ញុំបានផ្តល់ឱ្យហើយ! ប៉ុន្តែក្រុម ថែល អត់ព្រមទទួលយកទេសួរថាហេតុអ្វីបានជាមិនទទួលយក? ព្រោះចាស់ទុំទាំងបួនដែលបានដាក់ឈ្មោះខ្លួនឯងថា ក្រុមស្នូមបានសុំអង្វរឱ្យស្រុះស្រួលគ្នាដើម្បីឱ្យប្រជាជនបានធ្វើបុណ្យទាននោះរីឯខាងខ្ញុំ( ប្រាហឹម កៃ ) បានស្ម័គ្រចិត្តយល់ព្រមតាមសំណូមពរក្រុមចាស់ទុំទាំងបួនហ្នឹងសុខចិត្តលាលែងពីតំណែងគណកម្មការទាំងអស់គ្នាដោយស្មើមុខគ្នាហើយមិនមានអ្នកឈ្នះ និងអត់មានអ្នកចាញ់ទេ ព្រោះពួកគាត់ជាតំណាងសហគមន៍មកសុំអង្វរយើងឱ្យយើងជាគ្នាវិញស្រុះស្រួលគ្នាដើរចេញពីវត្តទុកឱ្យគាត់ (ក្រុមស្នូមទាំងបួន) ជាអ្នករៀបចំវត្តឡើងវិញហើយលែងមានទំនាស់ទៀតហើយដោយយើងបានប្រគល់ភារកិច្ចឱ្យមនុស្សចាស់ទុំក្នុងសហគមន៍ជាអ្នករៀបចំវត្តឱ្យសហគមន៍បានធ្វើបុណ្យធ្វើទានឡើងវិញដូច្នេះថែលក៏បានប្រាប់ខ្ញុំថា បើអញ្ចឹងពូព្រមតាមសំណូមពររបស់ចាស់ទុំទាំងបួនឬ? ខ្ញុំបានឆ្លើយថា ខ្ញុំចង់បានដូចតាមសំណូមពរចាស់ទុំទាំងបួនដោយខាងថែលទេ ដែលជំទាស់នឹងពួកគាត់! តើថែល យល់យ៉ាងម៉េចចំពោះសំណូមពររបស់ពួកគាត់ទាំងបួន? ខ្ញុំ( ប្រាហឹម កៃ ) យល់ថា ពួកគាត់ ( ព្រឹទ្ធាចារ្យទាំងបួន) រៀបចំស្មើណាស់ក្នុងរឿងនេះហើយសថែលក៏បានយល់ព្រមដែរក្នុងរឿងនេះ ប៉ុន្តែគាត់នឹងយករឿងនេះ ទៅជជែកគ្នាជាក្រុមសិនឱ្យយល់និងឯកភាពផ្សះផ្សារគ្នា និងយល់ព្រមដើរចេញទាំងអស់គ្នាឱ្យចាស់ទុំបានរៀបចំធ្វើបុណ្យទានសប្បាយចិត្តរៀង។ខ្លួនថែលក៏សុខចិត្តតាមនោះដែរថែលក៏បានទាមទារខ្លះ។ដែរដូចជាថែលចង់ដាក់វត្តនេះឱ្យទៅជាសង្គមសាធារណៈ មានន័យថា អ្នកណាក៏ទៅចូលរួមធ្វើបុណ្យបានដែរ ខ្ញុំ( ប្រាហឹម កៃ) ថាយើងមិនអាចធ្វើឯករាជ្យអញ្ចឹងបានទេបើធ្វើដូចនេះ គឺមានបញ្ហាហើយ មានន័យថា អ្នកណាក៏ចូលបានហើយសត្រូវទាំងប៉ុន្មានដែលយើងមិនចង់ឱ្យចូលក៏មានសិទ្ធិចូលដែរពេលនោះដូចនេះពុំចាំបាច់ដាក់ជាសាធារណៈទេ ទុកឱ្យចាស់ទុំគាត់រៀបចំទៅវាចប់ហើយចំណែកគណកម្មការចាស់ចង់ឈរឈ្មោះជាថាបានដែរ ប៉ុន្តែទុកឱ្យចាស់ទុំគាត់រៀបចំវត្តឱ្យហើយសិន គឺទុករយៈពេលឱ្យគាត់រៀបចំសិនមុនរើសគណកម្មការថ្មី ។ ដូចនេះ គណកម្មការថ្មីសរសេរច្បាប់ថ្មីសំរាប់ខ្លួនគេហើយ គណកម្មការចាស់ត្រូវដើរចេញទុកឱ្យគេធ្វើហើយខំប្រឹងធ្វើអ្វីទៀតបើយើងធ្វើមិនកើតទៅ ហើយទុកឱ្យអ្នកថ្មីគេមានសមត្ថភាពធ្វើចុះ។ ដូចនេះទើបសំរេចឱ្យចាស់ទុំដឹកនាំវត្តដោយឯករាជ្យអត់មានអ្នកណាម្នាក់ទៅលូកលាន់ទៀតទេរីឯថែលគាត់មានគំនិតមួយថាធ្វើទៅតាមព្រឹទ្ធាចារ្យទាំងបួននាក់នោះទៅ។

**លោក ពិន សំខុន :** តើព្រឹទ្ធាចារ្យទាំងបួននាក់មានសំណើរអ្វីដែរឬទេ?

**លោក ប្រាហឹម កៃ:** មិនមានអ្វីទេ !

ប៉ុន្តែសុំឱ្យលោកគង់នៅដដែល ដើម្បីជួយថែរក្សាវត្តបន្តទៅមុខទៀតហើយនឹងសុំឱ្យសរសេរលក្ខខណ្ឌមុនពេលគណកម្មការចាស់លាលែងចេញជាលាយលក្ខអក្សរដូចជា "ខ្ញុំសូមលាលែងពីគណកម្មការដោយមិន មានទាមទារអ្វីទាំងអស់" រួចរាល់ត្រូវមានអ្នកច្បាប់ទាំងសងខាងដើម្បីចុះហត្ថលេខាទៅលើឯកសារជាផ្លូវការ។

**លោក ពិន សំខុន :** តើព្រឹទ្ធាចារ្យយល់យ៉ាងម៉េច ?

**លោក ប្រាហឹម កៃ:** ពួកគាត់បានឆ្លើយថា បើយល់ព្រមតាមគាត់ស្នើសុំ គឺគាត់ធ្វើតែបើដាក់លក្ខខណ្ឌមកត្រួតត្រាគាត់គឺគាត់អត់ធ្វើទេការងារនេះ។

តំណាងក្រុមប្រឹក្សាវប្បធម៌ខ្មែរក៏បានបញ្ចេញប្រតិកម្មទាក់ទិននឹងបញ្ហាវត្តត្រៃរតនារាមនេះថា "ការបិទទ្វារវត្តបែបនេះដូចជាដាក់គុកវត្ត" អ្នកតំណាងកវខដែលមានលោកចាន់ថា គឹម លោកសុវណ្ណខន និងលោក ជួប ឡឿក បាននិយាយថា ក.វ.ខ.ជាជួងសំរាប់ដាស់ឱ្យភាគីទាំងពីរធ្វើការសម្រុះសម្រួលគ្នាដើម្បីឱ្យវត្តអារ៉ាមដំណើរការឱ្យប្រជាជនធ្វើបុណ្យទានវិញបានចុងក្រោយនេះ ក.វ.ខ.បានផ្តល់យោបល់ថាបើសិនជាដំណោះស្រាយមុន។ជាប់គាំងមិនអាចឯកភាពគ្នាគួរតែងាកមករកដំណោះស្រាយទន់ភ្លន់មួយ ។

តទៅលេខក្រោយ



## Yet Another CNRP Official Arrested...

**Continued from page 19**

more problems for the very good environment of negotiations," Mr. Sovann said.

"We would like to negotiate under a good environment, we do not want to see problems occur again and again—this is theater that the CPP plays again and again."

The CPP and CNRP are presently deadlocked in negotiations over the qualifications that members of a reformed National Election Committee should have, and whether they should be allowed to hold foreign citizenships.

The arrest of seven CNRP lawmakers-elect and an official in July came only a week before Mr. Rainsy and Prime Minister Hun Sen suddenly announced an end to the country's political deadlock and the CNRP's 10-month boycott of their 55 National Assembly seats.

In the month that followed the July 22 deal, with the CNRP rejecting the CPP's wording in a draft for a new constitutional chapter that was part of the agreement, police arrested three CNRP youth leaders in Phnom Penh.

The trio was released two weeks after the CNRP folded to the CPP's demands and entered the National Assembly.

Mr. Sovannara joins Sum Puthy, a CNRP member of the Chbar Ampov district council who was arrested in September over the same protest, as one of two CNRP officials presently being detained in Prey Sar prison.

Mr. Sovann said Tuesday that he believed the ongoing talks between the parties over the election law could still go ahead even with the latest arrest of Mr. Sovannara.

"This will make negotiations difficult. However, we will try our best to continue the negotiations peacefully, and I believe my president, Sam Rainsy, will call the top leaders of the CPP to try to solve the problem," he said.

Mr. Sovann said he believed negotiations with the CPP would soon lead to Mr. Sovannara's release.

"The arrests have happened two or three times before. The solution will be very similar to before."

naren@cambodiadaily.com

## តមកពីទំព័រទី ២០ កោះតូចរមណីយដ្ឋានថ្មី...

ដោយឡែកអ្នកប្រកបរបរបើកកាណូត ដឹកភ្ញៀវទេសចរ ក៏ដូចជាអ្នកលក់ដូរភេសជ្ជៈ ម្ហូបអាហារផ្សេងៗនៅឆ្នេរកោះតូចបានដឹងស្រប គ្នាថា ពួកគាត់រកស៊ីកាក់កបគួរសមដែរ តាំងពីបង្កើតអតីតកោះ អ្នកទេសាទនេះ ឱ្យក្លាយជារមណីយដ្ឋានត្រជាក់ចិត្តមក។ ពីមុនពួកគាត់ទម្រាំបានត្រី មឹក ឬក្តាមយកទៅលក់ លុះងាកមកប្រកបរបរបម្រើសេវាទេសចរណ៍ឃើញថា បានកម្រៃងាយស្រួលមិនឡើយហត់ដូចមុនទេ។

គួរបញ្ជាក់ថា ក្រុងព្រះសីហនុចាប់ផ្តើមសាងជាបណ្តើរៗតាំងពីសម័យសង្គមរាស្ត្រនិយម ម៉្លេះ ដែលកាលនោះសម្តេចឪព្រះបរមរតនកោដ្ឋ បានយាងទៅត្រួសត្រាយជាដំបូងដោយយកព្រះនាមព្រះអង្គជាឈ្មោះក្រុង។ កាលលោក ហ៊ីង សាខុន កាន់តំណែងជាចៅហ្វាយក្រុងព្រះសីហនុ នាទសវត្សន៍ឆ្នាំ១៩៦០ ទឹកដីនេះ សុទ្ធតែព្រៃ មានខ្លាដំរី និងពស់ធំៗ លូន កាត់ផ្លូវចំណែកកោះ នៅឆ្ងាយពីដីគោក ពុំទាន់មានអ្នកចាប់អារម្មណ៍ទេ។ លុះឆ្លងមកដល់ពេលនេះ ក្រុងព្រះសីហនុបានប្រែប្រួលមុខមាត់យ៉ាងលឿន សូម្បីតែកោះតូច លំនៅអ្នកនេសាទ ក៏ក្លាយជាតំបន់ទេសចរណ៍ដែរ៕


# CLASSIFIED ADS

**CALL: 978.677.7163**

EMAIL: SOBENPIN@KHMERPOST.US

**Your classify ad is here for only $50 per month**

ពាណិជ្ជកម្មរបស់អ្នកនៅទីនេះ

ចំណាយចំណាយត្រឹមតែ

**$50** ក្នុង១ខែ

***CALL:***

***978.677.7163***

*EMAIL: SOBENPIN@KHMERPOST.US*

**សិក្សាពីឥស្លាម**

**សួរ :** មានចម្ងល់អ្វីទេពីឥស្លាម?

**ឆ្លើយ :** សូមទៅមើលគេហទំព័រ

www.peacetv.tv ឬគេហទំព័រ

មួយទៀត www.gainpeace.com.

Q) Any Questions on Islam?

A)watch www.peacetv.tv

visit www.gainpeace.com.

## ជាវសៀវភៅតាមកាសែតខ្មែរប៉ុស្តិ៍ស.រ.អា




រឿងរាមកេរ្តិ៍ ដោយសាគូ សាមុត តម្លៃ $10




របាំបុរាណខ្មែរ ដោយសាគូ សាមុត តម្លៃ $10




រឿងរាមកេរ្តិ៍ ដោយសាគូ សាមុត តម្លៃ $10




ក្រុងភ្នំពេញមុនឆ្នាំ១៩៥៤ តម្លៃ $10




CAMBODGE តម្លៃ $5




អង្គការជានរណា? ២ភាគ តម្លៃ $5/1

សូមកាត់ក្រដាសនេះផ្ញើមកយើង

| | |
|---|---|
| អាស័យដ្ឋានយើង៖ 45 Merrimack St., Suite 218A, Lowell, MA 01852 | ឈ្មោះសៀវភៅបញ្ជាទិញ តម្លៃ$........ |
| ឈ្មោះ និងអស័យដ្ឋានរបស់លោកអ្នក | តម្លៃ$........ |
| អស័យដ្ឋាន | ចំនួនសៀវភៅសរុប: |
| ក្រុង, រដ្ឋ, ហ្ស៊ីពខូដ | ថ្លៃសៀវភៅសរុប តម្លៃសរុប$..................... |

ទូរស័ព្ទ/ អ៊ីម៉ែល: សូមផ្ញើជា Check ឬ Money order ទៅ KhmerPostUSA នៅអាស័យដ្ឋានខាងលើ

# ជោគជតារាសីលោកអ្នក ទាំង១២ ប្រចាំឆ្នាំមមី

## ឆ្នាំជូត

រាសីល្អជាមធ្យម។ នៅថ្ងៃនេះការប្រកបការងារអ្វីត្រូវចេះមើលមុខក្រោយពីព្រោះថាផលអាក្រក់នោះងាយកើតឡើងនាំសៅហ្មងផង។ អ្នកប្រកបរបររកស៊ីជួញដូរនៅក្នុងថ្ងៃនេះដែរមានភាពល់នឹងល្អហើយទោះជួញទីជិតឆ្ងាយអាចរកផលកម្រៃចូលហៅៗគ្រាន់សម្រាប់ការចាយវាយ។ ការធ្វើដំណើរទីជិតឆ្ងាយជួបភាពសុខដុមទាំងពេលទៅនិងត្រឡប់មកវិញ ។ បញ្ហាគូស្នេហាកំលោះក្រមុំពុំគប្បីយកភាពប្រកែប្រកាន់និងកំហឹងទល់កំហល់ដាក់ខ្លួនប្រយ័ត្នកើតរឿងជម្លោះវិវាទឥតឈប់ឈរហើយឈានមិនដល់ខ្លោងទ្វារអាពាហ៍ពិពាហ៍។

## ឆ្នាំឆ្លូវ

រាសីស្រុតចុះ។ ក្នុងថ្ងៃនេះដំណើរជីវិតរបស់លោកអ្នកស្រុតចុះដូចនេះមិនផ្តល់ផលល្អក្នុងការប្រកបការងារដែលសំខាន់ ឬកិច្ចការងារណាដែលធំដុំពេកឡើយ ពីព្រោះថា ផលមិនល្អនោះតែងឆ្លើយតបច្រើនជាងសព្វមួយដង។ អ្នកប្រកបរបររកស៊ីជួញដូរមានការទិញចូលលក់ចេញគ្រាន់បើតែយ៉ាងណាលោកអ្នកទាល់តែខិតខំខ្លាំងទើបទទួលជោគជ័យជំនួញធំៗទៅរួច ។ ការធ្វើដំណើរចេញក្រៅផ្ទះលោកអ្នកចូរប្រយ័ត្នការមានជម្លោះវិវាទសម្តីបន្តិចបន្តួចដោយសារការមិនចុះសម្រុងគ្នា ឬការប្រឆាំងគ្នាដោយប្រការណាមួយ ។ រីឯសម្ព័ន្ធស្នេហាកំលោះក្រមុំមានការប្រែប្រួលប្តូរផ្លាស់ព្រោះជួនត្រូវរ៉ូវគ្នាជួនទស់ទែងគ្នា ។

## ឆ្នាំខាល

រាសីល្អជាមធ្យម។ ក្នុងរយៈពេលនេះការរស់នៅលោកអ្នកត្រូវបំបាត់ភាពប្រកែប្រកាន់ចេញពីខ្លួនខ្លះទើបប្រសើរដែលមិនមានបញ្ហានាំឱ្យត្រូវឈឺក្បាល ហើយកើតតែរឿងរាវចំពោះមុខ។ ការបំពេញការងារនៅថ្ងៃនេះវិញមានការរីកលូតលាស់សន្សឹមៗទៅមុខតែបើចង់លោភលន់វិញមិនគាប់ដូចបំណងទេតែងខកបំណងច្រើនជាង។ សម្រាប់អ្នកប្រកបរបររកស៊ីជួញដូរមានការទិញចូលលក់ចេញដាច់មួយៗគ្រាន់បង្គ្រប់ឆ្នាំងបាយ ប៉ុន្តែយ៉ាងណាសម្រាប់ស្ត្រីឱ្យប្រយ័ត្នកើតជម្លោះវិវាទដោយសារក្រុមមនុស្សបាបមិត្តបង្កឡើង។ រីឯសម្ព័ន្ធស្នេហាប្រុសស្រីកុំចង់សាកល្បងកាមគុណពិសេសស្ត្រីប្រយ័ត្នកើតរឿងធំខូចទាំងកិត្តិយសអស់ទាំងអនាគតភ្លឺស្វាង។

## ឆ្នាំថោះ

រាសីខ្ពស់ត្រដែត ។នៅថ្ងៃនេះលោកអ្នកអាចមានជោគសំណាងខាងបញ្ហាទំនាក់ទំនងបន្តិច ព្រោះបើមានការស្នើសុំ ឬចង់បានអ្វីមួយដែលមិនធំដុំពេកតែងអ្នកដទៃគេអាណិតស្រឡាញ់ និងជួយជ្រោមជ្រែងជានិច្ច។ ក្រៅពីនេះទោះលោកអ្នកប្រកបកិច្ចការអ្វីក៏ដោយមានការចម្រើនលូតលាស់ទៅមុខជាសន្សឹមៗឥតថយក្រោយឡើយ។ ចំពោះអ្នកប្រកបរបររកស៊ីជួញដូរពេលនេះប្រៀបដូចបានជា"ភ្លៀងធ្លាក់មួយមេមេឃស្រឡះ"ព្រោះអាចកម្ចាត់រាល់ឧបទ្រពចង្រៃទាំងពួងឱ្យវិនាសជាអហោសិកម្មអស់ហើយលោកអ្នកអាចប្រកបមុខរបរពេញដៃពេញជើងឡើងវិញ ។ រីឯបញ្ហាសេចក្តីស្នេហាកំលោះក្រមុំមានការរីកលូតលាស់និងផ្អែមល្ហែមប្រពៃណាស់។

## ឆ្នាំរោង

រាសីខ្ពស់ត្រដែត។ នៅថ្ងៃនេះការងារតូចធំលោកអ្នកអាចសម្រុកពេញទីបានហើយពីព្រោះថាផ្លែផ្កាល្អៗតែងហុចមកវិញគ្រាន់ជាទីពេញចិត្តជានិច្ច។ សម្រាប់អ្នកប្រកបការងាររកស៊ីជួញដូរពេលនេះដួងរាសីមិនប្រសើរទេ ពិសេសបុរសដូចនេះទោះប្រកបការងារអ្វីក៏តោងតែប្រយ័ត្នប្រយែងបន្តិច ។ការធ្វើដំណើរឆ្ងាយជិតចូរប្រយ័ត្នបញ្ហាក្រុមមនុស្សបៀតបៀនយាយី។ រីឯបញ្ហាសេចក្តីស្នេហាកំលោះក្រមុំបើស្គាល់ចិត្តស្គាល់ថ្លើមគ្នាយូរហើយជាឱកាសល្អបំផុតក្នុងការរៀបចំផ្សំផ្គុំគ្រួសារហើយ។

## ឆ្នាំម្សាញ់

រាសីល្អជាមធ្យម។ នៅថ្ងៃនេះការប្រកបការងារអ្វីត្រូវចេះមើលមុខក្រោយ ពីព្រោះថាផលអាក្រក់នោះងាយកើតឡើងនាំសៅហ្មងផង។ អ្នកប្រកបរបររកស៊ីជួញដូរនៅក្នុងថ្ងៃនេះដែរមានភាពល់នឹងល្អហើយទោះជួញទីជិតឆ្ងាយអាចរកផលកម្រៃចូលហៅៗគ្រាន់សម្រាប់ការចាយវាយ។ ការធ្វើដំណើរទីជិតឆ្ងាយជួបភាពសុខដុមទាំងពេលទៅនិងត្រឡប់មកវិញ។ បញ្ហាគូស្នេហាកំលោះក្រមុំពុំគប្បីយកភាពប្រកែប្រកាន់ និងកំហឹងទល់កំហល់ដាក់ខ្លួនប្រយ័ត្នកើតរឿងជម្លោះវិវាទឥតឈប់ឈរហើយឈានមិនដល់ខ្លោងទ្វារអាពាហ៍ពិពាហ៍។

## ឆ្នាំមមី

រាសីល្អជាមធ្យម។ ក្នុងថ្ងៃនេះដំណើរជីវិតរបស់លោកអ្នកមិនល្អប្រសើរទេ ដូចនេះទោះធ្វើអ្វីតោងតែមានការអត់ធ្មត់ព្យាយាមខ្លះទើបអាចដោះស្រាយបញ្ហាមួយចំនួនដាច់ស្រេចទៅរួច ។ សម្រាប់អ្នកប្រកបរបររកស៊ីជួញដូរវិញលោកត្រូវចេះរៀបចំបញ្ហាបញ្ជីប្រាក់កាសឱ្យបានច្បាស់លាស់ពីព្រោះថា ងាយកើតបញ្ហាភាន់ច្រឡំណាមួយឡើងជាងសព្វមួយដង។ ការធ្វើដំណើរទីជិតឆ្ងាយមិនសូវមានសុវត្ថិភាពប៉ុន្មានទេ ពិសេសអ្នកបើកបរហាមសេពគ្រឿងស្រវឹង។ បញ្ហាសេចក្តីស្នេហាកំលោះក្រមុំពិសេសស្ត្រីឱ្យប្រយ័ត្នគ្រោះចាញ់បោកភាគីម្ខាងទៀត ដោយប្រការណាមួយហើយមកដេកសោកស្តាយអនាគតភ្លឺស្វាងឥតអំពើ។

## ឆ្នាំមមែ

រាសីស្រុតចុះ។ នៅថ្ងៃនេះលោកអ្នកធ្វើអ្វីតែងលេចបាតុភាពរាំងស្ទះជាពិសេសធ្វើច្រើនទទួលបានផលតិចថែមទៀត។ ទាំងស្ត្រីបុរសពេលនេះងាយឈ្លក់វង្វេងនឹងល្បែងស៊ីសងណាស់ប្រយ័ត្នជាប់ផុងខ្លួនហើយក្រែងដកពុំរួច។ សម្រាប់អ្នកប្រកបរបររកស៊ីជួញដូរមុនធ្វើអ្វីមួយត្រូវចេះត្រិះរិះពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយហើយពុំត្រូវមានគំនិតវៀចវេឡើយ បើពុំនោះទេនាំជួបផលលំបាកដល់អាត្មាខ្លួនឯងដោយសារអតិថិជនលែងមកក្បែរ។ រីឯបញ្ហាស្នេហាកំលោះក្រមុំក្នុងពេលនេះជួនត្រូវជួនឈ្លោះធ្វើឱ្យកើតការខ្វាយខ្វល់ឥតសូវស្បើយប៉ុន្មានឡើយ ។

## ឆ្នាំវក

រាសីខ្ពស់ត្រដែត។ នៅថ្ងៃនេះដំណើរជីវិតរបស់លោកអ្នកភ្លឺថ្លា ហើយធ្វើអ្វីក៏តែងមានភ្លើងខៀវបើករង់ចាំច្រើនចំពោះមុខជានិច្ច។ សម្រាប់លោកអ្នកដែលប្រកបរបររកស៊ីជួញដូរការរកផលចំណូលមានហូរចូលគ្រាន់គួរជាទីកក់ក្តៅហើយបើចង់ជួញផ្លូវឆ្ងាយផងជាការប្រសើរដោយលោកអ្នកអាចកើបផលចំណូលត្រឡប់មកវិញយ៉ាងស្រួលចិត្ត។ រីឯបញ្ហាស្នេហាកំលោះក្រមុំមានការលូតលាស់ទៅមុខ និងផ្អែមល្ហែមគួរជាទីកក់ក្តៅ។

## ឆ្នាំរកា

រាសីល្អជាមធ្យម។ នៅថ្ងៃនេះបើទោះបីមានរឿងរាវចូលមកកក្កូរផ្លូវចិត្តបន្តិចក្តីតែក៏មិនមានឧបសគ្គអ្វីនាំទុក្ខព្រួយដែរដោយលោកអ្នកអាចធ្វើការដោះស្រាយគ្រាន់ធូរចិត្តទៅវិញ ។ ការប្រកបការងារលោកអ្នកឱ្យប្រយ័ត្នជួបរឿងធ្វើច្រើនខុសច្រើនហើយបើទោះបីលោកអ្នកខំរត់ចុះឡើងក៏ពុំសូវសម្រេចដូចគាប់បំណងដែរ គឺតែងខកបំណងច្រើនជាង។ ចំពោះអ្នកប្រកបរបររកស៊ីជួញដូរ ក៏ដូច្នេះដែរ ការចង់បោះទុនទៅលើអ្វីមួយត្រូវមើលមុខមើលក្រោយ ព្រោះផ្លែផ្កាទទួលបានមកវិញ មានភាពយ៉ាប់យ៉ឺន និងបញ្ហាចូលមកលុកលុយច្រើន។ រីឯសម្ព័ន្ធស្នេហាប្រុសស្រីមានដំណើរប្រទាំងប្រទើសដែលងាយកើតរឿងជម្លោះវិវាទណាស់។

## ឆ្នាំច

រាសីស្រុតចុះ។ ក្នុងថ្ងៃនេះដួងរាសីមិនគាប់ប្រសើរប៉ុន្មានទេ ដូច្នេះបើទោះបីធ្វើអ្វីមួយក៏ដោយត្រូវប្រយ័ត្នប្រយែង ហើយមិនត្រូវជឿពាក្យអុជអាលអ្នកដទៃដែរ បើពុំនោះទេ រឿងខ្លះតូចតាចសោះ អាចរីកក្លាយជាធំជាក់ជាពុំខាន ។ សម្រាប់អ្នកប្រកបរបររកស៊ីជួញដូរមានការទិញចូលលក់ចេញគ្រាន់រស់រវើកបន្តិចវិញប៉ុន្តែយ៉ាងណាផលកម្រៃក៏មិនសូវឆ្លើយតបដូចសេចក្តីប៉ងប្រាថ្នាទេ ឬអាចនិយាយបានថាគ្រាន់មួយទប់ទល់ចាយវាយ។ រីឯបញ្ហាសេចក្តីស្នេហាកំលោះក្រមុំងាយទាំងទាស់ទែង និងត្រូវរ៉ូវគ្នា។

## ឆ្នាំកុរ

រាសីល្អជាមធ្យម។ នៅថ្ងៃនេះលោកអ្នកមិនមានអ្វីចូលមកយាយីនាំពិបាកឆ្លងកាត់ទេហេតុនេះមិនថា ជាការងារបញ្ហាប្រាក់កាស គឺមានការជឿនលឿនសន្សឹមៗដូចសព្វមួយដង។ ទោះបីយ៉ាងណាបញ្ហាសុខភាពរបស់លោកអ្នកមិនល្អប្រសើរទេគប្បីមានការប្រយ័ត្នប្រយែងបន្តិច ។ សម្រាប់អ្នកប្រកបរបររកស៊ីជួញដូរក្នុងថ្ងៃនេះដែរចូរប្រយ័ត្នក្រុមមនុស្សអុជអាលអ្វីមួយនាំឱ្យកើតការក្តៅក្រហាយបង្កជាជម្លោះជាមួយអ្នកដទៃឡើង។ រីឯបញ្ហាសេចក្តីស្នេហាប្រុសស្រី ចូរប្រយ័ត្នក្រុមមនុស្សទីពាចូលមកអុកឡុកនាំកើតជម្លោះវិវាទឈានដល់ការបែកបាក់។

# KhmerPost USA

The Cambodian-American Biweekly Newspaper

សារព័ត៌មានខ្មែរ-អាមេរិក ចេញពីរសប្តាហ៍ម្តង

a free local newspaper reaching over 20,000 Cambodian readers in the Greater Lowell area every two weeks

ផ្តល់ជូនកាសែតឥតគិតថ្លៃដល់អ្នកអានខ្មែរច្រើនជាង២០០០០នាក់នៅតំបន់ឡូវែលរាល់ពីរសប្តាហ៍ម្តង

**Soben Pin, Managing Partner** អ្នកគ្រប់គ្រង សុបិន្ត ពិន

## 978.677.7163 (Office) 978. 656.8141 (Mobile)

សូមកក់ពាណិជ្ជកម្មអ្នកជាមួយយើងខ្ញុំ ហើយទទួលបានការបញ្ចុះតម្លៃ២០%

## Reserve Your 2014 Ads with us today and receive up to 20% OFF!

**(Please mention this coupon ad: Summer 2014)**

## Sample of our affordable pricing បញ្ជីតម្លៃពាណិជ្ជកម្មក្នុងតម្លៃសមរម្យ

| ទំហំទំព័រ Page Size | ប្រវែង Length x Width | 1ខែ 1 month 10%OFF |
|---|---|---|
| 1/2 page color | (6.5"x10") | $484 |
| 1/4 page color | (6.5"x5") | $264 |
| 1/4 Classify Ad | (6.5"x5") | $160 |
| 1/8 Classify ad | (3.25"x5") | $100 |
| Business Card | | $50 |

## Our 2014 Publishing Dates កាលវិភាគបោះពុម្ព

November 7th & 21st
December 5th & 19th

*all ad materials are due one week prior to publishing date.
រាល់គំរូពាណិជ្ជកម្មត្រូវបញ្ជូន1សប្តាហ៍មុនចូលរោងពុម្ព




## Call or Visit our Sales Office

45 Merrimack Street. Suite 218A. Lowell, MA 01852
Tel: 978.677.7163. Cell: 978. 656.8141 Fax: 978.677.7092
Email: sobenpin@khmerpost.us or KhmerPostUSA@gmail.com
www.khmerpost.us | www.facebook.com/KhmerPostUSA

# City of Lights Parade

# ដង្ហែក្បួនឆ្នាំ២០១៤ នៅឡូវែលក្រុងដែលពោរពេញដោយពន្លឺ

## 2014 City of Lights Parade & Holiday Celebration

**Saturday, November 29 | 12pm – 8pm ថ្ងៃសៅរ៍ ទី២៩ វិច្ឆិកា ឆ្នាំ២០១៤**
**Visit Lowell.org for details!**
**Parade Start Time is 4:30pm ចាប់ផ្តើមនៅម៉ោង៤:៣០នាទីរសៀល**
**Event Information Center is at 103 Market Street**

**Children's Shopping Day at the Pollard Memorial Library** នាំក្មេងទៅសប់ភីងនៅបណ្ណាល័យផូឡាដ
**Pollard Memorial Library (Ground Floor Meeting Room)**
**401 Merrimack Street**
10AM - 1PM: Kids ages 4-14 years only
1PM - 2PM: Members of the Friends of the Library and kids ages 4-14 years only
2PM - 4PM: General Public welcomed
Select from hundreds of donated gently-used items ranging from $1 to $5. មានលក់តម្លៃ១-៥ដុល្លារ

**3rd Annual Holiday Shopping Tour via the COOL Bus** ជិះឡានឃូសបើសដើរសប់ភីងថ្ងៃបុណ្យទី៣
**12PM - 3:30PM throughout Downtown Lowell (round-trip loop)**
Free event! Ride the Cultural Organization of Lowell's "COOL Bus" and visit 11 museums & galleries!

**"Reading with Rowdy" with UMass Lowell Mascot Rowdy the Riverhawk** អានសម្លេងក្នុងក្តាំងជាមួយនឹង យូម៉ាស ឡូវមាស្កត់
**12PM: River Hawk Shop at University Crossing**
Free event! Join Rowdy the Riverhawk and UMass Lowell student-athletes for a kid's holiday book reading.

**"Holly Jolly Trolley" with Ranger Elves, Music & Holiday Decorations** ជិះត្រូលឡេហោលីចូលី ស្តាប់ចម្រៀង និងការតុបតែងបុណ្យ
**12PM - 4PM: Boott Cotton Mills to National Park Visitor Center (Round-trip Loop)**
**Free event, no reservations required!**

**Photos with Santa** ថតរូបជាមួយ សានតា
**1PM - 3PM: Lowell City Hall, 375 Merrimack Street**
Cost is $2 per photo. Line closes promptly at 3pm!
ថតរូប១ថ្លៃ២ដុល្លារ ថតនៅម៉ោង៣រសៀល

**Holiday Art Exploratory for Kids** នាំក្មេងទៅធ្វើគ្រឿងតុបតែងដើមគ្រីស្តម៉ាស់
**1PM - 4PM: 103 Market St (Next to Market Street Market)**
Free event! Make spectacular spin art creations and scratch art ornaments for your tree (while supplies last).

**Gentlemen Songsters Stroll Around Downtown** ចម្រៀងជាពួក ដើរជុំវិញដោនថោន
**1PM - 4PM: Throughout Downtown Lowell**
The Gentlemen Songsters sing holiday favorites in downtown Lowell!

**7th Annual Hot Chocolate Competition** ប្រណាំងធ្វើសូកូឡាក្តៅឆ្នាំទី៧
**2PM - 4PM: Visit Lowell.org for a full list of participants** មើលគេហទំព័រនេះដើម្បីស្គាល់ទីតាំង
Cost is 25 cents per 4oz sample. Vote for your favorite hot chocolate at NINE locations! តម្លៃ កែវចំណុះ ៤០២ថ្លៃ ២៥សេន

**Self-Guided Tours of St. Anne's Church ចូលទស្សនាវិហារ Stanne** ដោយខ្លួនឯង
**2PM - 6PM: St. Anne's Church, 8 Kirk Street**
Free event! Visit this beautiful church in the heart of downtown Lowell.

**"The Lucky Show" With Robert Clarke - Magician, Juggler, and Funny Guy** មើលគេលេងវេទមន្តនៅធនាគារ
**3PM: Lowell Five Bank, 34 John Street** ឡូវែលហ្វាយ
Free event! This one-of-a kind live show is great for kids and families!

**City of Lights Parade and City Hall Holiday Lighting** ដង្ហែក្បួនផារ៉េដផ្តើមនៅម៉ោង៤:៣០នាទីរសៀល ផ្តើមនៅផ្លូវ ចេក សឹន
**4:30PM - 6:30PM: Parade route starts on Jackson Street**
Holiday lighting of downtown Lowell, City Hall, and the Wannalancit Smokestack Tree takes place at the end of the parade! បញ្ចប់នៅផ្លូវសាលាក្រុង

**Annual City of Lights Choral Concert at St. Anne's Church** ចុងបញ្ចប់ទៅច្រៀងចម្រៀងនៅវិហារសេនអាន់
**6:30PM: St. Anne's Church, 8 Kirk Street**

Hockey Match Up at UMass Lowell Tsongas Center: Riverhawks vs. Harvard
7PM: UMass Lowell Tsongas Center

**Event Sponsors** **Parade Sponsor** **Band Sponsors** **City of Lights is presented by:**